ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2016, 13:24
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៨នាទី**

**សវនាការលើកទី៣៦៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ
កញ្ញា ជា ស៊ីវហ៊ាង
កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង
លោក ស្រ៊ា រតនៈ
លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក សាន់ ឡូន (2-TCW-1007) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក សាន់ ឡូន** (2-TCW-1007)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........ ទំព័រ ៦
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........ ទំព័រ ១៦
សួរដោយលោក សេង លាង ផ្ដើមពី ........ ទំព័រ ៤៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៤៨
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........ ទំព័រ ៥១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបានកំណត់ធ្វើសវនាការបន្តស្តាប់សក្ខីកម្ម អ៊ិន យឿង ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1007។ ប៉ុន្តែដោយសារលោកស្រី អ៊ិន យឿង ដែលអង្គជំនុំជម្រះបានធ្វើសវនាការស្តាប់រយៈពេល១៥នាទីកាលពីម្សិលមិញនេះ នៅថ្ងៃនេះគាត់មានបញ្ហាសុខភាព ត្រូវទទួលការសម្រាកព្យាបាលជាបន្ទាន់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនៅពេលនេះចាប់ផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-1007។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ៑ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-1007។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិពន្ធ ឬញាតិលោហិតជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា ឬលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:១០:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះ រ៉ាំរ៉ៃ អង្គុយយូរកាន់តែធ្វើឲ្យចង្កេះឈឺកាន់តែខ្លាំង និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-1007 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកសាក្សី តើលោកឈ្មោះអី?

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ សាន់ ឡូន។

[០៩:១៤:០៩]

**ស៖** អរគុណលោក សាន់ ឡូន។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

**ឆ៖** ថ្ងៃខែឆ្នាំកំណើត ខ្ញុំអត់បានចាំ ភ្លេច។

**ស៖** ឆ្នាំនេះ លោកអាយុប៉ុន្មានហើយ?

**ឆ៖** បាទ អាយុ៧៣ឆ្នាំ។

**ស៖** អរគុណលោក សាន់ ឡូន។ ហើយតើលោកមានទីកន្លែងកំណើតនៅកន្លែងណាដែរ?

**ឆ៖** បាទ ខ្ញុំទីកន្លែងកំណើត កើតនៅភូមិប្រគាប ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ សព្វថ្ងៃរស់នៅ អាសយដ្ឋានសព្វថ្ងៃនៅភូមិស្រះឈូក ស្រុកអន្លង់វែង – ឃុំត្រពាំង-ប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** បានប្រកបការងារមុខរបរអ្វីទេ នៅជាមួយកូន។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** បាទឪពុកខ្ញុំឈ្មោះ សាន់ ង៉ែត, ម្ដាយឈ្មោះ អ៊ុក ញ៉ែម គាត់ស្លាប់ ស្លាប់អស់ហើយ។

**ស៖** ប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ គ្រួសាររបស់ខ្ញុំឈ្មោះ ផូ ថន ខ្ញុំមានកូនប្រាំនាក់។

[០៩:១៦:៣២]

**ស៖** អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះទេ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់មានការពាក់ព័ន្ធជាមួយនឹងលោក ខៀវ សំផន – តាខៀវ សំផន, នួន ជា ទេ

បាទអត់ អត់មានការពាក់ព័ន្ធអីទេ។

**ស៖** តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកដែលនៅពីខាងកើតសាលសវនាការនៃអ.វ.ត.ក នេះហើយឬនៅ?

**ឆ៖** បាទ បានធ្វើបានសម្បថរួចហើយ។

**ស៖** បន្តទៅនេះ យើងប្រាប់ពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះ លោក សាន់ ឡុន។ អំពីសិទ្ធិក្នុងនាមជាសាក្សី – លោក សាន់ ឡុន ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏ឲ្យលោកធ្វើការរៀបរាប់ណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[០៩:១៨:១៣]

អំពីករណីយកិច្ច លោក សាន់ ឡុន ក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក សាន់ ឡុន តើលោកដែលធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ រយៈពេលកន្លងមក? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា លោកចាំដែរទេ?

**ឆ៖** ការសម្ភាសខ្ញុំបានមកម្តង។ សម្ភាសនៅកន្លែងនេះ ហើយកាលបរិច្ឆេទថ្ងៃខែអីអត់បានចាំ។

**ស៖** បាទ អរគុណ។ ហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល បានអាន ឬក៏ស្តាប់ការអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនដែលលោកអះអាងថាម្តងអម្បាញ់មិញនេះ ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ ការសម្ភាស សេចក្តីសម្ភាស ខ្ញុំបានអាន ហើយចាំខ្លះ អត់បានចាំខ្លះ។ បានអានពី

ម្សិលមិញ យប់ក៏បានអាន។

[០៩:២០:១៤]

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលលោកផ្តល់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងអ្វីដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែលលោកថាបានធ្វើម្តងនៅទីនេះនោះ វាស្របគ្នាដែរឬទេ?

**ឆ៖** បាទ ស្រប ៗតាម ត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី នួន ជា សួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី ហើយសហមេធាវីការពារក្តីទាំងពីរក្រុមមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះដែលជាការអនុវត្ត គឺមេធាវីការពារក្តីលោក ខៀវ សំផន នឹងសួរក្រោយគេបង្អស់ក្នុងចំណោមភាគីទាំងអស់នៃរឿងក្តីនេះ។ សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីសហព្រះរាជអាជ្ញា ហើយនិងលោកសាក្សីផងដែរ។ លោកប្រធាន ខ្ញុំមានមតិសង្ខេបមុនខ្ញុំចាប់ផ្តើមសួរសាក្សីរូបនេះ។ ខ្ញុំមានសេចក្តីរីករាយដើម្បីនឹងចាប់ផ្តើមសួរសំណួរសាក្សីរូបនេះ ប៉ុន្តែទោះយ៉ាងណាក្តី ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា យើងបានស្នើសុំសាក្សីនេះដើម្បីឱ្យកោះអញ្ជើញគាត់ទាក់ទងនឹងស្រុកត្រាំកក់ មិនជាពិសេសទាក់ទងទៅនឹងផ្នែកដែលនិយាយអំពីប្រព្រឹត្តកម្មលើជនជាតិវៀតណាមទេ។ ខ្ញុំគិតថាគឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការកោះហៅក្នុងប្រធានបទនោះ។ ហើយនិងខ្ញុំសួរសំណួរអំពីផ្នែកដែលទាក់ទងទៅនឹងជនជាតិវៀតណាម ក៏ប៉ុន្តែខ្ញុំគិតថាដើម្បីឱ្យវាសមស្រប ប្រសិនបើមានភាពចាំបាច់ ខ្ញុំមិនទាន់ប្រាកដទេ ខ្ញុំមិនទាន់អាចនឹងសួរដេញដោលបន្ថែមទៀត បន្ទាប់ពីសហព្រះរាជអាជ្ញាក្នុងករណីសាក្សីនេះប្តូរលំដាប់លំដោយបែបនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:២២:៥៥]

**លោក ខេល លីសាក់៖**

ខ្ញុំមិនមានការជំទាស់អ្វីទេ បើសិនជាមេធាវីការពារក្តីអាចនឹងមានពេលបន្ថែម មិនជាកត្តាសំខាន់អ្វីទេដែលថាខ្លួនកោះគាត់ពីបញ្ហាសហករណ៍ត្រាំកក់ ហើយក៏ថាអាចសួរពីបញ្ហាផ្សេងទៀតក្រៅពីសហករណ៍ត្រាំកក់នោះ។ ប៉ុន្តែអ៊ីចឹងគឺថាក្នុងវិសាលភាពដែលថាមានបញ្ហាថ្មីកើតមានឡើង យើងមិនមានការជំទាស់ទៅនឹងអ្វីដែលមេធាវីសុំពេលបន្ថែមនៅចុងបញ្ចប់ដើម្បីសួរទៅសាក្សីនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ។ ហើយបញ្ជាក់ឡើងវិញដើម្បីងាយស្រួល ព្រោះបញ្ហាករណីនេះ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តីគឺមានបានដាក់សំណើដាច់ដោយឡែក ហើយសូមស្តាប់សក្ខីកម្មហ្នឹងពិតមែនតែពាក់ព័ន្ធនឹងប្រធានបទសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់មែន ប៉ុន្តែគឺនៅក្នុងកាលៈទេសៈនេះ គឺមេធាវីការពារក្តីអាចសួរដេញដោលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលតាមបំណងប្រាថ្នារបស់លោកបាន ព្រោះអង្គហេតុនោះ ក៏អង្គជំនុំជម្រះបានកំណត់សម្រាប់ធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០២ដែរ។ ហើយអង្គហេតុ ប្រសិនបើយើងស្តាប់មុន ក៏យើងអាចស្តាប់ពាក់ព័ន្ធជាមួយនឹងសក្ខីកម្មដែលគាត់ដឹងនូវអង្គហេតុផ្សេងទៀតដែរ ប៉ុន្តែបើធ្វើដូច្នេះ វា។អាចទំនងជាមានបញ្ហាអ៊ីចឹងហើយបានជាយើងផ្តល់លទ្ធភាពជូនភាគី ហើយនិងជាពិសេសលោកមេធាវីការពារក្តីអាចសំណួរពាក់ព័ន្ធនឹងបញ្ហានុ៎ង។ ហើយបញ្ហាផ្សេងទៀត ប្រសិនបើចាំបាច់ នៅពេលដែលត្រូវការតាំងសំណួរដេញដោលបន្ទាប់ពីស្តាប់សក្ខីកម្ម -- ស្តាប់ការសួរដេញដោលភាគីម្ខាងទៀត ខាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គជំនុំជម្រះនឹងពិនិត្យសម្រេចតាមស្ថានភាពជាក់ស្តែង។

[០៩:២៥:០៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរគុណលោកប្រធាន។ សូមជម្រាបសួរម្តងទៀតលោកសាក្សី។ ខ្ញុំនឹងសួរលោក សំណួរមួយចំនួនដំបូងអំពីប្រវត្តិរបស់លោក។ តើត្រឹមត្រូវឬទេ ថាលោកមិនត្រឹមតែកើតនៅស្រុកត្រាំកក់ ខេត្តតាកែវទេ ប៉ុន្តែលោកក៏បានទៅរៀនសូត្រនៅទីនោះដែរ រហូតមកដល់ឆ្នាំ១៩៧៥, ៧៦ លោកចំណាយ

ពេលរស់នៅរហូតនៅក្នុងស្រុកនោះ គឺស្រុកត្រាំកក់ ត្រូវទេលោកសាក្សី?

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកនៅចាំដែរឬទេ ការរស់នៅក្នុងស្រុកត្រាំកក់ ហើយតើនៅក្នុងទីរួមខេត្តតាកែវនោះលោកចងចាំបានអ្វីខ្លះ មិនត្រឹមតែស្រុកត្រាំកក់ទេ?

**ឆ៖** បាទ អត់ទេ អត់បានចងចាំអីទេ ការស្មោះត្រង់ហើយ។

**ស៖** ខ្ញុំនឹងសួរពីបញ្ហានេះក្នុងពេលខ្លីខាងមុខ។ តើត្រឹមត្រូវដែរឬទេ ដែលថាលោកមានទំនាក់ទំនងគ្រួសារជាមួយ តាម៉ុក?

**ឆ៖** បាទ ស្តាប់អត់ទាន់យល់។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាលោកមានជាទំនាក់ទំនងគ្រួសារ ឬក៏ជាប់សាច់ញាតិជាមួយ តាម៉ុក ជាសាច់ថ្លៃ ឬក៏អ្វីក៏ដោយ?

**ឆ៖** បាទ ខ្ញុំជាប្អូនថ្លៃរបស់ តាម៉ុក ហើយគ្រួសារ តាម៉ុក ជាបងរស់ខ្ញុំ។

[០៩:២៧:២០]

**ស៖** ដូច្នេះដែលថារយៈពេលវែងដែលលោកស្គាល់ តាម៉ុក តាមរយៈទំនាក់ទំនងដែលជាសាច់ថ្លៃនេះ តើរយៈពេលប៉ុនណា ដែលលោកស្គាល់គាត់?

**ឆ៖** បាទ កាលណោះខ្ញុំវានៅតូច ហើយល្មមដឹងថាជាបង ម្ល៉ោះហើយស្គាល់គាត់ ជាបងថ្លៃរបស់ខ្ញុំ កាលនៅតូចៗ។

**ស៖** ខ្ញុំនឹងសួរសំណួរច្រើនអំពី តាម៉ុក។ រូបលោកផ្ទាល់ហ្នឹង គឺអ្នកស៊ើបអង្កេតបានសួរលោក ដែលថាអ្នកស៊ើបអង្កេតហ្នឹងមកពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃសាលាក្តីនេះឯង។ នៅក្នុងឯកសារ E3/9487 ហើយនៅក្នុងសំណួរចម្លើយ១២១ និង១២៣ ហើយលោកហៅថា តាម៉ុក គឺជាមេដឹកនាំកំពូលរបស់ខ្មែរក្រហម។ តើត្រឹមត្រូវដែរឬទេ ដែលលោកបានឆ្លើយបែបនេះទៅអ្នកស៊ើបអង្កេតនោះ?

**ឆ៖** បាទ អ្នកដឹកនាំកំពូល កំពូលគឺ ប៉ុល ពត ហើយបន្ទាប់មក តាម៉ុក បន្ទាប់ – បន្ទាប់ពី ប៉ុល ពត។

**ស៖** តើលោកដឹងដែរឬទេថា តាម៉ុក មានលេខសំគាល់ជាលេខកូដ ដែលគេហៅគាត់ថាជាតួ

ជាលេខទេ ជាលេខកូដ តើលោកដឹងទេ?

**ឆ៖** នេះតាមខ្ញុំដឹង ដឹងតាមគេហៅថាគាត់ថា តា១៥៧ ហ្នឹងតាមឮតាមគេនិយាយ គេហៅគាត់។

**ស៖** ដោយហេតុថា ជាសមាជិកជិតស្និទ្ធទៅនឹងគាត់ តើលោកដឹងពីមូលហេតុ ថាហេតុអីបានគេហៅគាត់ តា១៥? ដោយហេតុថាគាត់គឺជាមេដឹកនាំខ្ពស់ជាងគេ ដែលថាបន្ទាប់ពី ប៉ុល ពត ដឹងពីមូលហេតុថា ហេតុអីគេហៅគាត់ តា១៥ ដែរឬទេ?

**ឆ៖** ថាម៉េច ខ្ញុំអត់យល់ អត់យល់ដែរ។ ខ្ញុំអត់ដឹង។

**ស៖** បាទ មិនជាបញ្ហាសំខាន់ណាស់ណាទេ ខ្ញុំនឹងបន្តទៅទៀត។ លោកសាក្សី តើលោកមានកាន់តំណែង ឬក៏មុខងារអ្វីទេ រវាងឆ្នាំ១៩៧៥រហូតដល់១៩៧៩ នៅក្នុងស្រុកត្រាំកក់? បាទដែលថាជាមុខងារ ជាថ្នាក់ដឹកនាំ ឬក៏ជាកម្មាភិបាលដឹកនាំអ្វីមួយនោះ?

**ឆ៖** បាទ ខ្ញុំអត់មានកាន់នាទីតំណែងអីទេ។ បើនៅឃុំ គឺជានីរសារ ហើយនៅស្រុកក៏នៅជាមួយគណៈស្រុក ជានីរសារដែរ។ បាទគឺខ្ញុំអត់មាននាទីអីធំដុំអីទេ។ សូមឆ្លើយប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់បានធ្វើនីរសារឲ្យបុរសម្នាក់ឈ្មោះ តាជឹម ទេ?

**ឆ៖** បាទ អត់ទេ។ ធ្វើនីរសារឲ្យ យាយខុម – កូនតាម៉ុក។

**ស៖** ដើម្បីឲ្យប្រាកដ ប្រហែលជាខ្ញុំអានឈ្មោះខុស។ តើលោកនិយាយថា លោកមិនមែនជានីរសាររបស់ ពេជ្រ ជឹម ទេ ឬក៏នីរសាររបស់ តាជឹម ទេ តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយ! អំមិញអត់ទាន់ឆ្លើយទេ។ ឆ្លើយអំមិញ អត់មានក្បាលមីក្រូហ្វូនអត់ប្រតិបត្តិការស្មើនឹងអត់ឆ្លើយ។ ឆ្លើយ! សំណួរអំមិញគឺថាបញ្ជាក់ឡើងវិញ ថាតើលោកហ្នឹងជានីរសាររបស់ ពេជ្រ ជឹម ដែរឬទេ?

[០៩:៣៣:០៥]

**លោក សាន់ ឡូន៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំទាន់ឆ្លើយ! ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការទេណ៎ា អ៊ីចឹងវាអត់ឮ អត់ឮស្មើនឹងអត់ឆ្លើយ

ព្រោះសំឡេងរបស់លោក កាលណាឆ្លើយទៅ បានចែកចាយសំឡេងទៅគ្រប់ភាគីទាំងអស់ ជាពិសេសទៅដល់អង្គភាពបកប្រែភាសាផ្ទាល់មាត់នោះ ដើម្បីបកប្រែភាសាសម្តីរបស់លោកទៅជាភាសាអង់គ្លេស និងភាសាបារាំងទៀត ដើម្បីចែកចាយភាគី និងសាធារណជនជ្រាបទាំងអស់គ្នា ទាំងជាតិ ទាំងអន្តរ-ជាតិ។ លោកយល់ទេ? អ៊ីចឹងចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមសិនសឹមឆ្លើយ!

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ខ្ញុំអត់មានធ្វើនីរសារ តាជឹម បាទអត់ទេ អត់បានធ្វើទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកស្គាល់ថា តាជឹម ជាអ្នកណាទេ? បានន័យថា មានតំណែងជាអ្វីទេ?

**ឆ៖** មានតំណែងជាគណៈស្រុកដែរ តាជឹម។

[០៩:៣៤:២០]

**ស៖** លោកនិយាយថា លោកមិនមានកាន់តំណែងអ្វីទេ។ តើនៅពេលណាមួយ រូបលោកផ្ទាល់បានធ្វើជាមេភូមិរបស់ភូមិប្រគាបដែរឬទេ?

**ឆ៖** កាលឆ្នាំ១៩៧១, ៧២ អាហ្នឹងបានធ្វើ បានធ្វើប្រធានភូមិប្រគាប។

**ស៖** តើលោកធ្វើជានីរសារស្រុក ចាប់ពីពេលណាទៅដល់ពេលណា? តើលោកធ្វើជានីរសារស្រុកឲ្យ យាយខុម ហ្នឹងចាប់ពីពេលណាទៅដល់ពេលណាដែរ? លោកនៅនឹកឃើញទេ?

**ឆ៖** ខ្ញុំធ្វើនីរសារឲ្យ ខុម ហ្នឹង នៅឆ្នាំ១៩៧៥ ឬក៏៧៤, ៧៥ ខ្ញុំភ្លេចអស់ហើយ ភ្លេច ថាឆ្លើយប៉ុណ្ណឹង។

**ស៖** តើលោកធ្វើអ្វីនៅក្នុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧?

**ឆ៖** ខ្ញុំមករៀនកសិកម្មនៅមេច្បារ បាត់ដំបងបានមួយឆ្នាំ ក្នុងឆ្នាំ១៩៧៦ បានមួយឆ្នាំ។

**ស៖** ដូច្នេះនៅឆ្នាំ១៩៧៦ គឺថាលោកស្ថិតនៅ រៀននៅបាត់ដំបងពេញមួយឆ្នាំតែម្តង ឬក៏ឆ្នាំ១៩៧៧ ឬក៏ឆ្នាំ១៩៧៨ ទេ?

**ឆ៖** ម៉េចហើយ! ថា១៩៧៦ហ្នឹង មិនដឹងថា ច្បាស់ឬមួយក៏មិនទាន់ច្បាស់ បើខ្ញុំភ្លេចហើយ ឬក៏៧៥ តែម្តង ឬមួយយ៉ាងម៉េច អាហ្នឹងខ្ញុំភ្លេចដែរ។

**ស៖** តើលោកស្ថិតនៅបាត់ដំបងឬ នៅពេលដែលកងទ័ពវៀតណាមឈ្លានពានប្រទេសកម្ពុជា?

**ឆ៖** បាទ សុំម្តងទៀត។

[០៩:៣៨:១៥]

**ស៖** តើលោកនៅរៀននៅឯសាលាកសិកម្មដដែលឬ នៅពេលដែលកងទ័ពវៀតណាមវាយលុកចូលក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៨?

**ឆ៖** បាទ ក្នុងបញ្ហានេះ ខ្ញុំដឹងថា វៀតណាមចូលលុកលុយមកដល់ក្នុងប្រទេសកម្ពុជា ការរៀនសូត្រមេច្បារ នៅមេច្បារ ហ្នឹងគឺសិស្សទាំងអស់រត់ចេញ ដើរចេញពីសាលា ដើរចៀសចេញពីសាលាទៅក្រៅទៅ អត់មានបានរៀនសូត្រតទៅទៀតទេ។

**ស៖** លោកបានឆ្លើយថា លោកធ្វើជានីរសារឲ្យគណៈកម្មាធិការស្រុកយ៉ាងហោចណាស់ក៏ក្រោយឆ្នាំ១៩៧៥ដែរ។ តើលោកមានការងារណាផ្សេងទៀតដែលត្រូវបំពេញដែលត្រូវធ្វើដែរទេ នៅពេលដែលលោកនៅក្នុងស្រុកត្រាំកក់ហ្នឹង?

**ឆ៖** បាទ អត់ទេ។

**ស៖** តើលោកមានចូលរួមពាក់ព័ន្ធក្នុងការដឹកជញ្ជូនប្រជាជនពីកន្លែងមួយ ទៅកាន់កន្លែងមួយទៀតទេ?

**ឆ៖** បាទ រឿងនេះគឺខ្ញុំបានដឹកជញ្ជូនមែន ដឹកជញ្ជូនប្រជាជននៅក្នុងឃុំនីមួយៗ។

**ស៖** តើលោកដឹកជញ្ជូនប្រជាជនប្រភេទណាដែរ ប្រជាជនទាំងអស់ខ្មែរ ឬជាអ្វីដែរ?

**ឆ៖** បាទ ក្នុងរឿងនេះ ខ្ញុំខាងស្រុកបញ្ជា ឬថាឲ្យខ្ញុំទៅដឹកប្រជាជនទាំងអស់នោះ។ ប៉ុន្តែមិនដឹងថាប្រជាជន ជនយ៉ាងម៉េច ខ្ញុំអត់បានយល់ដែរ។ មិនបានដឹង។

**ស៖** តើលោកស្តាប់ឮពួកគេនិយាយដែរ? លោកស្គាល់ឈ្មោះពួកគេទេ?

**ឆ៖** បាទ អត់ស្គាល់។

[០៩:៤១:៣៦]

**ស៖** តើលោកនៅនឹកឃើញទេថា លោកចូលរួមដឹកជញ្ជូនប្រជាជនទាំងនេះពីទីតាំងកទៅទីតាំងខអ៊ីចឹង អស់រយៈពេលប៉ុន្មាន?

**ឆ៖** បាទ សុំម្តងទៀត។

**ស៖** តើលោកដឹងទេ លោករវល់ចូលរួមដឹកជញ្ជូនប្រជាជនពីទីកន្លែងមួយទៅកន្លែងមួយទៀតហ្នឹង អស់រយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ការដឹកជញ្ជូននេះ ប្រជាជននេះគឺនៅក្នុងឃុំនីមួយៗក្នុងរវាង៤ថ្ងៃ ដឹក៤ថ្ងៃ។

**ស៖** តើការរវល់ដឹកញ្ជូនហ្នឹងវានៅក្នុងឆ្នាំ១៩៧៥ ឬក៏៧៦ តាំងពីដើមដំបូងនៃរបបនោះ ឬក៏ជិតដំណាច់នៅរបបនោះហើយ?

**ឆ៖** បាទ ការដឹកជញ្ជូននេះ គឺមិនមែនជិតដំណាច់ឆ្នាំនោះទេ គឺដើមឆ្នាំ៧៥។

**ស៖** ខ្ញុំនឹងត្រឡប់ចូលមកប្រធានបទនេះ នៅពេលក្រោយបន្តិចទៀតនេះ។ តើធ្លាប់រស់នៅក្នុងក្រុងតាកែវដែរទេ អាចនៅក្នុងឆ្នាំ១៩៧៣ ឬក៏ថានៅក្នុងរបប លន់ នល់ ក៏ថាបាន តើលោកធ្លាប់រស់នៅក្នុងទីរួមខេត្តតាកែវទេ?

**ឆ៖** បាទ អត់ដែលបានធ្លាប់រស់នៅទេ។ ខ្ញុំនៅក្រៅ នៅជនបទ។

[០៩:៤៤:១៧]

**ស៖** តើលោកនៅនឹកឃើញអ្វីខ្លះ អំពីការប្រព្រឹត្តទៅលើជនជាតិវៀតណាមចន្លោះពីឆ្នាំ១៩៧០ ដល់៧៥ គឺក្នុងអំឡុងពេលដែល លន់ នល់ កាន់អំណាច?

**ឆ៖** បាទ អត់ទេ ខ្ញុំអត់មានចងចាំអីបាន។ បាទ អត់។

**ស៖** ឥឡូវនេះខ្ញុំព្យាយាមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច។ តើលោកស្គាល់ម្នាក់ឈ្មោះ អ៊ុង ហួន -- អ៊ុល ហឿន? តើលោកស្គាល់ អ៊ុល ហឿន ទេ?

**ឆ៖** អ៊ុល ហឿន បាទ អត់ស្គាល់។

**ស៖** អ៊ុល ហឿន គាត់ស្គាល់លោក។ ប្រហែលជាខ្ញុំអានមិនច្បាស់ ក៏មិនដឹង។ អ៊ុល ហឿន គឺជាមនុស្សម្នាក់ដែលធ្វើការឲ្យ ពេជ្រ ជឹម នៅក្នុងស្រុកត្រាំកក់ដែរ ឈ្មោះ អ៊ុល ហឿន គឺជាមួយ ពេជ្រ ជឹម នៅត្រាំកក់។

**ឆ៖** បាទ ខ្ញុំអត់ស្គាល់។

**ស៖** ខ្ញុំសូមអានសម្រង់នូវសក្ខីកម្មរបស់គាត់ ដែលបានឆ្លើយជូនតុលាការអំពីរយៈពេលឆ្នាំ១៩៧៥។ លោកប្រធាននេះគឺឯកសារ E1/298.1 គាត់បានឆ្លើយក្នុងតុលាការនៅថ្ងៃទី០៧ ឧសភា ២០១៥ នៅម៉ោង១៥:១៣នាទីរសៀល។ គាត់បានផ្តល់សក្ខីកម្មដូចតទៅ លោកសាក្សីខ្ញុំសូមដកស្រង់សម្តីគាត់៖ “គឺពីឆ្នាំ៧៥ដល់៧៦ មុនពេលនោះគឺទាហាន លន់ នល់ ក៏សម្លាប់យួនដែរ។ យួនរាប់រយពាន់នាក់ត្រូវបានគេៗប្រមូលដាក់រាប់រយពាន់ម៉ឺននាក់នៅសាលានៅតាកែវ ហើយទាហានទាំងអស់ហ្នឹងឡោមព័ទ្ធសាលាហ្នឹង ហើយបាញ់សម្លាប់យួនទាំងអស់ហ្នឹងចោល។ ដូច្នេះរបប លន់ នល់ នេះសម្លាប់យួនច្រើនជាងរបប ប៉ុល ពត ទៅទៀត។” ដំបូងខ្ញុំសូមសួរលោក ថាតើលោកធ្លាប់ឮថាប្រជាជន

វៀតណាមត្រូវគេប្រមូលដាក់នៅក្នុងសាលាមួយនៅក្នុងសាលាទីរួមខេត្តតាកែវ គេហៅសាលាដៃប្រាំ?

[០៩:៤៧:៤២]

**ធ៖** បាទ អត់ទេ អត់ដែលបានឮ។

**ស៖** តើលោកធ្លាប់ឮការសម្លាប់ទ្រង់ទ្រាយធំទៅលើជនជាតិវៀតណាមមុនឆ្នាំ១៩៧៥ នៅទីរួមខេត្ត -- នៅក្នុងទឹកដីខេត្តតាកែវនោះដែរទេ?

**ធ៖** បាទ អត់ទេ អត់បានដឹង អត់ដែលបានឃើញ។

**ស៖** ខ្ញុំសូមអានសម្រង់មួយចេញពីសៀវភៅរបស់អ្នកជំនាញដែលឆ្លើយជូនតុលាការនេះ គឺឯកសារ E3/20 ERN អង់គ្លេសគឺទំព័រ១២៥ ERN គឺ00237830, 0063987 *(ស៊ីក)*, ខ្មែរ 00232166។ អ្នកជំនាញនេះ គាត់និយាយអំពីការសម្លាប់ជនជាតិវៀតណាមទ្រង់ទ្រាយធំនៅគ្រប់ទីន្លែងទាំងអស់ទូទាំងផ្ទៃប្រទេស។ ហើយគាត់ក៏និយាយអំពីការសម្លាប់ទ្រង់ទ្រាយធំនៅក្នុងខេត្តតាកែវផងដែរ។ សូមដកស្រង់៖ "សារព័ត៌មានអន្តរជាតិ គឺថាបានឃើញ និងរាយការណ៍អំពីការសម្លាប់នេះរួមទាំងការសម្លាប់ទ្រង់ទ្រាយធំនៅក្នុងទីរួមខេត្តតាកែវភាគខាងត្បូងនៃទីក្រុងភ្នំពេញ ហើយដោយសារមានបាតុកម្មប្រឆាំងទៅនឹង លន់ នល់។" ខ្ញុំដកស្រង់សម្រង់ចេញពីសៀវភៅមួយនេះ លោកសាក្សី ដោយសារនៅពេលនោះ គឺថាសារព័ត៌មានអន្តរជាតិក៏បានដឹងអំពីបញ្ហានេះ។ សូមលោកគិតបន្តិចមើល អំពីការសម្លាប់ទ្រង់ទ្រាយធំនេះដែលបានកើតឡើងនៅក្នុងក្រុងតាកែវមុនឆ្នាំ១៩៧៥ លោកគិតបន្តិចមើលនឹកឃើញទេ?

**ធ៖** បាទ អត់ទេ អត់នឹកឃើញ។ អត់បានដឹង។

[០៩:៥០:១៦]

**ស៖** មិនថ្វីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមនិយាយអំពីព្រឹត្តិការណ៍មួយទៀតមុនឆ្នាំ១៩៧៥ ជាពិសេសឆ្នាំ១៩៧៣ តើលោកធ្លាប់ដែលឮការប្រឈមមុខដាក់គ្នា ការប៉ះទង្គិចគ្នារវាងកងទ័ពភូមិភាគនិរតីដែលដឹកនាំដោយបងថ្លៃរបស់លោក តាម៉ុក និងកងទ័ពវៀតកុង ដែលឮទេដែលឮការប៉ះទង្គិចគ្នានេះទេ?

**ធ៖** បាទ អត់ទេ បាទអត់។ មិនបានដឹង។

**ស៖** ម្សិលមិញនេះ យើងមានសាក្សីម្នាក់ដែលបានឆ្លើយចំពោះមុខអង្គជំនុំជម្រះអំពីការប៉ះទង្គិចគ្នារវាងវៀតកុង ហើយនិងកងទ័ពភូមិភាគនិរតី ដែលប៉ះទង្គិចគ្នាជាង១៤ថ្ងៃ។ ហើយគាត់ថា នៅចុងបញ្ចប់នៃការប៉ះទង្គិចគ្នានេះ ក៏មានការព្រមព្រៀងគ្នាថា កងទ័ពវៀតកុងទាំងអស់ ឬថាកងទ័ព

កុម្មុយនីស្តទាំងអស់ពីប្រទេសវៀតណាម ត្រូវតែចាកចេញពីទឹកដីខេត្តតាកែវ គឺភូមិភាគនិរតី ហើយត្រឡប់ទៅវៀតណាមវិញ។ តើលោកធ្លាប់ឮពីបញ្ហានេះទេ?

**ឆ៖** អារឿងនេះ ខ្ញុំធ្លាប់បានឮគេនិយាយតៗគ្នា ខ្ញុំគ្រាន់តែឮតាមគេទេ។ បាទ ខ្ញុំឮ ធ្លាប់គេនិយាយអ៊ីចឹងដែរ កងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា។ បាទប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែតើលោកធ្លាប់បានឮ ឬក៏ថាអាចធ្លាប់ឮពីបងថ្លៃរបស់លោក តាម៉ុក ថា កងទ័ពវៀតកុងទាំងអស់នោះ បានចាកចេញពីកម្ពុជា ហើយត្រឡប់ទៅវៀតណាមវិញ លោកធ្លាប់ឮទេ?

**ឆ៖** បាទ ធ្លាប់ឮគេនិយាយ។

[០៩:៥២:៥១]

**ស៖** តើលោកអាចបញ្ជាក់ ឬក៏ប៉ាន់ប្រមាណថាមានប្រជាជនវៀតណាមប៉ុន្មានរស់នៅក្នុងស្រុកត្រាំកក់ក្នុងឆ្នាំ១៩៧៥? គឺយើងគិតមកត្រឹមតែថ្ងៃ១៧ មេសា ៧៥ បានហើយ ថាតើមានប្រជាជនវៀត-ណាមប៉ុន្មាននាក់រស់នៅក្នុងស្រុកត្រាំកក់?

**ឆ៖** បាទ ខ្ញុំភ្លាប់អត់បានដែរ ខ្ញុំអត់បានដឹង។ នេះនិយាយការពិត។

**ស៖** ខ្ញុំយល់ហើយថា លោកមិនតួនាទីអីបញ្ជាក់អំពីតួលេខឲ្យបានច្បាស់លាស់ ក៏ប៉ុន្តែតើមានជនជាតិវៀតណាមច្រើនទេ ចាកចេញនៅក្នុងឆ្នាំ១៩៧៥? តើគ្រាន់តែចាកចេញតិចតួច ឬក៏ច្រើនមែនទែន? តើលោកអាចជម្រាបជូនតុលាការបានទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំបានឃើញថាជនជាតិវៀតណាម គេប្រមូលឲ្យបញ្ជូនទៅប្រទេសវៀត-ណាមវិញ គឺថា គឺច្រើនដែរ នេះឃើញ ខ្ញុំឃើញ។

**ស៖** តើពេលហ្នឹង ឲ្យចំមែនទែនទៅ នៅពេលណាដែរ?

**ឆ៖** បាទ សូមម្តងទៀត។

**ស៖** លោកទើបតែបានឆ្លើយថា លោកបានឃើញប្រជាជនវៀតណាមយ៉ាងច្រើនត្រូវបានបញ្ជូនឲ្យទៅវៀតណាមវិញ។ សំណួររបស់ខ្ញុំសួរថា តើលោកចាំទេ នៅពេលណាឲ្យជាក់លាក់ទៅដែលលោកបានឃើញគេបញ្ជូនវៀតណាមទៅវិញហ្នឹង នៅក្នុងឆ្នាំណា?

**ឆ៖** ភ្លេចហើយ ភ្លេចឆ្នាំហើយ មិនដឹងឆ្នាំណាទេ។ ខ្ញុំភ្លេច។

[០៩:៥៥:៤៣]

**ស៖** ឥឡូវខ្ញុំសួរឲ្យជាក់លាក់តែម្តង តើការបញ្ជូនជនជាតិវៀតណាមទៅវិញហ្នឹងមុនថ្ងៃ១៧

មេសា ១៩៧៥ ឬក៏ក្រោយឆ្នាំ១៩៧៥ គឺពេលដែលលោកឃើញគេបញ្ជូនប្រជាជនវៀតណាមយ៉ាងច្រើន បញ្ជូនទៅប្រទេសវៀតណាមវិញនោះ?

**ឆ៖** បាទ ការបញ្ជូនវៀតណាម ប្រជាជនវៀតណាមទៅវៀតណាមវិញនេះ គឺក្នុង ក្រោយឆ្នាំ ១៩៧៥ ហ្នឹងតាមខ្ញុំបានដឹង។ បាទ សូមឆ្លើយប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំអ្វីខ្លះទៀត? តើខ្លួនលោកផ្ទាល់ចូលរួមពាក់ព័ន្ធក្នុងការដឹកជញ្ជូនជនជាតិវៀតណាមទាំងនេះ បញ្ជូនឲ្យទៅប្រទេសវៀតណាមនោះវិញដែរទេ?

**ឆ៖** បាទ អត់។ អត់ឃើញ ខ្ញុំអត់បានឃើញទេ។ ប៉ុន្តែខ្ញុំ គ្រាន់តែបានដឹង ដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹងថាខ្ញុំបានគ្រាន់តែឃើញ អំបានដឹកជញ្ជូនប្រជាជនវៀតណាមទាំងនោះមែន។

**ស៖** ធ្វើម៉េចបានជាលោកដឹងថា ប្រជាជនទាំងអស់នេះ ត្រូវបានគេបញ្ជូនទៅប្រទេសវៀត-ណាមវិញ គឺយកទៅទម្លាក់នៅវៀតណាមខាងត្បូង ម៉េចបានលោកដឹង?

**ឆ៖** បាទ ខ្ញុំគ្រាន់តែឮតាមគេ តាមការនិយាយរបស់ខាងស្រុក ខ្ញុំបានឮតាមនិយាយអ៊ីចឹង។

**ស៖** ខ្ញុំសុំសួរពីឈ្មោះ អ៊ុល ហឿន ឡើងវិញ។ តើលោកស្គាល់ -- ចុះបើខ្ញុំនិយាយពីឈ្មោះ ឯក ហឿន វិញម្តង តើលោកស្គាល់ទេ?

**ឆ៖** ឯក ហឿន អត់ទេ ខ្ញុំអត់ស្គាល់។

[០៩:៥៨:៤៨]

**ស៖** ដូចដែលខ្ញុំបានប្រាប់ហើយគឺថា គាត់ថា គាត់ស្គាល់លោក។ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់មួយ គាត់ថា លោកនេះចូលរួមពាក់ព័ន្ធក្នុងការដឹកជញ្ជូនជនជាតិវៀតណាមប្រហែល៩.០០០គ្រួសារ។ តើត្រឹមត្រូវដែរទេ ការដឹកជញ្ជូនដែលលោកបានឆ្លើយពីមុននេះ? តើការដឹកជញ្ជូននេះ ជាការដឹកជញ្ជូនជនជាតិវៀតណាម ប្រហែលជា៩០០០នាក់ឲ្យទៅវៀតណាមវិញ ហ្នឹងឬក៏មិនមែនទេ?

**ឆ៖** បាទ មែន។ ឯការដឹកនេះ តាមការបញ្ជារបស់ខាងស្រុក ឲ្យខ្ញុំ – បញ្ជាឲ្យខ្ញុំទៅដឹក។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែសំណួរខ្ញុំសួរពាក់ព័ន្ធចំណុចខាងដើមនេះ ថាតើប្រជាជនវៀតណាម ៩.០០០នាក់នេះ បានទៅដល់វៀតណាមប្រកបដោយសុវត្ថិភាពទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹង។ ដឹករួចហើយ ដាក់គាត់ចុះ ខ្ញុំក៏ត្រឡប់មកវិញ។

**ស៖** តើលោកប្រាកដឬទេ ថាការដឹកជញ្ជូនកាលនោះ ការដឹកវៀតណាមហ្នឹង គឺកើតឡើងនៅ

ដើមនៃរបបនោះ។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅដល់ប្រធានបទមួយផ្សេងទៀត លោកសាក្សី។ តើលោកដឹងអ្វីខ្លះអំពីការប្រព្រឹត្តទៅលើអតីតទាហាន ឬក៏មន្ត្រីរបបសាធារណរដ្ឋខ្មែរនៅខេត្តតាកែវ ឬក៏នៅក្នុងភូមិភាគនិរតីទាំងមូល? តើលោកដឹងអ្វីខ្លះអំពីអ្នកទាំងនោះ? ពួកនោះមានបញ្ហាអ្វីទេ ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក? តើលោកបានដឹងទេនៅពេលនោះ?

[១០:០១:៤២]

**ឆ៖** បាទ ខ្ញុំអត់បានដឹង អត់បានយល់។ អត់បានដឹងមែន។

**ស៖** តើលោកធ្លាប់ចូលរួមកិច្ចប្រជុំណាមួយ មុនឆ្នាំ១៩៧៥ ឬក្រោយឆ្នាំ១៩៧៥ នៅខេត្តតាកែវ ឬក៏ក្នុងរួមខេត្តតាកែវ ឬក៏កន្លែងណាផ្សេង ដែលនៅក្នុងកិច្ចប្រជុំនោះ តាម៉ុក ឬក៏ តាសោម បាននិយាយហើយប្រាប់អ្នកដែលចូលរួមប្រជុំនោះ ថាតើត្រូវធ្វើដូចម្ដេចចំពោះទាហាន លន់ នល់ បន្ទាប់ពីស័ក្តិ១រហូតទៅដល់ស័ក្តិ៣នោះ?

**ឆ៖** រឿងនេះ ខ្ញុំក្តាប់អត់បានដែរ អត់បានយល់។

**ស៖** តើលោកធ្លាប់ឮថាមានការណែនាំ ត្រូវបានចេញមកពីតំបន់ ឬក៏ភូមិភាគទៅស្រុកផ្សេងៗនៅក្នុងភូមិភាគនិរតីដែរឬទេ ដែលថាទាហាន លន់ នល់ ពីថ្នាក់ក្រោមរហូតទៅដល់ស័ក្តិ៥នោះ គឺមិនត្រូវឲ្យមានការប៉ះពាល់ទេ? តើលោកធ្លាប់ឮអ៊ីចឹងទេ?

**ឆ៖** បាទ រឿងនេះ ខ្ញុំជំនាន់ទាហាន លន់ នល់ អត់ៗក្តាប់បាន អត់យល់។ អត់យល់ទេ ក្តាប់អត់បាន។

**ស៖** តើដោយសារតែវាមិនឋិតនៅក្នុងមុខងារភារកិច្ចរបស់លោក ដែលគេចាត់ចែងឲ្យលោកធ្វើបានជាលោកមិនដឹង? តើមកពីមូលហេតុហ្នឹង ឬអ្វី?

**ឆ៖** បាទ មកពីបញ្ហាហ្នឹង។

[១០:០៤:២៤]

**ស៖** នៅពេលដែលលោកយកកិច្ចការអ្វីៗពីថ្នាក់ស្រុកទៅថ្នាក់ឃុំ ឬក៏ទៅភូមិនានានោះ តើលោកធ្លាប់មានឱកាសបានអានសំបុត្រ ឬក៏សំបុត្រ ឬក៏លិខិតអីពីស្រុកទៅឃុំ ទៅភូមិដែរឬទេ?

**ឆ៖** បាទ អត់ អត់ដែលបានឃើញ។

**សៈ** តើលោកធ្លាប់បានជជែកអ្វីជាមួយ យាយខុម ឬក៏ជាមួយ ពេជ្រ ជឹម នៅក្នុងគណៈស្រុកដែរឬទេ? ថាតើត្រូវធ្វើដូចម្ដេច ចំពោះមនុស្សដែលគេចាត់ទុកថាជាសមាសភាពមិនល្អ ឬក៏អ្នកដែលគេចាត់ទុកថាប្រឆាំង ឬក៏អ្នកដែលមានគំនិតថានឹងផ្ដួលបដិវត្តន៍ដែរឬទេ?

**ឆៈ** បាទ អត់ទេ អត់ដែលបានឮ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនទាន់បញ្ចប់ទាំងស្រុងទេ ខ្ញុំសូមរក្សាសិទ្ធិ ៥ឬ១០នាទីដែលខ្ញុំនៅសល់ដើម្បីខ្ញុំសួរដេញដោលសាក្សីនេះនៅពេលណាមួយចុងក្រោយ។ ខ្ញុំបញ្ចប់នៅពេលនេះសិន ប៉ុន្តែខ្ញុំមិនទាន់អស់ម៉ោងទេ ខ្ញុំសូមអនុញ្ញាតទុក ៥ឬ១០នាទីនេះចុងក្រោយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១០:០៦:៤០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងលោកសាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**សៈ** ខ្ញុំចង់ចាប់ផ្ដើមសួរ ដោយសូមឲ្យលោកបំភ្លឺអំពីអាយុរបស់លោក។ លោកបានឆ្លើយថ្ងៃនេះថា លោកអាយុ៧៣ឆ្នាំ នៅក្នុងបទសម្ភាសន៍ការិយាល័យសហចៅក្រមស៊ើបអង្កេត សំណួរចម្លើយ៥៦ លោកថាអាយុ៧១ឆ្នាំនៅពេលនោះ ដែលថាក្នុងខែកញ្ញា ឆ្នាំមួយពាន់ប្រាំបួនរយ -- ឆ្នាំ២០១៤ មានន័យថាលោកបានកើតឡើងនៅឆ្នាំ១៩៤៣ ដើម្បីឲ្យលោកមានអាយុ៧១ ឬ៧២ នៅពេលដែលគេសម្ភាសលោក។ តើតាមអ្វីដែលលោកចាំហ្នឹង គឺថា លោកជឿថាលោកកើតនៅក្នុងឆ្នាំ១៩៤៣ហ្នឹងដែរឬទេ?

**លោក សាន់ ឡុន៖**

**ឆៈ** បាទ ហ្នឹងហើយ ត្រឹមត្រូវហើយ។

**សៈ** លោកក៏បានចង្អុលបង្ហាញនៅក្នុងសំណួរចម្លើយ៧៧ ថាលោកបានកើតនៅ លោកកើតនៅឆ្នាំវក តើប្រាកដថាលោកកើតឆ្នាំវកទេ?

**ឆ៖** បាទ ខ្ញុំឆ្នាំ កើតឆ្នាំវក។

[១០:០៨:៣១]

**ស៖** មូលហេតុដែលខ្ញុំសួរសំណួរនេះ គឺថាជាពិសេសនៅផ្នែកខាងដើមនៃបទសម្ភាសន៍របស់លោកដែលជាបទសម្ភាសន៍មួយដ៏វែង លោកបានធ្វើការអះអាងមួយចំនួនថាលោកមិនបានដឹង ហើយមិនអាចចងចាំអ្វីៗដោយសារលោកជានៅក្មេង ជាក្មេងប្រុសពេកនៅរបបខ្មែរក្រហម។ ខ្ញុំសូមអានជូនលោកនៅក្នុងសំណួរចម្លើយ៦០ "សំណួរ៖ តើលោកយល់ពាក្យថាសហករណ៍ដែរឬទេ? ចម្លើយ៖ ខ្ញុំមិនដឹងទេ ពីព្រោះនៅខ្ញុំនៅក្មេងតូចនៅឡើយនៅពេលនោះ។ ចម្លើយ៩៥ គេសួរទៅទៀតដែលថា៖ បានច្បាំងនៅក្នុងសង្គ្រាមស៊ីវិលដែលនាំឱ្យខ្មែរក្រហមកាន់អំណាចដែរឬទេ? លោកឆ្លើយថា៖ អត់យល់ ខ្ញុំអត់ដឹង ខ្ញុំនៅក្មេង ខ្ញុំមិនដឹងអ្វីទេ។" ខ្ញុំចង់ឱ្យលោកបំភ្លឺជូនតុលាការ លោកសាក្សី បើលោកកើតនៅឆ្នាំ១៩៤៣ ហើយលោកអាយុ៧០ឆ្នាំហើយនៅថ្ងៃនេះ – ៧៣ឆ្នាំនៅពេលនេះ គឺថាអាចលោកអាចនៅអាយុ៣១ ឬក៏៣២ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមនោះ។ ហើយអាយុ៣១, ៣២ មិនមែនជាកុមារទេ មិនមែនក្មេងទេ គឺថានៅអាយុ ក្នុងវ័យ៣០នៅក្នុងដែលខ្មែរក្រហមកាន់អំណាច។ តើអ៊ីចឹងត្រូវទេ លោកសាក្សី?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយចំណុចមួយទៀត ដែលខ្ញុំព្យាយាមដើម្បីយល់ នៅក្នុងចំណុចពាក់កណ្ដាលនៃការសួរសំណួរ គឺថា៥០ទំព័រដំបូងនៃបទសម្ភាសន៍នោះ ហើយលោកបន្តនិយាយហើយនិយាយទៀតដដែលៗ លោកនិយាយថា មិនដឹងអ្វីទាល់តែសោះ មិនដឹងអ្វី ទោះបីជាថា លោកជាបងប្អូន ជាប្អូនថ្លៃតាម៉ុក ជាបងប្អូនជីដូនមួយ ហើយលោកអះអាងនៅក្នុងចម្លើយ១១៧ ថាលោកមិនដែលបានជួប តាម៉ុក ហើយនៅក្នុងចម្លើយ៤១៩ គេសួរថា៖ "តើលោកធ្វើអ្វីនៅក្នុងរបបខ្មែរក្រហមរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩? លោកបានឆ្លើយថា សូមដកស្រង់៖ ខ្ញុំអត់ទេ ខ្ញុំអត់មានធ្វើអ្វីទេ។" ចប់សេចក្ដីដកស្រង់។ សូមលោកជួយឱ្យយើងយល់បានទេ ប៉ុន្តែពេលក្រោយមក លោកទទួលស្គាល់ខ្លួនឯងថា លោកបានជួបជាមួយ តាម៉ុក ហើយបានកាន់តំណែងខ្លះ។ ចុះហេតុអ្វីបានជាកំណត់ហេតុ៣៥ទំព័រពីខាងដើម នៅពេលសម្ភាសជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត លោកថា មិនដឹងអីទេ លោកឆ្លើយបដិសេធរហូត ប៉ុន្តែដល់ក្រោយមក លោកទទួលស្គាល់។ សូមលោកពន្យល់ពីមូលហេតុដែលលោកឆ្លើយបែបនោះ ជូនតុលាការផង បានទេ?

[១០:១២:១៣]

**ឆ៖** ពេលមុនខ្ញុំនិយាយទៅដូចថា វាភ្លេច ភ្លេចអស់។ និយាយរ៉ាយរ៉ាប់ រៀបរាប់ទៅក៏ពិបាកអត់ចេះ ក៏ភ្លេចអស់។ ហើយក្រោយមក ខ្ញុំក៏បានយល់ បានដឹង ស្គាល់ តាម៉ុក ហ្នឹង។ សូមបញ្ជាក់ប៉ុណ្ណឹង។

**សៈ** តើអ្វីៗដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម លោកមានការលំបាកក្នុងការនិយាយ ឬក៏លោកមានការភ័យខ្លាចក្នុងការនិយាយដែរឬទេ លោកសាក្សី?

**ឆ៖** បាទ ក្នុងរបបខ្មែរក្រហមនោះ គឺមានការពិបាកនិយាយ ភ័យដែរ ចេះតែខ្លាចៗ ប៉ះពាល់នយោបាយអីយ៉ាងម៉េច។ អាហ្នឹងគឺមានការភ័យខ្លាច ខ្លាចគេចោទប្រកាន់។

**សៈ** លោកមានការភ័យខ្លាច ថាមានការចោទប្រកាន់នោះ ខ្លាចអ្នកណាចោទប្រកាន់?

**ឆ៖** បាទ ខ្លាចពាក្យសម្ដី ខ្លាចឮតៗគ្នាទៅ វាឮដល់ថ្នាក់ដឹកនាំភូមិ ឬក៏ថ្នាក់ដឹកនាំឃុំអីអ៊ីចឹងទៅ។ បាទ ខ្លាចអ៊ីចឹង ឬក៏ក្រុម យកការនិយាយស្ដីហ្នឹងមិនសមរម្យ មិន ធ្វើឲ្យប៉ះពាល់យ៉ាងម៉េច គឺនាំពាក្យហ្នឹងរាយការណ៍ទៅ។ ម្ល៉ោះហើយចេះតែភ័យ មានការភ័យខ្លាចអ៊ីចឹង។

**សៈ** ដើម្បីឲ្យប្រាកដនៅក្នុងកំណត់ត្រាតុលាការ តើលោកនិយាយអំពីការខ្លាចនិយាយនៅក្នុងរបបខ្មែរក្រហម ឬក៏លោកនិយាយថា ខ្លាចក្នុងពេលដែលនិយាយនៅក្នុងបទសម្ភាសន៍នៅជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត?

**ឆ៖** បាទ ការខ្លាចនេះ គឺនៅក្នុងរបបខ្មែរក្រហម។

**សៈ** បាទ អ៊ីចឹងខ្ញុំនឹងបន្តសូមឲ្យលោកបំភ្លឺបន្ថែមទៀត អំពីមុខតំណែងរបស់លោកក្នុងរបបនោះ។ ថ្ងៃនេះលោកនិយាយថា--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារង។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៦នាទី ដល់ម៉ោង ១០:៣៤ នាទី)*

[១០:៣៤:៣០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរលោកឲ្យបញ្ជាក់អំពីតួនាទីដែលលោកមាននៅពេលនោះ ហើយនិងការងារដែលលោកធ្វើ ហើយនិងពេលវេលាដែលលោកកាន់កាប់នូវតំណែងទាំងនោះ។ លោកបានឆ្លើយនៅថ្ងៃនេះថា លោកបានធ្វើជានីរសារឲ្យ យាយខុម ដែលជាកូនស្រីរបស់ តាម៉ុក។ តើលោកនៅតែធ្វើជានីរសារស្រុកដដែលឬ នៅពេល យាយខុម ចាកចេញទៅ ហើយ តាជឹម ក៏ត្រូវបានដំឡើងឲ្យធ្វើជាចៅហ្វាយស្រុក ជាលេខាស្រុកនៅពេលនោះ?

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ខ្ញុំនៅតែធ្វើនីរសាររហូតៗមក។

[១០:៣៦:៤៤]

**ស៖** ខ្ញុំសូមអានសម្រង់មួយចំនួនឲ្យលោកស្តាប់ ចេញពីកំណត់ហេតុស្តាប់ចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេតគឺ E3/9487 ចម្លើយទី១ -- បាទចម្លើយ៦៧៤ដល់៦៧៣ សូមដកស្រង់៖ “ខ្ញុំបានជួប តាជឹម នៅឆ្នាំ១៩៧៣,៧៤ និង៧៥។ សំណួរ៖ តើលោកចាប់ផ្តើមធ្វើការជាមួយ ពេជ្រ ជឹម

នៅពេលណា? ឆ្លើយ៖ ខ្ញុំចាប់ផ្ដើមធ្វើការជាមួយ ពេជ្រ ជឹម នៅឆ្នាំ១៩៧៣។ ហើយនៅចម្លើយលេខ ៩២៥៖ សួរ៖ តើអ្នកណាឡើងជំនួស ខុម? ឆ្លើយ៖ តាជឹម ត្រូវបានដំឡើងឲ្យជំនួស ខុម។ សំណួរ៩២៩៖ សួរ៖ នៅពេលដែល តាជឹម ដំឡើងឲ្យធ្វើជាលេខាស្រុក តើលោកនៅតែធ្វើជានីរសារឲ្យ តាជឹម នៅស្រុកនោះដដែល? ឆ្លើយ៖ ខ្ញុំនៅតែធ្វើជានីរសារស្រុកនោះដដែល។" បញ្ចប់ការដកស្រង់។

ដូច្នេះខ្ញុំសូមសួរបញ្ជាក់អំពីកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត គឺលោកនិយាយច្រើនណាស់អំពី តាជឹម។ តើនៅថ្ងៃនេះ លោកបញ្ជាក់ថាដើមដំបូងឡើយ គឺលោកធ្វើនីរសារឲ្យ យាយខុម ហើយក្រោយមកនៅពេលដែល យាយខុម ចាកចេញទៅ គេត្រូវឲ្យ តាជឹម ឡើងជំនួស តើនៅក្នុងអំឡុងពេលនោះលោកធ្វើនីរសារឲ្យ តាជឹម ឬ?

**ឆ៖** បាទ កាលនោះដែល យាយខុម គាត់ចាកចេញទៅ ខ្ញុំនៅក្នុងមន្ទីរ យាយខុម ហើយនៅក្នុងមន្ទីរ យាយខុម ដដែល។ ហើយការក្រោយមក ក៏នៅក្នុងក្រោមការថ្នាក់ដឹកនាំរបស់ តាជឹម បន្តពី យាយខុម ។ នៅធ្វើ ធ្វើនីរសារ ប៉ុន្តែគ្រាន់តែកន្លែងខុសពីកន្លែង តាជឹម។

**ស៖** នៅពេលដែលលោកធ្វើជានីរសារស្រុក តើលោកទទួលបញ្ជាពីអ្នកណា? តើលោកទទួលបញ្ជាពីចៅហ្វាយស្រុក ពីយាយខុម, ពីតាជឹម ឬក៏មានអ្នកផ្សេងនៅក្នុងមន្ទីរស្រុកហ្នឹងបញ្ជា ជាអ្នកបញ្ជាមកលោក?

**ឆ៖** បាទ ក្នុងបញ្ហានេះគឺខ្ញុំឋានៈជានីរសារ ហើយការបញ្ជារបស់ថ្នាក់ស្រុកក៏មាន ឬក៏ថ្នាក់អ្នកនៅមន្ទីរផ្សេងទៀតក៏មាន ហ្នឹងការបញ្ជារបស់ខ្ញុំ សម្រាប់ឲ្យខ្ញុំធ្វើ។

[១០:៤០:៣៥]

**ស៖** ខ្ញុំនឹងចូល ខ្ញុំនឹងសួរច្រើនអំពីការងាររបស់លោកជានីរសារស្រុក។ តើលោកស្ថិតនៅស្រុកត្រាំកក់អស់រយៈពេលប៉ុន្មាន? ហើយនៅពេលណាដែលលោកទៅបាត់ដំបង?

**ឆ៖** កាលនោះ គឺនៅក្នុងស្រុកត្រាំកក់ ក្នុងឆ្នាំ១៩៧៥ ដែល តាម៉ុក ឬការបញ្ជារបស់ តាម៉ុក មកថ្នាក់ក្រោម ថ្នាក់ក្រោមហ្នឹង គឺបញ្ជាឲ្យខ្ញុំទៅរៀនកសិកម្មនៅមេច្បារ បាត់ដំបង។

**ស៖** ព្រឹកមិញនេះ លោកបាននិយាយថា លោកនឹកមិនឃើញឲ្យពិតប្រាកដថា លោកនៅបាត់ដំបងនោះនៅក្នុងឆ្នាំណាទេ។ ខ្ញុំសូមអានចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ក្រែងលោវាជួយរំឭកដល់ការចងចាំរបស់លោកបានខ្លះ។ គឺឯកសារ E3/9487 ចម្លើយ៦៧៦ ដល់៦៧៨ សូមដកស្រង់៖ "ខ្ញុំបានរៀននៅសាលាកសិកម្មនៅមេច្បារ ខេត្តបាត់ដំបង។ សួរ៖ តើលោកនៅបាត់ដំបងអស់

រយៈពេលប៉ុន្មាន? ឆ្លើយ៖ ខ្ញុំបានរស់នៅបាត់ដំបងអស់រយៈពេល១ឆ្នាំ។ សួរ៖ អ៊ីចឹងនៅពេលនោះ លោកធ្វើអ្វី? ឆ្លើយ៖ ក្រោយពីសិក្សាបាន១ឆ្នាំ កងទ័ពវៀតណាមក៏បានចូលមកក្នុងប្រទេសកម្ពុជា។" បញ្ចប់ការដកស្រង់។ តើត្រឹមត្រូវដែរទេ លោកសាក្សី នៅពេលថាលោកបានសិក្សានៅសាលាកសិកម្មហ្នឹងប្រហែល១ឆ្នាំ មុនពេលកងទ័ពវៀតណាមចូលមកក្នុងប្រទេសកម្ពុជា?

**ឆ៖** បាទ ហ្នឹងហើយ ត្រឹមត្រូវ។

[១០:៤៣:២៨]

**ស៖** តើលោកសាក្សី លោកចាំច្បាស់ទេ នៅពេលនោះ មូលហេតុដែលខ្ញុំសួរនេះ គឺថាកងទ័ពវៀតណាមបានចូលលុកលុយកម្ពុជា នៅខែមករា ១៩៧៩ មានន័យថា លោកនៅបាត់ដំបង អស់រយៈពេលប្រហែល១ឆ្នាំ។ អ៊ីចឹងគឺភាគីច្រើន គឺលោកអាចនៅទីនោះស្ទើរពេញមួយឆ្នាំ១៩៧៧ ហើយចូលឆ្នាំ១៩៧៨ ហើយដែល គឺនៅពេលដែលលោកចាកចេញពីត្រាំកក់ទៅបាត់ដំបងហ្នឹង តើវានៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ អ៊ីចឹងឬ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកបាននិយាយអំពីព្រឹត្តិការណ៍មួយ ដែលលោកបានរៀបរាប់ថា គឺលោកបានចូលរួមដឹកជញ្ជូនប្រជាជនអស់រយៈពេល៤ថ្ងៃ។ តើលោកនៅចាំទេ នៅពេលដែលលោកទទួលបញ្ជាឲ្យដឹកជញ្ជូនប្រជាជនក្នុងរយៈពេល៤ថ្ងៃហ្នឹង គឺនៅក្នុងអំឡុងពេលដែល យាយខុម ជាលេខាស្រុក ឬក៏នៅពេលដែល តាជឹម ជាចៅហ្វាយស្រុក?

**ឆ៖** បាទរឿងនេះខ្ញុំក្តាប់មិនបានដែរ ព្រោះការបញ្ជាខ្ញុំឲ្យទៅដឹកប្រជាជននោះ គឺខាងៗមន្ទីរៗផ្សេងក្រៅពីមន្ទីររបស់លេខាស្រុក ហើយនិងគណៈៗស្រុក និងការបញ្ជាឲ្យខ្ញុំទៅៗដឹកប្រជាជនអស់ទាំងនោះ។

**ស៖** តើនៅពេលនោះអ្នកណាជាចៅហ្វាយស្រុក? តើពេលដឹកជញ្ជូនហ្នឹង គឺនៅពេលដែល យាយខុម ជាចៅហ្វាយស្រុក ឬក៏នៅពេលដែល តាជឹម ជាចៅហ្វាយស្រុក?

**ឆ៖** នៅពេលនោះគឺ យាយខុម ជាចៅហ្វាយស្រុក។

[១០:៤៧:០០]

**ស៖** ខ្ញុំសូមសួរលោកនូវចម្លើយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/9487 ពីចម្លើយ៤៩៧ដល់៤៩៨ សំណួរសួរអំពីព្រឹត្តិការណ៍ទាំងនោះ "សួរ៖ តើអ្នកណាជា

ចៅហ្វាយស្រុក? ឆ្លើយ៖ ចៅហ្វាយស្រុកគឺ យាយខុម អ៊ំ!សុំទោស ចៅហ្វាយស្រុកគឺ ជឹម ទេ។ សួរ៖ តើ ពេជ្រ ជឹម ហ្នឹងឬ? ឆ្លើយ៖ បាទគឺ ពេជ្រ ជឹម ហ្នឹងហើយ។" បញ្ចប់ការដកស្រង់។ ដូច្នេះតើលោកអាចបញ្ជាក់ជូនតុលាការបន្តិចបានទេ ថាលោកប្រាកដថា នៅពេលដែលលោកដឹកជញ្ជូនមនុស្សហ្នឹងគឺ យាយខុម ជាប្រធានស្រុក ឬនៅពេលដែល តាជឹម ជាប្រធានស្រុក គឺពេលដែលលោកដឹកជញ្ជូនប្រជាជនអស់រយៈពេល៤ថ្ងៃហ្នឹង លោកច្បាស់ថា នៅពេលដែលអ្នកណាជាប្រធានស្រុក?

**ឆ៖** កាលដែលបញ្ជាឲ្យខ្ញុំទៅដឹក គឺគណៈមន្ទីរៗស្រុក ខាងឈ្មោះៗ ភី ហ្នឹងខាងមន្ទីរៗស្រុក។ ហើយការបញ្ជា យាយខុម ឬ តាជឹម បញ្ជា ខ្ញុំអត់បានដឹងទេ។ ហ្នឹងនិយាយការពិតរបស់ខ្ញុំ។

**សៈ** តើ ភី ហ្នឹងជាអ្នកណា ភី ដែលបញ្ជាលោកហ្នឹង?

**ឆ៖** ភី ហ្នឹងគឺជាអ្នកនៅមន្ទីរៗ ផ្សេងទៀត។

**សៈ** តើបុគ្គលម្នាក់នេះឈ្មោះ ភី ឬក៏ឈ្មោះ ធី?

**ឆ៖** បាទ ឈ្មោះ ភីៗ។

**សៈ** តើនៅថ្នាក់ស្រុកហ្នឹង ភី ទទួលខុសត្រូវផ្នែកអ្វីដែរ មានតួនាទីអ្វីដែរ?

**ឆ៖** ខ្ញុំជាអ្នកទទួលខុសត្រូវខាងមនុស្ស សម្រាប់ទទួលខុសត្រូវខាងផ្នែកគ្រប់គ្រងកន្លែងទាំងអស់ ទាំងមើលការខុសត្រូវគ្រប់កន្លែងមន្ទីរទាំងអស់បាទ។

[១០:៥១:០៧]

**សៈ** ខ្ញុំសូមអាននូវចម្លើយរបស់លោកនៅចម្លើយ៤៦៣ សូមដកស្រង់៖ "សំណួរ៖ អ្នកណាទទួលខុសត្រូវស្រុកត្រាំកក់? ចម្លើយ៖ អ្នកដែលទទួលខុសត្រូវត្រាំកក់ហ្នឹងរួមទាំងប្រធានស្រុក អនុប្រធានស្រុក និងសមាជិស្រុក ហើយអ្នកដែលទទួលខុសត្រូវសម្រាប់មន្ទីរអប់រំគឺឈ្មោះ ភី។" បញ្ចប់ការដកស្រង់។ តើត្រឹមត្រូវដែរទេ លោកសាក្សី ដែលថាបុគ្គលដែលចាត់តាំងឲ្យលោកពាក់ព័ន្ធក្នុងការដឹកជញ្ជូនប្រជាជនហ្នឹង គឺជាមនុស្សដែលទទួលខុសត្រូវខាងផ្នែកមន្ទីរអប់រំនៅស្រុកត្រាំកក់ តើអ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ អ៊ីចឹងហើយ ត្រឹមត្រូវ។

**សៈ** តើមន្ទីរអប់រំស្រុកដែល ភី ទទួលខុសត្រូវហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរទទួលខុសត្រូវរបស់ ភី ហ្នឹងគឺនៅឆ្ងាយ នៅឆ្ងាយពីកន្លែងលេខាស្រុក អនុស្រុក សមាជិកស្រុក បាទនៅឆ្ងាយពីគ្នា។

**ស៖** មន្ទីរស្រុកដែលលោកធ្វើការនុ៎ង តើវាស្ថិតនៅក្នុងភូមិឃុំអ្វីដែរនៅក្នុងស្រុកត្រាំកក់ហ្នឹង?

**ឆ៖** បាទ មន្ទីររបស់ ភី ហ្នឹងគឺនៅឆ្ងាយៗ នៅក្នុងភូមិនៅក្នុងស្រុកដែរ មិនមែននៅឆ្ងាយទេ។ វានៅឆ្ងាយពីគ្នា។

**ស៖** ឥឡូវនេះ ខ្ញុំកំពុងតែសួរលោកអំពីមន្ទីរស្រុកតែម្តង គឺមន្ទីរស្រុកនៅពេលដែលលោកធ្វើការជានីរសារ តើមន្ទីរស្រុកហ្នឹង វាស្ថិតនៅក្នុងទីតាំងភូមិអី ឃុំអី នៃស្រុកត្រាំកក់ហ្នឹង?

**ឆ៖** បាទ មន្ទីរស្រុកហ្នឹង សម្រាប់ទទួលខុសត្រូវប្រជាជនហ្នឹង គឺនៅក្នុងឃុំសំរោងៗ តែមិនដឹងភូមិអី ស្រុកត្រាំកក់ដដែល។ ភូមិ ខ្ញុំអត់ក្តាប់បាន។

[១០:៥៥:០២]

**ស៖** គឺមន្ទីរហ្នឹងស្ថិតនៅភូមិសំរោង តើលោកកំពុងតែនិយាយពីមន្ទីររបស់ ភី ហ្នឹងឬដែលស្ថិតនៅក្នុងភូមិសំរោងនោះ?

**ឆ៖** បាទ សូមម្តងទៀត។

**ស៖** មន្ទីរដែលលោកនិយាយថាស្ថិតនៅភូមិសំរោងហ្នឹង ជាមន្ទីររបស់ ភី ហ្នឹងឬ?

**ឆ៖** បាទ ជាមន្ទីររបស់ ភី ហើយ ភី ក៏នៅក្នុងភូមិរបស់គាត់ ស្រុកកំណើតរបស់គាត់នៅសំរោងហ្នឹងដែរ ប៉ុន្តែមន្ទីរមិនមែននៅបៀតផ្ទះគាត់ទេ នៅឆ្ងាយពីផ្ទះគាត់ ហ្នឹងមន្ទីរគាត់។

**ស៖** ហើយមន្ទីរដែលលោកធ្វើការជានីរសារស្រុកនោះ តើមន្ទីរស្រុកហ្នឹងស្ថិតនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរដែលខ្ញុំធ្វើការនៅជានីរសារនៅខាងស្រុក គឺនៅៗអង្គរកា វត្តអង្គរកា និយាយរួមទៅគឺនៅមិនកំណត់ទេ ម្តងនៅត្រង់នេះ ម្តងនៅត្រង់នោះអ៊ីចឹងទៅ ផ្លាស់ប្តូរកន្លែងជាប់។

**ស៖** សូមអរគុណលោកសាក្សី។ ហេតុផលដែលខ្ញុំសួរហ្នឹងដោយសារយើងបានស្តាប់សក្ខីកម្មរបស់សមាជិកមន្ទីរសន្តិសុខ ឬក៏សមាជិកមន្ទីរអប់រំស្រុកត្រាំកក់ពីរនាក់។ ម្នាក់នៅក្នុងចំណោមសាក្សីទាំងពីរហ្នឹង គឺរស់នៅភូមិព្រំប្រទល់នឹងស្រុក នឹងឃុំសំរោងក្បែរក្រាំងតាចាន់។ យើងក៏បានស្តាប់សក្ខីកម្មរបស់អ្នកធ្វើការនៅមន្ទីរអប់រំដែលស្ថិតនៅអង្គរកា មិនឆ្ងាយពីមន្ទីរអប់រំស្រុកនៅអង្គរកានោះទេ។ តើមន្ទីរមួយណាដែល ភី ទទួលខុសត្រូវ ឬក៏ ភី ទទួលខុសត្រូវមន្ទីរទាំងពីរនេះ? តើ ភី ទទួលខុសត្រូវមន្ទីរដែលស្ថិតនៅព្រំប្រទល់ឃុំសំរោង និងឃុំគុស ឬក៏ ភី ទទួលខុសត្រូវមន្ទីរអប់រំកែប្រែដែលមានទីតាំងនៅអង្គរកា?

[១០:៥៨:៣៤]

**ឆ៖** បាទ បញ្ហានេះគឺឈ្មោះ ភី គឺជាអ្នកទទួលខុសត្រូវរួម ខាងកន្លែងស្រុក ខាងលេខាស្រុក ក៏គាត់ទទួលខុសត្រូវដែរ អាហ្នឹងគ្រប់ៗទាំងអស់។ ហ្នឹងបន្ទាប់ ភី ហ្នឹងជាបន្ទាប់លេខាស្រុក លេខាស្រុកត្រូវការអីគឺបញ្ជាឲ្យ ភី ហ្នឹងធ្វើ ប៉ុណ្ណឹង។

**ស៖** មុននឹងខ្ញុំបន្តសំណួរទៅមុខទៀត មន្ទីរអប់រំកែប្រែនៅឃុំអង្គរកា តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ ម៉េង ដែរទេ ដែលគាត់ធ្វើការនៅមន្ទីរអប់រំនៅអង្គរកា គឺគាត់ឈ្មោះ ម៉េង លោកស្គាល់ទេ?

**ឆ៖** បាទ អត់, អត់ស្គាល់។

**ស៖** លោកបាននិយាយពីឈ្មោះ ភី ដែលគាត់មានតួនាទីនៅក្នុងគណៈកម្មការស្រុក។ លោកស្គាល់មនុស្សម្នាក់ធ្វើការនៅថ្នាក់ស្រុកហ្នឹងដែរឈ្មោះ កើន -- ឈ្មោះ ឌឿន លោកស្គាល់ទេ ឈ្មោះ ឌឿន (សូមទោស) ឈ្មោះ ឌឿន?

**ឆ៖** អត់ទេ បាទ ភ្លេចបាត់អស់។

**ស៖** ដូច្នេះលោកមិនចាំអំឡុងពេលដែលបុគ្គលម្នាក់ឈ្មោះ ឌឿន ទទួលតំណែងពី ភី នោះទេឬ?

**ឆ៖** បាទ អត់ចាំ ហើយអត់ស្គាល់។

[១១:០១:១២]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំត្រឡប់បន្តិច សួរសំណួរមួយអំពីពេលវេលា គឺពេលវេលាហេតុការណ៍ដែលថា ៤ថ្ងៃដែលលោកបានចូលរួមដឹកមនុស្ស លោកបាននិយាយអំពីពេលមួយ ពេលដែលលោកមេធាវីការពារក្ដីសួរនោះ លោកនិយាយអំពីវិធី ដែលលោកបានដឹងពីមនុស្សនៅថ្នាក់ស្រុកអំពីការដឹកមនុស្សចេញដែលមានវៀតណាមចំនួនច្រើន ប៉ុន្តែលោកនិយាយថា លោកមិនបានចូលរួមនៅក្នុងការដឹកជញ្ជូនមនុស្សទាំងអស់នោះទេ។ ហើយលោកក៏បាននិយាយពីហេតុការណ៍៤ថ្ងៃ ដែលលោកបានចូលរួមនៅក្នុងការដឹកនាំមនុស្សមួយចំនួនធំ មួយចំនួនច្រើន។ ខ្ញុំចង់ឲ្យលោកបំភ្លឺអំពីពេលវេលានៃហេតុការណ៍ទាំងពីរហ្នឹង តើពេលណាដែលលោកបានចូលរួមនៅក្នុងការដឹកមនុស្ស? តើលោកហេតុ-ការណ៍នោះកើតឡើងនៅពេលណា បើពាក់ព័ន្ធទៅនឹងការជម្លៀសមនុស្សចេញ ការបញ្ជូនមនុស្សចេញដែលលោកបានដឹងឮនោះ?

**ឆ៖** បាទ រឿងនេះ ខ្ញុំបាន ខាងថ្នាក់ដឹកនាំស្រុកបញ្ជាឲ្យខ្ញុំទៅដឹកមនុស្ស ដឹកប្រជាជនអស់ -- វៀតណាមទាំងនោះមែន។ ហើយពេលវេលា ក៏ខ្ញុំអត់ចាំដែរ មិនដឹងជាថ្ងៃណា ថ្ងៃណី ខ្ញុំអត់បានចាំ គឺខ្ញុំ

បានទៅដឹកប្រជាជនវៀតណាមនោះមែន តាមបញ្ជារបស់ឈ្មោះ ភី ហ្នឹង។

**ស៖** ខ្ញុំសួរទៅលោកអំពីរយៈពេល៤ថ្ងៃ ដែលលោកដឹកមនុស្សទាំងអស់នោះ តើ៤ថ្ងៃហ្នឹងមុនពេលដែលលោកឮអំពីពីការជម្លៀសមនុស្សចេញ ឬក៏ក្រោយពីៗ ការជម្លៀសជនជាតិវៀតណាមចេញ ដែលលោកបានដឹកមនុស្សចំនួន៤ថ្ងៃនោះ?

**ឆ៖** បាទ ក្នុងការជម្លៀសនេះ គឺក្នុង៤ថ្ងៃហ្នឹង ក្នុងពេលជាមួយគ្នា ជិតៗគ្នាហ្នឹង។

[១១:០៤:២២]

**ស៖** មនុស្សដែលលោកបានដឹកនៅក្នុងរយៈពេល៤ថ្ងៃនោះ តើគេបញ្ជាឲ្យលោកដឹកទៅកន្លែងណា?

**ឆ៖** មនុស្សដែលគេបញ្ជាឲ្យខ្ញុំដឹកនោះ គឺយកទៅដាក់ត្រាំកក់ បាទដាក់ត្រាំកក់។

**ស៖** តើត្រាំកក់ហ្នឹងនៅត្រង់កន្លែងណា ជាកន្លែងជាក់លាក់ដែលលោកអាចបញ្ជាក់បាន?

**ឆ៖** ត្រាំកក់ គឺនៅក្នុង ខាងៗលិច -- ខាងត្បូងអង្គតាសោម ហើយក៏ត្រូវនៅក្នុងឃុំញ៉ែងញ៉ង ខាងហ្នឹង ជាប់គ្នាហ្នឹង។

**ស៖** តើញ៉ែងញ៉ង ឃុំញ៉ែងញ៉ងកាលណោះ តើមានអ្វីនៅទីនោះ ជាមន្ទីររបស់គេនៅទីនោះ ដែលត្រូវយកមនុស្សទៅដាក់កន្លែងហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** មន្ទីរញ៉ែងញ៉ង អត់មានមន្ទីរអីទេ យកទៅដល់ ដាក់ដល់ត្រាំកក់តែម្តង កន្លែងញ៉ែងញ៉ង គឺជាកន្លែងឃុំ ជាកន្លែងឃុំញ៉ែងញ៉ង ហើយប្រជាជនហ្នឹងគឺដឹកយកទៅដល់ត្រាំកក់។

**ស៖** នៅពេលដែលលោកនិយាយថា ក្រោយពេលគេមកដល់ យកទៅដាក់ត្រាំកក់ តើលោកចង់និយាយយ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះគេឲ្យខ្ញុំយកទៅដាក់ដល់ហ្នឹង ក៏ដាក់ហ្នឹងទៅ អត់បានដឹងយ៉ាងម៉េចៗ អត់បានដឹងទេ។

[១១:០៧:២២]

**ស៖** ខ្ញុំនឹងប្រាប់ពីមូលហេតុដែលខ្ញុំសុំការបំភ្លឺ នៅក្នុងបទសម្ភាសន៍ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/9487 គឺសំណួរចម្លើយ៤៦៦ ដល់៤៦៧។ គេសួរថា៖ "តើលោកដឹកមនុស្សចេញពីកន្លែងណាទៅកន្លែងណា? ឆ្លើយ៖ ខ្ញុំដឹកពីឃុំយកទៅដាក់ត្រាំកក់។ សំណួរ៖ ទៅមន្ទីរស្រុកត្រាំកក់ ឬយ៉ាងណា? ចម្លើយ៖ បាទ។" ចប់សេចក្តីដកស្រង់។ តើខ្លឹមសារនេះ ធ្វើឲ្យលោកនឹកឃើញ

ឡើងវិញទេ គឺថា ដែលថាលោកបានដឹកមនុស្សទាំងអស់នេះទៅស្រុកត្រាំកក់? ក្នុងករណីបែបនោះមុន គឺថាតើៗមន្ទីរស្រុកត្រាំកក់ស្ថិតនៅក្នុងឃុំញ៉ែងញ៉ងៗដែរឬទេ នៅពេលនោះ? សូមលោកជួយបំភ្លឺបញ្ជាក់។

**ឆ៖** បាទ ដែលកាលណោះគឺ ដឹកប្រជាជនទៅ គឺដាក់ដល់ត្រាំកក់ៗតែម្តង ហើយក៏ អត់មាននៅមន្ទីរអី អត់មាននៅជាប់ក្នុងឃុំញ៉ែងញ៉ងអីទេ អត់ទេ។

**ស៖** តើអ្នកណាជាអ្នកទទួលមនុស្សដែលលោកបានដឹកទៅ ពេលដែលលោកដាក់គេនៅកន្លែងហ្នឹង? តើអ្នកណាជាអ្នកទទួលពួកគេនៅៗចំណុចទិសដៅដែលលោកយកទៅដាក់ហ្នឹង?

**ឆ៖** បាទ តាមការខ្ញុំដឹងគឺដឹកទៅដល់ ខាងប្រធានឈ្លបដែលជាអ្នកទទួលមនុស្សទាំងអស់នោះ។

**ស៖** នៅពេលដែលលោកនិយាយប្រធានឈ្លប តើលោកនិយាយអំពីប្រធានឈ្លបស្រុក ឬក៏ប្រធានឈ្លបឃុំ?

**ឆ៖** បាទ ប្រធានឈ្លបនោះគឺជាប្រធានឈ្លបរបស់ស្រុក។

**ស៖** តើប្រធានឈ្លបស្រុកហ្នឹង គាត់ឈ្មោះអ្វីនៅពេលនោះ តាមដែលលោកចាំ?

**ឆ៖** ភ្លេចហើយ ខ្ញុំភ្លេចហើយ ឈ្មោះអីទេ។

[១១:១០:៥១]

**ស៖** ខ្ញុំនឹងត្រឡប់មកចំណុចនេះនៅពេលបន្តិចខាងមុខនេះ។ នៅពេលដែលលោកដឹកមនុស្សក្នុងរយៈពេលបួនថ្ងៃនេះ តើលោកប្រើមធ្យោបាយដឹកជញ្ជូនអ្វីខ្លះ? សូមលោករៀបរាប់ពីមធ្យោបាយដឹកជញ្ជូន លោកប្រើអ្វីដើម្បីដឹកអ្នកទាំងនោះ?

**ឆ៖** បាទ ការដឹកជញ្ជូនមនុស្សទាំងអស់នោះ គឺឡាន ដឹកដោយកម្លាំងឡាន។

**ស៖** លោកប្រើឡានប៉ុន្មានកាលនោះ?

**ឆ៖** ឡានតែមួយ ប៉ុន្តែធំ ឡានធំ។

**ស៖** នៅពេលដែលលោកនិយាយថា ឡានធំ សូមលោកបញ្ជាក់ពីសេចក្តីលម្អិតធំប៉ុនណា? តើលោកនៅចាំទេ ប្រភេទឡានធំហ្នឹង ប្រភេទអ្វីជាដើម?

**ឆ៖** ឡាននោះធំ ទ្រុងធំ គេហៅឈ្មោះហ្វូស្តាំង មានដំបូល ទ្រុងធំ។

**ស៖** នៅក្នុងអំឡុងពេលបួនថ្ងៃនោះ លោកសាក្សី តើលោកទៅទទួលដឹកមនុស្សចេញពីប៉ុន្មានឃុំដើម្បីដឹកយកមកមន្ទីរស្រុកកាលនោះ?

**ឆ៖** បាទ តាមការបញ្ជារបស់ខាងមន្ទីរ ឲ្យខ្ញុំទៅដឹក មានឃុំ មានបួនឃុំ មានឃុំអង្គតាសោម, មានលាយបូរ, មានពពេល, ញ៉ែងញ៉ង, គុស បាទបួនប្រាំ ប្រាំឃុំ។ ហើយស្រែរនោង ស្រែរនោងមួយទៀត។

[១១:១៣:៥២]

**ស៖** តើលោកទៅកាន់កន្លែងណានៅក្នុងឃុំនីមួយៗនេះ? តើលោកទៅយកមនុស្សហ្នឹងនៅចំណុចត្រង់ណា? តើអ្នកណានៅក្នុងឃុំនីមួយៗនោះ ក្នុងការប្រគល់មនុស្សដែលលោកត្រូវដឹកចេញមកនោះ? សូមលោករៀបរាប់អំពីដំណើរការដែលថាទៅដល់ ទៅកន្លែងណា ទទួលពីអ្នកណាជាដើម។

**ឆ៖** បាទ ដែលខ្ញុំយកឡានទៅដឹកតាមឃុំនីមួយៗនោះ គឺទៅកន្លែងឃុំ។ ដូចឃុំអង្គតាសោម បរឡានទៅចូលដល់ឃុំអង្គតាសោមហ្នឹង អាហ្នឹងកំណត់នៅលើប្រធានឃុំប្រមូលមនុស្សដាក់កន្លែងណា គេប្រាប់ឡានឲ្យទៅកន្លែងណោះ។ ហើយដល់ទៅខាងពពេល ខាងពពេលនៅ ឃុំប្រមូលដាក់កន្លែងណា នៅជាប់ផ្លូវខ្មៅ យកមកប្រមូលគាត់ដាក់កន្លែងណាទៅ កន្លែងណាមួយ ឡានទៅដឹកកន្លែងហ្នឹងទៅ។ តាមឃុំនីមួយៗគឺអ៊ីចឹង ហើយដោយឃុំណាពិបាកពេក ដូចជាឃុំរនោង ស្រែរនោង ហ្នឹងយកមកដាក់ផ្លូវអ៊ីចឹងមក ឲ្យគាត់មកផ្លូវ។ បាទហ្នឹងអ៊ីចឹង ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ប៉ុន្តែនៅក្នុងឃុំនីមួយៗដែលលោកបានទៅកាន់នោះ គឺជាមេឃុំដែលជាអ្នកទទួលបន្ទុកក្នុងការប្រមូលមនុស្សដែលលោកត្រូវដឹក។ តើអ៊ីចឹង ឬយ៉ាងម៉េចបាទ?

**ឆ៖** បាទ ហ្នឹងអ៊ីចឹង បាទអ៊ីចឹង។

**ស៖** លោកបានកំណត់អត្តសញ្ញាណឈ្មោះឃុំមួយចំនួន ដែលលោកទៅទទួលមនុស្សទាំងអស់នោះ។ តើលោកអាចដឹកមនុស្សទាំងអស់ ដែលត្រូវបានប្រមូលនៅក្នុងឃុំនីមួយៗតែមួយជើង ឬក៏លោកទៅច្រើនជើងនៅក្នុងឃុំទាំងអស់នេះ? បាទ ចង់សួរបែបនេះ។

[១១:១៦:៥០]

**ឆ៖** ការដឹកនេះគឺឃុំណាដែលច្រើន ពីរជើង ហើយបើតិច តែមួយជើងទេ។ ហ្នឹងអ៊ីចឹង។

**ស៖** តើលោកនៅចាំដែរឬទេ ថាឃុំណាដែលមានមនុស្សច្រើន ដែលលោកត្រូវដឹកពីរជើង?

**ឆ៖** បាទ អត់ទេ អត់ចាំទេ។

**ស៖** ឡានធំដែលលោកបានរៀបរាប់ តើអាចដឹកមនុស្សបានប៉ុន្មាននាក់ ចំណុះមនុស្សប៉ុន្មាននាក់ ឡានធំនេះបាទ?

**ធ៖** ឡាននោះគឺដឹកចំណុះ៥០នាក់ ឬក៏៦០នាក់តែប៉ុណ្ណោះ។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំនឹងត្រឡប់មកចំណុចនេះពេលក្រោយ ដើម្បីសួរលោកបន្ថែមទៀតអំពីអ្វីៗដែលកើតឡើងទាក់ទងនៅក្នុងរយៈពេល៤ថ្ងៃនោះ។ ប៉ុន្តែដំបូងខ្ញុំសួរសំណួរមួយចំនួនអំពី តាម៉ុក សិន។ នៅពេលដែលលោកធ្វើការនៅមន្ទីរស្រុក តើ តាម៉ុក ធ្លាប់មកមន្ទីរត្រាំកក់ ហើយនិងគាត់បានរៀបចំកិច្ចប្រជុំអ្វីនៅទីនោះដែរឬទេ?

**ធ៖** បាទ គាត់មកដែរនៅក្នុង មកមន្ទីរស្រុកដែរ ប៉ុន្តែមិនបានប្រជុំអីទេ មកមួយភ្លែតក៏គាត់ទៅបាត់ទៅ។ បាទគឺអ៊ីចឹង។ មកដល់ជួបខាងស្រុក និយាយគ្នា ប៉ុន្តែមិនដឹងជានិយាយអី ខ្ញុំក៏មិនបានដឹងដែរ បាទប៉ុណ្ណឹង។

**ស៖** បាទ ឥឡូវនេះយើងនិយាយពីលេខាតំបន់ បាទគឺតាគិតស្រុក -- តំបន់តាកែវ១៣ ថាតើលេខាតំបន់ហ្នឹងគាត់មកមន្ទីរស្រុកដែរឬទេ មកញឹកញាប់ប៉ុនណា?

**ធ៖** លេខាតំបន់គាត់ ខ្ញុំមិនបានដឹងដែរ មិនដឹងជាគាត់មកញឹកញាប់អីយ៉ាងម៉េច អត់បានដឹងដែរ។

[១១:២១:០០]

**ស៖** នៅក្នុងបទសម្ភាសន៍របស់លោក លោកសាក្សី លោកបានបញ្ជាក់អំពីសាច់ថ្លៃរបស់លោកបុរសម្នាក់ឈ្មោះ តាទិត្យ ដែលរៀបការប្អូនស្រីម្នាក់របស់ តាម៉ុក ហើយលោកនិយាយថា គាត់នោះគឺជាលេខាតំបន់ក្នុងពេលមួយ។ តើលោកនៅចាំដែរឬទេថា តាទិត្យ មកមន្ទីរស្រុកត្រាំកក់ដែរឬទេកាលដែលគាត់ធ្វើជាលេខាតំបន់កាលនោះ?

**ធ៖** បាទ កាលនោះគឺគាត់ដើរធ្វើការជាប់ទៅតាមស្រុកនីមួយៗ។

**ស៖** ទាក់ទងនឹងលេខាតំបន់ តើលោកនៅចាំកម្មាភិបាលម្នាក់ឈ្មោះ សោម ដែលជាលេខាតំបន់មុន តាទិត្យ? តើលោកចាំគាត់ទេ?

**ធ៖** បាទ ធ្លាប់ៗស្គាល់គាត់ ស្គាល់។

**ស៖** តើ សោម នេះៗធ្លាប់មកមន្ទីរស្រុកដែរឬទេ?

**ធ៖** បាទ សោម នេះគឺគាត់ធ្លាប់មកៗមន្ទីរស្រុក។ ហើយតែគាត់ស្លាប់បាត់ហើយ។

**ស៖** តើមានឱកាសណាមួយដែល តាម៉ុក ហើយនិងលេខាតំបន់ ឬមួយក៏ តាសោម ឬ តាទិត្យ នៅពេលនោះគឺមកជាមួយគ្នា មកមន្ទីរស្រុកត្រាំកក់នៅក្នុងពេលតែមួយទេ?

**ឆ៖** បាទ ក្នុងរឿងនេះខ្ញុំអត់បានដឹងដែរ អត់បានយល់ដែរ។ មិនដឹងគាត់មកយ៉ាងម៉េច ខ្ញុំអត់យល់ អត់ដឹង។

[១១:២៤:៥៨]

**ស៖** ខ្ញុំនឹងជួយរំឭកការចងចាំរបស់លោក លោកសាក្សី គឺថាបទសម្ភាសន៍ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ចម្លើយ៩០៧៖ "សួរ៖ តើ តាទិត្យ មកមន្ទីរដែរទេ? ឆ្លើយ៖ គាត់បានមកមន្ទីរស្រុកនៅជាមន្ទីររបស់លេខា។" គឺសំណួរចម្លើយ៩០៩ទៅដល់៩១១៖ "សំណួរ៖ តើ តាទិត្យ មកមន្ទីរស្រុកត្រាំកក់ទៀងទាត់ដែរឬទេ? ចម្លើយ៖ តាមធម្មតា ថ្នាក់ដឹកនាំខាងលើតែងតែជួបគ្នា ប៉ុន្តែខ្ញុំមិនដឹងថាគេមកដើម្បីធ្វើអ្វីទេ។ សំណួរ៖ នៅពេលដែល តាទិត្យ មកមន្ទីរស្រុកត្រាំកក់ តើគាត់បានជួបជាមួយអ្នកណា? ចម្លើយ៖ គាត់បានជួបជាមួយ តាម៉ុក នៅមន្ទីរស្រុក មិនមែននៅមន្ទីរអប់រំទេ ជាកន្លែងដែលគេឃុំខ្លួននោះទេ ឃុំខ្លួនមនុស្សនោះទេ។ សំណួរ៖ នៅពេលដែល តាទិត្យ មកមន្ទីរស្រុកជាមន្ទីរលេខាស្រុកនោះ តើលោកបានឃើញ តាម៉ុក មកជាមួយគាត់ទេ? ចម្លើយ៖ ជួនកាល តាម៉ុក នៅមន្ទីរនោះ ហើយ តាទិត្យ ក៏បានមកមន្ទីរនោះដែរ។" ចប់សេចក្តីដកស្រង់។

តើខ្លឹមសារនេះរំឭកការចងចាំរបស់លោកទេ គឺថាមានពេលខ្លះគឺ តាម៉ុក និង តាទិត្យ ហ្នឹងមកមន្ទីរស្រុកជួបគ្នានៅមន្ទីរស្រុកត្រាំកក់? តើលោកនៅចាំដែរឬទេ ថាពួកគេមកជួបនៅទីនោះ ហើយជួបគ្នាជាមួយនឹងលេខាស្រុកដែរឬទេ?

**ឆ៖** បាទ ការមកហ្នឹង គឺមកតែងតែជួប ជួបគ្នា ជួប។

**ស៖** នៅចម្លើយ៩១៣ គេសួរលោកថា៖ "តើ តាម៉ុក ហើយនិង តាទិត្យ ជួបជាមួយលេខាស្រុកដែរឬទេ? លោកឆ្លើយថា៖ បាទ។" តើលោកនៅចាំដែរឬទេ នៅពេលដែលលោកបានឃើញ តាម៉ុក ហើយនិង តាទិត្យ នៅមន្ទីរស្រុកកាលនោះ? តើកាលនោះគឺលេខាស្រុកហ្នឹងឈ្មោះអី ដែលគាត់ជួប? តើនៅពេលដែល យាយខុម ជាលេខាស្រុក ឬក៏នៅពេលដែល ពេជ្រ ជឹម ជាលេខាស្រុកត្រាំកក់ នៅពេលនោះ?

[១១:២៧:០១]

**ឆ៖** ខ្ញុំអត់យល់ អត់ដឹង។

**ស៖** ខ្ញុំអានជូនលោកពីអ្វីដែលលោកបានប្រាប់ទៅអ្នកស៊ើបអង្កេត ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺចម្លើយ៩១៥ដល់៩១៦៖ "សំណួរ៖ នៅពេលដែល តាទិត្យ និង តាម៉ុក ទៅមន្ទីរស្រុក

ត្រាំកក់ តើ ពេជ្រ ជឹម បានទៅជួប តាទិត្យ និង តាម៉ុក ដែរឬទេ? ឆ្លើយ៖ ថ្នាក់ដឹកនាំតែងតែជួបគ្នាហើយ។ សំណួរ៖ មានន័យថា ពេជ្រ ជឹម ក៏បានទៅជួប តាម៉ុក និងតាទិត្យ ផងដែរ តើត្រឹមត្រូវដែរ ឬទេ? ចម្លើយ៖ បាទ។” ចប់សេចក្តីដកស្រង់។ តើខ្លឹមសារនេះរំឭកការចងចាំរបស់លោកដែរឬទេ នៅពេលដែល ពេជ្រ ជឹម ធ្វើជាលេខាស្រុក ហើយ តាម៉ុក និងតាទិត្យ បានមកមន្ទីរស្រុក?

**ឆ៖** បាទ ខ្ញុំយល់ស្រប ត្រឹមត្រូវ។

**ស៖** តើលោកចាំដែរឬទេ តើការជួបហ្នឹងមុន ឬក៏ក្រោយពេលដែលលោកបានឃើញ តាម៉ុក ហើយនិង តាទិត្យ មកមន្ទីរស្រុកត្រាំកក់? មុនពេលហ្នឹង ឬក៏ក្រោយពេលហ្នឹង ដែលលោកបានទទួលការចាត់តាំងឲ្យដឹកមនុស្សអស់រយៈពេល៤ថ្ងៃហ្នឹង?

**ឆ៖** មិនដឹងពេលណាទេ ខ្ញុំភ្លេចអស់ហើយ។

**ស៖** ខ្ញុំនឹងរំឭកការចងចាំលោកម្តងទៀតអំពីសេចក្តីដកស្រង់ពីបទសម្ភាសន៍របស់លោក គឺសំណួរចម្លើយ៨១៩ រហូតទៅដល់៨២០៖ “សំណួរ៖ ឥឡូវយើង -- លោកនិយាយថា គេបានបញ្ជាលោកឲ្យទៅដឹកជញ្ជូនប្រជាជនពីតាមឃុំ។ តើការដឹកជញ្ជូនប្រជាជននេះកើតឡើងមុន ឬក្រោយពេលដែល តាម៉ុក និងតាទិត្យ ទៅមន្ទីរស្រុកត្រាំកក់? ចម្លើយ៖ កើតឡើងក្រោយ។ សំណួរ៖ តើកើតឡើងក្រោយពេលដែលពួកគេប្រជុំគ្នាម្តង ឬក៏ប្រជុំច្រើនដង? ចម្លើយ៖ កើតឡើងក្រោយប្រជុំពីរបីដង។” ចប់សេចក្តីដកស្រង់។ តើខ្លឹមសារនេះ ធ្វើឲ្យលោកចងចាំឡើងវិញទេ អំពីការចាត់តាំងដែលលោកបានទទួលថាឲ្យដឹកមនុស្សនៅក្នុងរយៈពេល៤ថ្ងៃនោះ? តើការដឹកជញ្ជូនហ្នឹង ក្រោយពីការប្រជុំរបស់ តាម៉ុក, តាទិត្យ នៅមន្ទីរស្រុក? តើត្រឹមត្រូវអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំនឹកឃើញហើយ ត្រឹមត្រូវស្របតាម។

[១១:៣០:៤៨]

**ស៖** សូមលោកជម្រាបតុលាការ លោកសាក្សី អ្វីដែលលោកបានដឹងអំពីតួនាទីរបស់ តាម៉ុក នៅក្នុងការចេញបញ្ជាទៅគណៈស្រុកនៅពេលនោះ។ តើលោកដឹងថាតើ តាម៉ុក ជាអ្នកចេញបញ្ជាទៅគណៈស្រុក ដើម្បីឲ្យប្រមូលមនុស្សទាំងអស់ មនុស្សដែលលោកត្រូវដឹកហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ ការបញ្ជាគឺមិនមែន តាម៉ុក បញ្ជាផ្ទាល់ទេ គឺមាននីរសាររបស់គាត់សម្រាប់មកនាំពាក្យមកប្រាប់ខាងស្រុក បាទអ៊ីចឹង។

**ស៖** តើនីរសាររបស់ តាម៉ុក ដែលនាំបញ្ជាមកថ្នាក់ស្រុកហ្នឹងគាត់ឈ្មោះអ្វី?

**ឆ៖** នីរសាររបស់ តាម៉ុក នោះគឺឈ្មោះ ទូចៗ សម្រាប់ទទួលបញ្ជាពី តាម៉ុក។

**ស៖** នៅពេលដែលលោកធ្វើការនៅមន្ទីរស្រុក តើបញ្ជារបស់ តាម៉ុក ចេញផ្ទាល់ពីគាត់តាមរយៈនីរសាររបស់គាត់ ឬក៏គេផ្ញើបទបញ្ជានេះឆ្លងតាមមន្ទីរតំបន់មក?

**ឆ៖** បាទ រឿងនេះគឺឆ្លងកាត់តាមតំបន់ បញ្ជាមកខាងស្រុក។

**ស៖** បញ្ជាដែលមន្ទីរស្រុកបានទទួលនោះ ទទួលមកពី តាម៉ុក តាមរយៈតំបន់ តើបញ្ជាហ្នឹងរាប់បញ្ចូលថា មនុស្សណាដែលគេត្រូវចាប់ខ្លួនដែរឬទេ?

**ឆ៖** ការបញ្ជាហ្នឹងគឺបញ្ជាតាមនីរសាររបស់គាត់ ឈ្មោះ ទូច ហ្នឹង។ ហើយ ទូច ហ្នឹងក៏មកប្រាប់ មកទាក់ទងជាមួយខាងស្រុកមក។ បាទអាហ្នឹងអ៊ីចឹង។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំនឹងសួរសំណួរដកស្រង់ អាចនឹងដល់ពេលសម្រាកល្មមទេដឹងលោកប្រធាន។

[១១:៣៤:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៥៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ថាតើការតាំងសំណួរដេញដោលចំពោះសាក្សីនេះ ទំនងជាប្រើប្រាស់ពេលវេលាប្រហែលប៉ុន្មានទៅ តាមការប៉ាន់ស្មាន? អាចបញ្ជាក់បានដែរទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំត្រូវការពេលគឺពេញមួយវគ្គសម្រាប់ខ្ញុំតែម្តង ហើយប្រសិនបើមេធាវី កូប៉េ គាត់ចង់សួរបន្ថែមនូវវេលាដែលគាត់សល់ហ្នឹង គឺគាត់អាចប្រើបាន ចំពោះខ្ញុំគឺខ្ញុំត្រូវការពេលពេញតែម្តងសម្រាប់ការសួរសំណួរនេះ ក៏ប៉ុន្តែវាអាស្រ័យទៅលើសំណួរដែលបានសួរមុនខ្ញុំដែរ ប៉ុន្តែទោះជាយ៉ាងណាខ្ញុំគិតថា ខ្ញុំត្រូវការពេលមួយវគ្គពេញ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅវគ្គនេះ គឺអាចលៃពេលវេលាយ៉ាងហោចណាស់២០នាទីសល់សម្រាប់ផ្តល់ទៅឲ្យក្រុមសហមេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

ព្រឹកមិញ គឺសួរមុនអស់រយៈពេលប្រហែលជា១០នាទី អង្គជំនុំជម្រះជួសជុលបន្ថែម៥នាទីប្រហែលត្រូវ១៥នាទី។ នេះជាការសន្សំពេលវេលា ហើយបើអាចគឺទុកពេលវេលានេះ ឬក៏ពេលវេលាប្រហែលជា២០នាទី សម្រាប់ទុកឲ្យមេធាវី នួន ជា ដើម្បីសួរចុងក្រោយចំពោះសាក្សីរូបនេះ ចៀសវាងអញ្ជើញគាត់មកសាជាថ្មីម្តងទៀតនៅពេលណាមួយនាពេលខាងមុខនោះ វាមិនល្អទេរយៈពេលខ្លី ហើយបើទុកធ្វើសវនាការហួសពីម៉ោងបួនទៅនឹងមានការប្រតិកម្មពីមជ្ឈដ្ឋានបុគ្គលនៃអ.វ.ត.ក ដែលពាក់ព័ន្ធនឹងការគាំទ្រកិច្ចដំណើរការនេះផង ព្រោះបញ្ហាឥឡូវនេះ បញ្ហាការកកស្ទះចរាចរណ៍វាជាបញ្ហាមួយប្រឈមសម្រាប់យើងទាំងអស់គ្នា ដែលធ្វើត្រូវធ្វើដំណើរត្រឡប់ទៅផ្ទះវិញផ្លូវឆ្ងាយ។

[១៣:៣៦:១៨]

**លោក ឌេល លីសាក់៖**

ដើម្បីឲ្យខ្ញុំច្បាស់ថាការបកប្រែត្រឹមត្រូវ លោកប្រធានចង់ឲ្យខ្ញុំបញ្ចប់១៥*មីនុត*មុនចុងបញ្ចប់នៃវគ្គនេះ ឬយ៉ាងណា លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ លោករួមទាំងពេលវេលាសម្រាប់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផង ធ្វើយ៉ាងណាទុកពេលវេលា១៥*មីនុត*ចុងនៃវគ្គនេះ សម្រាប់ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន -- ការពារក្តី នួន ជា។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យើងបានពិភាក្សាគ្នាអំពីបញ្ហាថាតើមានការចាប់ខ្លួនដែលបញ្ជាដោយ តាម៉ុក ឬទេ។ ខ្ញុំបម្រុងនឹងអានជូនលោកនូវសេចក្តីដកស្រង់ពីបទសម្ភាសន៍របស់លោក គឺឯកសារ E3/9487 គឺថាត្រង់សំណួរ និងចម្លើយ៨៣៥ និង -- ៨៦៣ ដល់៨៦៥។ "ថាតើអ្នកណាជាអ្នកបញ្ជាឲ្យចាប់ខ្លួនអ្នកទោសធ្ងន់ និងអ្នកទោសស្រាល? ចម្លើយ៖ តាម៉ុក ជាអ្នកបញ្ជា។ អ្នកណាជាអ្នកទទួលបញ្ជាផ្ទាល់ពី តាម៉ុក? ចម្លើយ៖ តាម៉ុក បញ្ជាតាមរយៈស្រុក រួចមកឃុំ រួចហើយមកភូមិ។ សំណួរ៖ តើ តាម៉ុក កំណត់ថាអ្នកណាម្នាក់ជាអ្នកទោសធ្ងន់ដោយរបៀបណា? តើ តាម៉ុក ដឹងឈ្មោះអ្នកមានទោសធ្ងន់ដោយរបៀបណា? ចម្លើយ៖ គាត់ដឹងតាមរយៈថ្នាក់ឃុំ។" ចង់សេចក្តីដកស្រង់។

មុនពេលសម្រាក លោកបានបំភ្លឺតុលាការថា បញ្ជាចេញមកតាមរយៈតំបន់ ពី តាម៉ុក មក។ អ៊ីចឹងខ្ញុំសួរសំណួរទូទៅមួយ ថាតើលោកដឹងដោយររបៀបណា នៅពេលដែលលោកនៅមន្ទីរស្រុកកាលនោះ ថាមន្ទីរស្រុកទទួលបញ្ជាពី តាម៉ុក ទាក់ទងទៅនឹងមនុស្សដែលត្រូវគេចាប់ខ្លួននោះ?

[១៣:៣៩:០៤]

**លោក សាន់ ឡូន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ សូមបញ្ជាក់សំណួរហ្នឹងម្តងទៀត។

**ស៖** បាទ លោកបានឆ្លើយទៅអ្នកស៊ើបអង្កេតថា បញ្ជាក្នុងការចាប់អ្នកទោសដែលមានទោសធ្ងន់នោះ គឺចេញមកពី ដល់ថ្នាក់ស្រុកហ្នឹង គឺចេញមកពី តាម៉ុក។ តើលោកបានដឹងថាបែបនោះ ដឹង

ដោយរបៀបណា?

**ឆ៖** រឿងនេះខ្ញុំអត់ៗទាន់ដឹងដែរ រឿងទោសធ្ងន់ ទោសស្រាល។

**ស៖** ខ្ញុំសូមដកស្រង់ចំណុចមួយទៀត ដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតទៅចម្លើយ ៨៨៧ “សំណួរ៖ យើងបាននិយាយអំពីការដែល តាម៉ុក ចេញបញ្ជាឲ្យចាប់អ្នកទោសធ្ងន់ តើលោកដឹងថាមានបញ្ជាដោយរបៀបណា? ចម្លើយ៖ បញ្ជានេះ តាម៉ុក បញ្ជាឲ្យចាប់អ្នកទោសថ្មី គាត់បញ្ជាតាមរយៈតំបន់មកស្រុក ស្រុកមកឃុំ។ ដូច្នេះចំពោះខ្ញុំដែលធ្វើការនៅស្រុក អាចដឹងតាមរយៈហ្នឹង។” ចប់សេចក្ដីដកស្រង់។ តើខ្លឹមសារនេះរំឭកការចងចាំរបស់លោកទេ? អ្វីដែលខ្ញុំចង់ឲ្យលោកព្យាយាមចងចាំហ្នឹងគឺថា តើលោកបានដឹងដូចម្ដេច ថាបញ្ជានោះចេញមកពី តាម៉ុក? ជាបញ្ជាជាលាយលក្ខណ៍អក្សរ ឬក៏ជាការណែនាំផ្ទាល់មាត់ពី តាម៉ុក ទៅបុគ្គលណាមុននឹងមកដល់ស្រុក? តើលោកបានដឹងពីបញ្ជានេះដោយវិធីណា?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ក្ដាប់មិនបាន។ អត់ដឹងថា តាម៉ុក ហ្នឹងបញ្ជាតាមវិធីណា ខ្ញុំអត់ដឹង។

[១៣:៤១:៣៨]

**ស៖** លោកបានជម្រាបតុលាការព្រឹកមិញនេះថា បញ្ជាមកពី តាម៉ុក បញ្ជូនតាមនីរសារដែលធ្វើការឲ្យគាត់ឈ្មោះ ទូច។ តើជាបញ្ជានោះជាបញ្ជាលាយលក្ខណ៍អក្សរដែលនីរសារហ្នឹងបញ្ជូនមក ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** បាទ ការបញ្ជូននេះគឺជួនកាលនីរសារឈ្មោះ ទូច ហ្នឹងមកផ្ទាល់ក៏មាន ឬក៏ផ្ញើសំបុត្រក៏មាន ក៏បានដែរ។

**ស៖** នៅពេលដែលគាត់មក ថាតើគាត់ប្រគល់បទបញ្ជា ឬក៏បញ្ជាហ្នឹងទៅឲ្យអ្នកណា?

**ឆ៖** បាទ សូមសួរម្ដងទៀត។

**ស៖** នៅពេលដែល ទូច មកមន្ទីរស្រុក តើគាត់យកបទបញ្ជាហ្នឹងទៅឲ្យអ្នកណា បើជាបទបញ្ជាជាសំបុត្រ ឬក៏ផ្ទាល់មាត់ហ្នឹង គាត់ប្រគល់ទៅឲ្យអ្នកណានៅមន្ទីរស្រុកហ្នឹង?

**ឆ៖** ប្រគល់ឲ្យលេខាស្រុក ហើយគាត់មកហ្នឹង យកមកប្រគល់ឲ្យខាងលេខាស្រុក។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងត្រឡប់មកហេតុការណ៍មួយដែលយើងនិយាយព្រឹកមិញនេះ ហើយជាមួយនឹងមេធាវីការពារ ហើយនិងខ្ញុំផងដែរ គឺរយៈពេល៤ថ្ងៃដែលលោកបានចូលរួមក្នុងការដឹកមនុស្ស។ នៅក្នុងបទសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត នៅពេលដែលយើងបាន

ពិភាក្សាព្រឹកមិញនេះ គឺថាពីរបីទំព័រខាងដើម -- ៣០ទំព័រដំបូង លោកហាក់ដូចជាមិនចងចាំទេ ប៉ុន្តែមកដល់ពាក់កណ្ដាលនៃបទសម្ភាសន៍នោះ គឺបានអានចម្លើយរបស់សាក្សីផ្សេងទៀត ដូចជា ឯក ហឿន ដែលធ្វើការនៅមន្ទីរស្រុកផងដែរនោះ។ ហើយគេសួរលោកអំពីបញ្ហានោះ នេះជាបទសម្ភាសន៍របស់លោកនៅក្នុង E3 នៅត្រង់សំណួរចម្លើយ៤៥៤ ដែលសំណួរសួរទៅលោក លោកបានអានសេចក្ដីដកស្រង់នេះ អំពីសក្ខីកម្មរបស់ អ៊ុល ហឿន។ “សំណួរ៖ តើលោកៗធ្លាប់ឮការចាប់ខ្លួន និងបញ្ជូនជនជាតិវៀតណាមទៅក្រាំងតាចាន់ដែរឬទេ? ឆ្លើយ៖ ត្រូវធ្វើការបោសសម្អាតជនជាតិវៀតណាមឱ្យអស់ពីភូមិនិងប្រទេស។ សំណួរ៖ តើជនជាតិវៀតណាមប៉ុន្មាននៅក្នុងស្រុកត្រាំកក់? ឆ្លើយ៖ ឈ្មោះ ឡូន ហៅមួយ ដែលជាប្អូនប្រុសថ្លៃរបស់ តាម៉ុក រស់នៅក្នុងឃុំជាងទង គឺជាអ្នកប្រមូលជនជាតិវៀតណាមទាំងអស់នោះ ហើយយកទៅសម្លាប់។ ឡូន បានប្រមូលជនជាតិវៀតណាមពីឃុំអង្គតាសោម, លាយបូរ, ពពេល ហើយនិងស្រែរនោង។ ខ្ញុំមិនដឹងថា មានជនជាតិវៀតណាមប៉ុន្មាននាក់ទេ នៅក្នុងស្រុកត្រាំកក់។ ខ្ញុំគ្រាន់តែដឹងថា ជនជាតិវៀតណាមក្នុងឃុំទាំងបួនខាងលើប៉ុណ្ណោះ។ ឡូន បានប្រាប់ខ្ញុំថា គាត់បានយកឡានធំវែងទៅដឹកជនជាតិវៀតណាម ៩.០០០គ្រួសារពីឃុំទាំងបួននេះ។” ចប់សេចក្ដីដកស្រង់។

[១៣:៤៥:៣៧]

ហើយបន្ទាប់គេអានសេចក្ដីដកស្រង់ជូនលោកស្ដាប់ហើយ អ្នកអង្កេតនោះសួរលោកថា៖ “តើលោកបានធ្វើ ដូចម្ដេច -- លោកយល់ដូចម្ដេចចំពោះសេចក្ដីដកស្រង់នេះ? ហើយលោកនិយាយថា៖ ចំពោះការដឹកមនុស្សនេះ ខ្ញុំមិនដឹងម៉េចទេ។ អ្នកធំគេប្រើខ្ញុំចេះតែទៅហើយ។ គេប្រើ ខ្ញុំធ្វើតាមគេ។” ចប់សេចក្ដីដកស្រង់។

ហេតុអ្វីបានលោកមានបញ្ហាមិនចងចាំបញ្ហាជាច្រើននៅក្នុងពេលសម្ភាស? ហេតុអ្វីក៏លោកមិនបានចងចាំពីហេតុការណ៍ដែលលោកបានដឹកមនុស្សអស់រយៈពេល៤ថ្ងៃហើយ ពេលដែលគេសួរលោក លោកមិនចាំ លោកមានបញ្ហាមិនចាំទាល់តែមានគេអានចម្លើយអ្នកផ្សេងទៅ បានលោកនឹកឃើញ? ហេតុអ្វីបានជាអ៊ីចឹង?

**ឆ៖** ពីខាងដើម ខ្ញុំបានឆ្លើយសំណួរដែលលោកបានសួរខ្ញុំថា ដឹកកម្លាំងប្រជាជននៅតាមឃុំនេះ ខ្ញុំឆ្លើយជូនរួចស្រេចហើយ។ ប៉ុន្តែចំនួនមនុស្សប៉ុន្មានរយៗ ខ្ញុំភ្លាប់មិនបានដែរ។

**ស៖** ព្រឹកមិញនេះ លោកនិយាយថា លោកបានយកមនុស្សពី ដែលលោកប្រមូលមកពីឃុំនានា យកទៅដាក់មន្ទីរស្រុក ហើយប្រធានឈ្លបស្រុកជាអ្នកទទួល។ ពេលដែលប្រធានឈ្លបមកទទួលមនុស្ស

ទាំងនោះ គាត់មកតែម្នាក់ឯង ឬក៏មានសមាជិកកងឈ្លបស្រុកមកជាមួយគាត់ដែរ នៅពេលដែលលោកប្រគល់មនុស្សនោះទៅឲ្យគេ?

**ឆ៖** បើកឡានមកម្នាក់ឯង។

[១៣:៤៨:១៥]

**ស៖** ខ្ញុំមិនសួរពីលោកទេ គឺសួរពីប្រធានឈ្លប តើមានសមាជិកឈ្លបជាមួយគាត់មកជាមួយគាត់ទេ ពេលដែលគាត់មកទទួលមនុស្សពីលោកហ្នឹងបាទ?

**ឆ៖** បាទ មានតើ! មាននីរសាររបស់ប្រធានឈ្លបហ្នឹង។

**ស៖** ខ្ញុំបានសួរលោកពីព្រឹកមិញនេះ អំពីឈ្មោះប្រធានឈ្លប ហើយលោកមិនអាចចងចាំ ពេលខ្ញុំសួរដំបូង។ តើលោកចាំឈ្មោះមនុស្សម្នាក់ ចាំមនុស្សម្នាក់ឈ្មោះថា យន ទេ?

**ឆ៖** យន អត់ៗស្គាល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមទោសដែលខ្ញុំរំខាន។ លោកព្រះរាជអាជ្ញា សូមលោកសួរឲ្យគាត់ឆ្លើយម្ដងទៀត នូវសំណួរមុនអម្បាញ់មិញនេះ ពីព្រោះថាចម្លើយហ្នឹង មិនត្រូវបានបកប្រែទាំងស្រុងជាភាសាបារាំងទេ។ គឺសំណួរដែលសួរថា តើប្រធានឈ្លបហ្នឹងមកហ្នឹង មកតែម្នាក់ឯង ឬក៏មកជាមួយឈ្លបផ្សេងទៀតនោះ។ ពេលនោះសាក្សីគាត់ឆ្លើយ ក៏ប៉ុន្តែបកជាបារាំងទៅ វាមិនបានពេញលេញទេ មិនចប់ទេ។

[១៣:៥០:១០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកចៅក្រម ឡាវែន៍។ ខ្ញុំសួរលោកសាក្សីម្ដងទៀត ខ្ញុំសួរខុសពីសំណួរខាងដើមបន្តិច។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលលោកបានដឹកមនុស្សចេញពីឃុំយកទៅឲ្យឈ្លបស្រុក តើឈ្លបស្រុកកាលហ្នឹងមានប៉ុន្មាននាក់ដែលមកទទួលមនុស្សដែលលោកយកទៅប្រគល់ឲ្យនោះ? ខ្ញុំសួរថាតើមានឈ្លបស្រុកហ្នឹងប៉ុន្មាននាក់មកទទួលមនុស្សដែលលោកដឹកទៅ ទៅឲ្យ?

**លោក សាន់ ឡាន៖**

**ឆ៖** សុំឆ្លើយសំណួរហ្នឹង គឺប្រធានឈ្លបស្រុកដែលបានមកទទួលមនុស្សនោះ គឺមានចំនួនប្រហែលមួយក្រុម មានកម្លាំងរបស់គាត់ ប្រហែលមួយក្រុម ឬនដប់នាក់អីហ្នឹង។

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅពេលនេះសុំអនុញ្ញាតបង្ហាញសាក្សីអំពីឯកសារចេញមកពីស្រុកត្រាំកក់ គឺឯកសារ E3/2435ៗ ជារបាយការណ៍មកពីឃុំអង្គតាសោម ពាក់ព័ន្ធទៅនឹងជនជាតិវៀតណាម ហើយនិងខ្មែរក្រោម ដែលខ្ញុំសុំសួរទៅសាក្សីអំពីរបាយការណ៍នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៣:៥១:០៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារដែលខ្ញុំជូនទៅលោកនោះ គឺជាលិខិតមកពីឃុំអង្គតាសោម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧។ នៅខាងមុខនៃឯកសារដែលលោកបានឃើញនេះ សួរសំណួរទាក់ទងទៅនឹងការចុះឈ្មោះខ្មែរក្រោម "ធ្វើបញ្ជីជនកម្ពុជាក្រោម" ហើយនិង តើត្រូវធ្វើដូចម្ដេចអំពីអ្នកដែលរៀបការចម្រុះជាតិសាសន៍ ដែលអ្នករៀបការប្រពន្ធជាយួន ហើយដែលអ្នកខ្លះដែលយួនជាប្ដី រៀបការជាមួយប្រពន្ធខ្មែរ។ នៅក្នុងវាក្យខណ្ឌទី២ និយាយថា៖ "ប្រសិនបើយួនទាំងអស់ យើងនឹងបញ្ជូនពួកគេទៅអង្គការ"។ ហើយប្រសិនបើលោកមើលទៅខាងក្រោយនៃឯកសារនេះ មានកំណត់សម្គាល់មួយដែលបញ្ជាក់ថា៖ "បញ្ជាក់បន្ថែមចំពោះអ្នកមានបណ្ដាស័ក្តិ២មួយ ឬ១ យើងត្រូវទាក់ទងមិត្ត យន ជាយោធាស្រុកយកល្ងាចនេះហើយ យកចេញល្ងាចនេះហើយ"។ ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងរបាយការណ៍នេះ។ ពាក្យដែលហៅថា "សមមិត្តយន" ជាយោធាស្រុក នៅក្នុងទំព័រខាងក្រោយនៃឯកសារនេះ តើអាចរំឭកឲ្យលោកនឹកឃើញទេ ថាតើឈ្មោះប្រធានយោធាស្រុកហ្នឹងឈ្មោះអី? តើលោកនៅចាំសមមិត្តយន នេះទេ?

**លោក សាន់ ឡួន៖**

**ឆ៖** ឈ្មោះអីទេ ភ្លេចទៅហើយ យន មិនដឹង អីមិនដឹង។ បាទ ខ្ញុំភ្លេចមែន។

[១៣:៥៤:៣៨]

**ស៖** ហើយសំបុត្រនេះមកពីអង្គតាសោម គឺចុះថ្ងៃទី២៦ មេសា ឆ្នាំ១៩៧៦។ ក្នុងរយៈពេលពីរអាទិត្យបន្ទាប់ពីនោះមក គឺមានសេចក្ដីដកស្រង់មកពីឃុំប្រាំមួយ ដែលចុះបញ្ជីក្នុងឃុំទាំងអស់នោះ គឺថាក្រុមគ្រួសារទាំងឡាយ ជាពិសេសគឺខ្មែរក្រោម កម្ពុជាក្រោម ដែលរាប់បញ្ចូលឃុំមួយចំនួន ដែលលោកបានកំណត់ថា លោកទៅដឹកមនុស្សចេញពីឃុំទាំងនោះផងដែរ។ ហើយខ្ញុំនឹងយោងទៅរក គឺថាលោកបានប្រាប់តុលាការព្រឹកមិញនេះ ថាលោកបានទៅអង្គតាសោម គឺឯកសារ E3/2049 ហើយនិង E3/4082 គឺជាបញ្ជីឈ្មោះមកពីអង្គតាសោម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ គឺបានបញ្ជាក់ថា មានខ្មែរក្រោម២៦គ្រួសារ។ ហើយលោកបញ្ជាក់ថា លោកបានទៅយកមនុស្សមកពីឃុំពពេលផងដែរ គឺ E3/2262 គឺជាឯកសារដែលថា បញ្ជាក់ថាមានខ្មែរក្រោម៦៤គ្រួសារ ត្រូវបានប្រមូល។ ហើយលោកក៏បាននិយាយពីឃុំគុស ហើយរបាយការណ៍ចុះថ្ងៃទី២៩ មេសា ឆ្នាំ១៩៧៧ ពីឃុំនោះ គឺឯកសារ E3/2438 បានកំណត់ថា មានខ្មែរក្រោម៣៥គ្រួសារ នៅក្នុងបញ្ជី។ លោកក៏បានបញ្ជាក់ពីឃុំស្រែរនោង។ ហើយយើងមានបញ្ជីចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ មាន៣៧គ្រួសារចេញពីនោះ គឺថា E3/4083។

ខ្ញុំសួរលោកអំពីរឿងនេះ លោកសាក្សី ដោយផ្អែកលើមូលហេតុពីរ។ ទី១ រយៈពេលដែល នៃការធ្វើបញ្ជីនេះ ហើយនិងពេលវេលានៃការធ្វើឯកសារនេះ គឺពីខែមេសា រហូតដល់ឧសភា ឆ្នាំ១៩៧៧។ តើព័ត៌មាននេះ ធ្វើឲ្យលោកនឹកឃើញពីការចងចាំរបស់លោកដែរទេ អំពីរយៈពេលដែលលោកបានចូលរួមក្នុងការដឹកជញ្ជូនមនុស្សចេញពីឃុំនានានោះ ទៅមន្ទីរស្រុក? ថាតើអាចនៅក្នុងខែមេសា ឬឧសភា ឆ្នាំ១៩៧៧ ដែរឬទេ?

[១៣:៥៧:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់នឹងសំណួរនេះ។ នេះជាសំណួរនាំមុខខ្លាំងណាស់ យកឯកសារទៅឲ្យសាក្សី ហើយអានព័ត៌មានជាច្រើនឲ្យគាត់ស្ដាប់។ ហើយបន្ទាប់មកសហព្រះរាជអាជ្ញាយកព័ត៌មានទាំងអស់ទៅបញ្ចុកមាត់សាក្សី ហើយៗជំរុញឲ្យគាត់ឆ្លើយថា តើកាលបរិច្ឆេទហ្នឹង ឬមិនហ្នឹង ការចូលរួមដឹកជញ្ជូនមនុស្សហ្នឹង។ ពេលដែលគាត់និយាយហ្នឹង សាក្សីមិននិយាយថាដឹកខ្មែរក្រោមឯណា មិននិយាយបែបនោះទេ។ អ៊ីចឹងគឺថា សូមបដិសេធព្រោះសំណួរនេះ នាំមុខខ្លាំងណាស់។

**លោក ឌេល លីសាក់៖**

លោកប្រធានយើងបានសួរសំណួរនោះបើកចំហយ៉ាងច្រើន។ សាក្សីអាចមានភាពអល់អែក ឬក៏លាក់លៀម ឬក៏មិនច្បាស់ដោយខ្លួនគាត់។ ហើយគាត់ក៏បញ្ជាក់ថា គាត់បានដឹកមនុស្សចេញពីឃុំទាំងអស់នោះទៅស្រុក។ ហើយជាភាពសមស្របដែលខ្ញុំអាចសួរសំណួរហ្នឹង ដើម្បីបញ្ជាក់ពីភាពទាក់ទងគ្នាពីពេលវេលា ហើយនិងកាលបរិច្ឆេទ ហើយនិងមនុស្ស ហើយប្រភេទមនុស្សដែលស្ថិតនៅក្នុងអង្គហេតុនេះលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៩:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា លោក វិចទ័រ កូប៉េ ចំពោះសំណួរនេះៗ ដែលសហព្រះរាជអាជ្ញារងអន្តរជាតិតាំងសំណួរចំពោះសាក្សីសមស្របហើយ ព្រោះគាត់បានសួរបើកពាក់ព័ន្ធនឹងបញ្ហានេះ រួចហើយ ទើបគាត់បានបញ្ជាក់លើភ័ស្តុតាងដែលវាមាននៅក្នុងឯកសារ ជាមូលដ្ឋាន សម្រាប់បញ្ជាក់បន្ថែមដូចសព្វដងដែរ។

សាក្សីឆ្លើយតបនឹងសំណួរ បើសិនបើសាក្សីអាចស្ដាប់បាន ហើយបើស្ដាប់មិនទាន់ទេ គឺសុំឲ្យសហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹង រៀបចំសំណួរ តាំងសាជាថ្មីទៀត សំណួរចុងក្រោយរបស់ខ្លួន។

សាក្សីអាចឆ្លើយសំណួរហ្នឹងបានទេ?

រៀបចំសំណួរសាជាថ្មីម្ដងទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារមួយចំនួនដែលខ្ញុំបានអានជូនលោកស្ដាប់ គឺបញ្ជីមកពីឃុំនានា ដែលរាប់បញ្ចូលទាំងឃុំដែលលោកបានបញ្ជាក់ថា លោកបានទៅដឹកមនុស្សចេញពីឃុំទាំងនោះផង។ ហើយបញ្ជីឈ្មោះចេញមកពីឃុំមួយៗនោះ បានន័យថាម្ដៃ – មានគ្រួសារ២៦ខ្មែរក្រោម ហើយនិងទៅដល់៤០ជាដើមហ្នឹង គឺថាកាលបរិច្ឆេទនៃបញ្ជីទាំងអស់នេះ គឺមានចុះកាលបរិច្ឆេទពីខែមេសា ដល់ខែឧសភា ១៩៧៧។ អ៊ីចឹងអ្វីដែលខ្ញុំសួរទៅលោកនោះ ថានៅពេលដែលលោកទទួលការចាត់តាំងឲ្យទៅដឹកមនុស្ស

ចេញពីឃុំទាំងអស់ហ្នឹង តើក្នុងខែឧសភា ឬក៏ក្នុងខែមេសា?

[១៤:០១:២២]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ម្ដងទៀតដដែលហើយ។ សហព្រះរាជអាជ្ញា សួរសំណួរនាំមុខហ្នឹងគឺច្បាស់ក្រឡែត គឺថាសាក្សីឆ្លើយព្រឹកនេះដោយខ្លួនឯង គឺថាគាត់ជឿថានៅដើមនៃរបបកម្ពុជាប្រជាធិបតេយ្យគឺថាអាចនឹងដើមឆ្នាំ១៩៧៥។ អ៊ីចឹងគឺថា ហើយការដែលផ្ដល់កាលបរិច្ឆេទជាខែពីរនេះទៅសាក្សី គឺជាសំណួរនាំមុខ។

**លោក ឌេល លីសាក់៖**

មិនមែននាំមុខទេ គឺថាមិនមែនជាពាក្យខ្ញុំទេ កាលបរិច្ឆេទជាឈ្មោះខែនេះ គឺយកមកពីឯកសារដែលជារបាយការណ៍។ ហើយសាក្សីក៏បានបញ្ជាក់ដោយខ្លួនឯងផងដែរថា គាត់មានភ័ន្តច្រឡំអំពីកាលបរិច្ឆេទហ្នឹង គាត់មិនច្បាស់។ ដូច្នេះហើយសហព្រះរាជអាជ្ញាមានសិទ្ធិក្នុងការសួរអំពីភ័ស្តុតាងនេះដើម្បីឲ្យគាត់បញ្ជាក់ថាជឿមិនជឿ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចបដិសេធរួចហើយ ហើយឲ្យសួរសំណួរនេះដដែលទេ បញ្ហាដដែលទេមិនមែនបញ្ហាថ្មីទេ។ តទៀត!

យ៉ាងម៉េចទៅ មេធាវី គង់ សំអុន?

**លោក គង់ សំអុន៖**

បាទ មិនមែនជាការជំទាស់ទេ លោកប្រធាន។ សូមឲ្យសហព្រះរាជអាជ្ញារងអន្តរជាតិបញ្ជាក់ពីកាលបរិច្ឆេទតាមការដកស្រង់របស់លោកអម្បាញ់មិញនេះ នៅក្នុងឯកសារហ្នឹង នៅត្រង់កន្លែងណាឲ្យច្បាស់ផងបាទ។

[១៤:០៣:០១]

**លោក ឌេល លីសាក់៖**

ខ្ញុំបានបញ្ជាក់ហើយ ខ្ញុំសូមបញ្ជាក់ឡើងវិញ ដើម្បីលោក លោកមេធាវី គង់ សំអុន គឺ E3/2049 ហើយនិង E3/4082 គឺជាបញ្ជីចុះថ្ងៃទី៣០ មេសា ឆ្នាំ១៩៧៧ មកពីឃុំអង្គតាសោម។ E3/2262 គឺជាបញ្ជីមកពីឃុំពពេល។ E3/2438 បញ្ជីមកពីឃុំគុស ចុះថ្ងៃទី២៩ មេសា ឆ្នាំ១៩៧៧។ E3/4083 ជា

បញ្ជើមកពីឃុំស្រែរនោង ចុះថ្ងៃទី២៧ មេសា ឆ្នាំ១៩៧៧។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួរខ្ញុំជូនលោកសាក្សី ដោយបានឮអំពីឯកសារទាំងអស់នេះ តើធ្វើឱ្យលោកចងចាំទេ ថាតើការចាត់តាំងឲ្យលោកទៅយកមនុស្សចេញពីឃុំទាំងអស់នេះ កើតឡើងនៅក្នុងខែណា ដែលតាមអ្វីដែលខ្ញុំបញ្ជាក់ អានពីខាងដើមនេះ?

**លោក សាន់ ឡូន៖**

**ឆ៖** ការចាត់តាំងឲ្យខ្ញុំទៅដឹកមនុស្សទាំងអស់នេះ ខ្ញុំភ្លេចហើយ ភ្លេចអស់ហើយ មិនដឹងខែណា ថ្ងៃទីប៉ុន្មាន ខែណា អត់ចាំ ភ្លេចអស់ហើយ។ មិនមែនថាខ្ញុំនិយាយមិនការពិតទេ គឺភ្លេចមែន។

**ស៖** តើលោកបានដឹងដែរឬទេ ថាតើមនុស្សដែលលោកបានដឹកទៅមន្ទីរស្រុកហ្នឹង គឺថាជោគវាសនារបស់ពួកគាត់ហ្នឹងដូចម្ដេចដែរ? នៅពេលដែលលោកយកពួកគាត់ទៅដាក់នៅកន្លែងនោះហើយ តើលោកធ្លាប់បានប្រទះឃើញអ្នកណាម្នាក់ក្នុងចំណោមនោះជាថ្មីម្ដងទៀតទេ?

**ឆ៖** ក្នុងរឿងនេះ ខ្ញុំអត់ដែល អត់បានជួបប្រទះមនុស្សនោះសាជាថ្មី អត់ៗចំណាំមនុស្សបាន។

[១៤:០៦:២៦]

**ស៖** អរគុណលោកសាក្សី។ ខ្ញុំត្រឡប់មកប្រធានបទចុងក្រោយដែលមេធាវីការពារក្ដីសួរលោកព្រឹកមិញ គឺប្រធានបទនិយាយអំពីការប្រព្រឹត្តទៅលើទាហាន និងមន្ត្រី អតីតមន្ត្រីលន់ នល់ នៅក្នុងស្រុករបស់លោក។ តើលោកស្គាល់វត្តមួយនៅត្រាំកក់ ឈ្មោះហៅវត្តចំប៉ាលើក លោកស្គាល់វត្តចំប៉ាលើកនេះទេ?

**ឆ៖** ស្គាល់។

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗឲ្យឮណា! លោក ឡូន ឆ្លើយអំមិញអត់ទាន់ឆ្លើយទេ លោកឆ្លើយទៅក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការផង លោកឆ្លើយទៅវាអត់ឮណា។ ហើយមន្ត្រីរដ្ឋបាលតុលាការមើលទាញសម្រួលក្បាលមីក្រូហ្វូនឲ្យជិតគាត់បន្តិចមើល ព្រោះដូចជាឆ្ងាយបន្តិច។

**លោក សាន់ ឡូន៖**

**ឆ៖** បាទ សូមសួរម្ដងទៀត ភ្លេចហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកស្គាល់វត្តមួយនៅក្នុងស្រុកត្រាំកក់ ហៅឈ្មោះថាវត្តចំប៉ាលើក?

**ឆ៖** បាទ ក្នុងឈ្មោះវត្តនេះ ខ្ញុំអត់ៗដែលស្គាល់ ចំប៉ាលើក។

**ស៖** ខ្ញុំចង់សួរលោកអំពីចម្លើយមួយទៀតដែលសាក្សីដដែលមុននោះដែលឆ្លើយថា លោកក៏បានចូលរួមដឹកជញ្ជូនក្រុមគ្រួសារជនជាតិវៀតណាម កម្មាភិបាល អ៊ុល ហឿន ដែលធ្វើការស្រុកដែរនៅក្នុងបទសម្ភាសន៍ អូ.ស៊ី.អាយ.ជេ គឺE3/9582 ចម្លើយ១១៣៖ “សំណួរ៖ តើលោកដឹងពីការកាប់សម្លាប់ទាហាន ហើយនិងសមាជិកក្រុមគ្រួសារទាហានលន់ នល់ ដែរទេ?--

[១៤:០៨:៥៧]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ! កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបដិសេធចំពោះការប្រើពាក្យថា “កម្មាភិបាល អ៊ុល ហឿន” ព្រោះគាត់ខ្លួនឯងគាត់និយាយថានៅតុលាការនេះ គាត់គ្រាន់តែជាប្រជាជនធម្មតា អ្នកភូមិទេ នៅក្នុងឯកសាររបស់គាត់គឺ E3/9594 ចម្លើយ១៦ គាត់និយាយថា៖ “ខ្ញុំ គេមិនឲ្យខ្ញុំកាន់តំណែងអ្វីទេ គេចោទខ្ញុំថាមាននិន្នាការជាប់ខ្សែ គេមិនប្រើខ្ញុំទេ ពីព្រោះជាប់ខ្សែនយោបាយ។” ការដែលសហព្រះរាជអាជ្ញាហៅគាត់កម្មាភិបាលគឺជាការធ្វើឲ្យសាក្សីរូបនេះភ័ន្តច្រឡំ។

**លោក ឌេល លីសាក់៖**

គឺថាតាមសក្ខីកម្មរបស់គាត់ អ៊ុល ហឿន គាត់ថាគាត់ធ្វើការនៅមន្ទីរស្រុក។ អ៊ីចឹងអ្នកដែលធ្វើការនៅមន្ទីរស្រុកហ្នឹងគឺអ៊ីចឹងហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ក៏ប៉ុន្តែលោកសាក្សី អ៊ុល ហឿន មកពីមន្ទីរស្រុកត្រាំកក់ គាត់ឆ្លើយនៅក្នុង E3/9582 ជាចម្លើយរបស់គាត់ ចម្លើយ១១៣៖ “សួរ៖ តើលោកបានដឹងអ្វីខ្លះអំពីការកាប់សម្លាប់ទាហាន លន់ នល់ ហើយនិងក្រុមគ្រួសារ ហើយនិងជនស៊ីវិលនៅក្នុងខេត្តតាកែវដែរឬទេ? ចម្លើយ៖ នៅពេលនោះខ្មែរក្រហមប្រកាសជ័យជម្នះថា ឈ្នះហើយភ្នំពេញ។ បន្ទាប់មកគេបានជម្លៀសប្រជាជនចេញពីភ្នំពេញ

ទៅដាក់វត្តចំប៉ាលើក ដែលស្ថិតនៅខាងលិចនៃអង្គតាសោម ពីរបីគីឡូម៉ែត្រក្នុងស្រុកត្រាំកក់។ ក្នុងរយៈពេល៧ថ្ងៃ ខ្មែរក្រហមបានឃោសនាដោយស្វែងរកអ្នកដែលធ្លាប់មានបណ្ដាស័ក្តិឱ្យមកចុះឈ្មោះ។ ខ្មែរក្រហមបានប្រមូលផ្តុំអ្នកទាំងអស់ហ្នឹង ហើយយកចេញទៅបាត់។ នេះជាទម្លាប់អនុវត្តទូទៅ ហើយគឺមានរាប់រយរាប់ពាន់នាក់ត្រូវបានបញ្ជូនចេញទៅ រហូតដល់អស់ពួកអ្នកដែលមានបណ្ដាស័ក្តិដូចជា អ្នកសក្តិ១ ឬក៏សក្តិ២ ជាដើម គឺនៅសល់តែប្រជាជនធម្មតាតែប៉ុណ្ណោះ។" ចប់សេចក្ដីដកស្រង់។ តើលោកសាក្សីបាននឹកឃើញ ឬក៏បានដឹងពីហេតុការណ៍អ្វីដែលកើតឡើងនៅវត្តចំប៉ាលើក បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

[១៤:១១:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់លោកប្រធាន គឺថាខ្ញុំបានយោងទៅលើខ្លឹមសារ វគ្គដែលសវនាការសម្ងាត់។ ដូច្នេះសហព្រះរាជអាជ្ញាគឺមិនអាចនឹងយកខ្លឹមសារនេះមកយោងបានទេ ពីព្រោះថា ខ្ញុំបានព្យាយាមធ្វើដូច្នោះ ខ្ញុំបានរងការជំទាស់ ប៉ុន្តែសហព្រះរាជអាជ្ញាហ្នឹងក៏ខ្ញុំជំទាស់ចំពោះសហព្រះរាជអាជ្ញាយកចម្លើយហ្នឹងមកសួរសាក្សីនេះ គឺថា ហើយគាត់ក៏គួរយោងទៅរកបុគ្គលបីនាក់ ដែលជាកម្មាភិបាលបីនាក់គឺនៅស្រុក១៣, ២៣ ផងដែរ ដែលថាគេបញ្ជាក់ថា អតីតទាហានលន់នល់ ចាប់ពីស័ក្តិ៥ចុះទៅហ្នឹង គឺគេមិនឱ្យប៉ះពាល់ទេ។ សាក្សីបីរូបនិយាយស្របៗគ្នាបែបនោះ។ អ៊ីចឹងសហព្រះរាជអាជ្ញាត្រូវតែយោងបែបនេះដែរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន គាត់បានសួរសាក្សីរួចហើយពីរឿងនេះ។ អ៊ីចឹងខ្ញុំជឿថា ពេលលោកមេធាវីការពារក្តី វេនរបស់លោក លោកសួរអ៊ីចឹងទៅ។ អ៊ីចឹងគឺថា ខ្ញុំសួរតែសាក្សីរូបនេះ ហើយខ្ញុំអាន ហើយខ្ញុំចង់បានឱ្យសាក្សីនេះ គាត់មានប្រតិកម្មតបទៅនឹងចម្លើយរបស់សាក្សីផ្សេងទៀតនោះ តែប៉ុណ្ណោះ។

[១៤:១២:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា លោកមេធាវី វ៉ិចទ័រ កូប៉េ ហើយម្យ៉ាងទៀត យើងជម្រាបរួចហើយ ម្តងហើយម្តងទៀតថា ភាគីមិនគប្បីបង្រៀនភាគីដទៃទៀតឱ្យតាំងសំណួរបែបណា បែបណានោះទេ ព្រោះមិនចង់ឱ្យភាគីទាំងអស់យកវេទិកានេះធ្វើជា

សាកលវិទ្យាល័យសម្រាប់បង្រៀនបច្ចេកទេសដល់ភាគីផ្សេងទៀតនោះទេ។ យើងបានប្រាប់ច្រើនដង ហើយ។ ហើយជាវិធីសាស្ត្រ និងជាបច្ចេកទេសរបស់ភាគីពាក់ព័ន្ធរៀងៗខ្លួន នៅក្នុងដំណើរការនេះ ហើយម្យ៉ាងគឺជាភាគីដែលត្រូវបំពេញមុខងារទៅតាមភារកិច្ចរៀងខ្លួន មួយចោទ មួយដោះបន្ទុក។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី តើនេះជួយរំឭកដល់ការចងចាំរបស់លោកទេ? លោកដឹងថាគេប្រមូលមនុស្ស តើលោកដឹងថា គេប្រមូលមនុស្សដាក់នៅវត្តចំប៉ា ហើយទាហាន លន់ នល់ ត្រូវបានបំបែកពីគ្រួសារ ហើយនាំខ្លួនយកចេញទៅបាត់នោះដែរទេ?

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ខ្ញុំអត់បានដឹង ឆ្លើយមិនកើត។

**ស៖** ខ្ញុំសូមបង្ហាញឯកសារមួយពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះខ្មែរក្រោម ឬក៏ប្រជាជនយួន នៅខែមេសា ១៩៧៧។ លោកប្រធាន ខ្ញុំសុំការអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារពីស្រុកត្រាំកក់ ទាក់ទងទៅនឹងប្រជាជនចេញពីរបប លន់ នល់ គឺឯកសារ E3/2048១។ ជាពិសេសនៅថ្ងៃទី៣០ មេសា ១៩៧៧ ដែលមានរបាយការណ៍ចេញពីឃុំជាងទង ហើយនៅថ្ងៃទី២៨ មេសា ១៩៧៧ មានរបាយ-ការណ៍ចេញពីឃុំតាភេម។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញឯកសារនេះជូនសាក្សី។

[១៤:១៥:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី គឺថាឥឡូវនេះលោកមានឯកសារពីរនៅក្នុងដៃ។ ឯកសារទី១ គឺរបាយ-ការណ៍មកពីឃុំជាងទង ចុះថ្ងៃទី៣០ មេសា ១៩៧៧ នេះគឺឯកសារ E3/2048 ខ្មែរ ERN 00079089, អង់គ្លេស 00276562 ដល់ 63, បារាំង 00611659។ នេះគឺជារបាយការណ៍មកពីឃុំជាងទង ដែលសរសេរថា សូមដកស្រង់៖ “ក្រោយពីបានទទួលការណែនាំជាបន្តបន្ទាប់ពីអង្គការ អំពីការប្រុងប្រយ័ត្នទៅលើខ្មាំង ហើយនិងការរែកមុខរកខ្មាំង យើងបានតាមដាន និងពិនិត្យរកឃើញមនុស្សមួយចំនួនដូច

តទៅ ហើយនិងអតីតទាហាន នល់ នល់ មួយទៀតគឺរកឃើញមួយ គឺស័ក្តិ៤។" ឯកសារទី២ គឺ ERN គឺឯកសារ E3/2048ដែរ ចុះថ្ងៃទី២៨ មេសា ១៩៧៧ ពីឃុំតាភេម ដែលសរសេរថា៖ "យើងសមាជិកសាខាឃុំតាភេម បានរកឃើញទាហានដែលមានបុណ្យស័ក្តិ។ ក្រោយពីទទួលបានការណែនាំពីបក្សរួចមក ហើយបានពិនិត្យយ៉ាងដិតដល់ ហើយគឺថានៅមានមន្ត្រីទាហាន ទាហានដែលមានបុណ្យស័ក្តិខ្ពស់ហ្នឹងប្រាំមួយនាក់ទៀត គឺដែលមានឋានៈស័ក្តិ៤ -- ស័ក្តិ១ បាទស័ក្តិ១។"

សំណួររបស់ខ្ញុំសួរអ៊ីចេះលោក ដើម្បីរំឭកការចងចាំរបស់លោក នៅក្នុងអំឡុងពេលនោះ ក៏មានបញ្ជីខ្មែរក្រោមផងដែរ តើលោកដឹងថា ថ្នាក់ស្រុកបានឲ្យថ្នាក់ឃុំកំណត់អត្តសញ្ញាណ និងចាប់អតីតទាហានលន់ នល់ ដែលមានបុណ្យស័ក្តិនោះដែរទេ?

[១៥:១៨:១៣]

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ដែលរឿងនេះខ្ញុំអត់បានដឹង អត់បានយល់។ អត់ដឹងមែន។

**ស៖** តើលោកដឹងទេថា មនុស្សដែលលោកដឹកជញ្ជូនទៅឲ្យខាងឈ្លបឃុំ លោកដឹងថាអ្នកទាំងនោះមានជាប់ពាក់ព័ន្ធទៅនឹងរបបលន់ នល់ នោះដែរទេ?

**ឆ៖** អត់ទេ ខ្ញុំអត់បានដឹង អត់បានយល់ អត់បានគិតដល់ហ្នឹង។

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សហការីរបស់ខ្ញុំមានសំណួរខ្លះបន្ថែមទៀត ហើយខាងសហមេធាវីនាំមុខប្រាប់មកថា គាត់អត់មានសំណួរទេ។

**លោក សេង លាង៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន ហើយនិងលោក លោកស្រីចៅក្រម ហើយសូមគោរពសាក្សី។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ។ ថ្ងៃនេះ ដោយសារពេលវេលាអស់ហើយ ខ្ញុំមានពីរបីសំណួរទេ ចង់ឲ្យលោកជួយបញ្ជាក់។

**សួរដោយលោក សេង លាង៖**

**ស៖** សំណួរដំបូងរបស់ខ្ញុំហ្នឹង កាលពីព្រឹកមិញ ដូចជាខ្ញុំស្តាប់ ពេលដែលលោកឆ្លើយសំណួរទៅនឹងលោកមេធាវី កូប៉េ លោកបានបញ្ជាក់ថា លោកធ្លាប់ធ្វើជាមេភូមិប្រគាប នៅចន្លោះឆ្នាំ១៩៧១ ដល់៧២។ តើការលើកឡើងរបស់ខ្ញុំត្រឹមត្រូវដែរឬទេ?

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

[១៤:២០:៣២]

**ស៖** តើលោកអាចប្រាប់បានទេ ថាតើនៅក្នុងអំឡុងឆ្នាំ៧១, ៧២ហ្នឹង តើភូមិប្រគាបរបស់លោកហ្នឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ឬក៏អាចនិយាយម៉្យាងទៀតថាស្ថិតនៅក្នុងការគ្រប់គ្រងរបស់កងទ័ពរំដោះ ឬក៏យ៉ាងណា?

**ឆ៖** កាលណោះគឺ ការរស់នៅក្រោមរបស់ខ្មែរក្រហម។

**ស៖** តើនរណាគេជាអ្នកតែងតាំងឲ្យលោកធ្វើជាមេឃុំនៅពេលហ្នឹង -- មេភូមិនៅពេលហ្នឹង?

**ឆ៖** កាលណោះ គឺការឲ្យធ្វើមេ ប្រធានភូមិនេះគឺ របស់ខាងឃុំ របស់ឃុំដែលឲ្យខ្ញុំធ្វើ។

**ស៖** អរគុណលោកសាក្សី។ តើលោកសាក្សីអាចស្តាប់បានទេថា លោកអាចដឹងប្រហែលចំនួនប្រជាជននៅក្នុងភូមិរបស់លោកកាលហ្នឹង ថាប្រហែលមាន ប្រហែលជាប៉ុន្មានគ្រួសារដែរ?

**ឆ៖** ប្រជាជននៅក្នុងភូមិនោះ ប្រហែលជា១៥០គ្រួសារប៉ុណ្ណោះ។

**ស៖** តើនៅក្នុងចំណោមប្រជាជនទាំងអស់ហ្នឹង តើមានទេ មានជនជាតិវៀតណាមទេរស់នៅក្នុងភូមិរបស់លោក ឬនៅក្នុងឃុំ ឬក៏ក្នុងស្រុករបស់លោកហ្នឹង មានជនជាតិវៀតណាមរស់នៅដែរទេ?

**ឆ៖** ដឹងមានអត់ទេ ខ្ញុំក្តាប់មិនបានដែរ។

**ស៖** នៅពេលដែលលោកធ្វើជាមេភូមិហ្នឹង តើខ្មែរក្រហមមានឲ្យធ្វើការប្រមូលផ្តុំជនជាតិវៀត-ណាមដែរឬទេពេលហ្នឹង?

**ឆ៖** បាទ ពេលនោះ អត់មានប្រមូលផ្តុំជនជាតិវៀតណាមអីឲ្យនៅដោយឡែកគ្នា អត់ទេ អត់ទាន់គិតដល់ហ្នឹងទេ។

[១៤:២៣:៤៥]

**ស៖** ចុះក្រោយមកប្រហែលជាក្នុងពេលណា ទើប -- ក្រោយមកមានការឲ្យប្រមូលផ្តុំប្រជាជនវៀតណាមឬទេ ពេលក្រោយមក?

**ឆ៖** ឆ្នាំណាដែល ខ្ញុំ ប្រហែលខ្ទង់៧៥ – ១៩៧៥ ឲ្យខ្ញុំដឹកកម្លាំងប្រជាជនៗវៀតណាមហ្នឹងហ្នឹងបានដឹងនៅពេលនោះ។

**ស៖** អ៊ីចឹងគោលនយោបាយខ្មែរក្រហមឲ្យប្រមូលប្រជាជនវៀតណាម គឺនៅប្រហែលជា

ក្រោយឆ្នាំ៧៥ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ហ្នឹងៗ។

**ស៖** លោកសាក្សី ពីព្រឹកមិញពេលដែលលោកឆ្លើយនឹងសំណួររបស់លោក កូប៉េ ប្រហែលជាលោក តាមខ្ញុំស្ដាប់បានលោកធ្លាប់បាននិយាយថា មានពេលមួយនោះ គឺលោកធ្លាប់ធ្វើជានីរសារឲ្យឃុំ ហើយក្រោយមកទៀតលោកទៅធ្វើជានីរសារឲ្យស្រុក។ តើការលើកឡើងរបស់ខ្ញុំត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក សាន់ ឡូន៖**

**ឆ៖** កាលនោះខ្ញុំធ្វើនីរសារស្រុក គឺខ្ញុំសូមឯកភាព ស្របតាមពាក្យលោក។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសួរថាតើលោកធ្លាប់ធ្វើជានីរសារឲ្យឃុំ ហើយក្រោយមកធ្លាប់ធ្វើនីរសារឲ្យស្រុក តើត្រឹមត្រូវដែរទេ? តើលោកធ្លាប់ធ្វើជានីរសារនៅឃុំណាដែរលោក អាចប្រាប់បានទេ? ហើយចន្លោះពីពេលណាដល់ពេលណា?

[១៤:២៥:៥៩]

**ឆ៖** អត់ទេ ខ្ញុំអត់បានធ្វើនីរសារអីក្រៅពីស្រុកទេ គឺធ្វើនីរសារជាប់ជាមួយស្រុក ខាងឃុំ អត់ទេ។

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ដោយសារពេលវេលាអស់ហើយ ខ្ញុំសូមជូនវេទិកាជូនទៅខាងមេធាវីការពារក្ដី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តនេះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន ខ្ញុំមានសំណួរខ្លីទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សីកាលពីព្រឹកមិញហ្នឹង លោកនិយាយអំពីឈ្មោះ ភី ដែលធ្វើការនៅថ្នាក់ស្រុក ហើយគាត់ជាប្រធានមន្ទីរអប់រំ។ តើលោកអាចជម្រាបបានទេឈ្មោះ ភី នេះគឺជា ភី ប៉ុងពៀចហ្នឹងមែនទេ គេហៅគាត់ថា ភី ប៉ុងពៀចហ្នឹង មែនទេ?

[១៤:២៧:០៨]

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ភី ប៉ុងពៀច ហ្នឹង។

**ស៖** សំណួរទី២ ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការដឹកជញ្ជូនប្រជាជន។ លោកអាចជម្រាបជូនបានទេ ប្រជាជនដែលត្រូវបានដឹកនៅក្នុងឡានហ្នឹង គេដាក់ខ្នោះ គេចងទេ គេមានធ្វើយ៉ាងម៉េចចំពោះអ្នកទាំងអស់ហ្នឹង?

**ឆ៖** បាទ ដែលការដឹកប្រជាជននេះ អត់មានចង ដាក់ខ្នោះដាក់អីទេ គឺឲ្យគាត់ឡើងឡានតែម្តងឡើងជិះឡាន។

**ស៖** ខ្ញុំយល់ថា គេធ្វើបញ្ជីឈ្មោះមនុស្សដែលត្រូវដឹកជញ្ជូនចេញទៅ។ ដូច្នេះលោកផ្ទាល់ ស្រុកមានបានប្រគល់បញ្ជីឈ្មោះនោះមកឲ្យលោកទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំដឹងថា ខ្ញុំមិនអាចជំទាស់ទៅនឹងសំណួររបស់ចៅក្រមបានទេ។ ក៏ប៉ុន្តែខ្ញុំមានសំណួរ ព្រោះថាខ្ញុំមិនយល់ តើពាក្យថា "បញ្ជី" ហ្នឹងចេញមកពីណាលោកចៅក្រម? ខ្ញុំមិនឮពាក្យនេះចេញពីសាក្សីទេ សហព្រះរាជអាជ្ញា គាត់លើកពីបញ្ជីដែរ ប៉ុន្តែវាមិនមែនចេញមកពីមាត់របស់សាក្សីទេ។ អ៊ីចឹងលោកចៅក្រម តើលោកមានឯកសារយោងណាច្បាស់លាស់ពាក់ព័ន្ធទៅនឹងការធ្វើបញ្ជីឈ្មោះមនុស្ស ដែលត្រូវដឹកតាមឡានចេញទៅហ្នឹងទេ? មានតែពីមាត់ព្រះរាជអាជ្ញាប៉ុណ្ណោះ ដែលនិយាយថាអំពីបញ្ជីនោះ សាក្សីគាត់មិនបាននិយាយទេ។

[១៤:២៩:១៦]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំយោងទៅនឹងឯកសារដូចសហព្រះរាជអាជ្ញាដែរ ដែលបានបញ្ហាញថាមានបញ្ជីឈ្មោះមនុស្ស។ អ៊ីចឹងហើយបានជាខ្ញុំសួរទៅសាក្សី តើថាគាត់នេះ មានបានទទួលបញ្ជីឈ្មោះមនុស្សហ្នឹងពីស្រុកទេ?

**លោក សាន់ ឡួន៖**

**ឆ៖** បាទ ខ្ញុំអត់បានទទួលបញ្ជីទេ ព្រោះវាមានអ្នកទទួលខុសត្រូវ អ្នកយកសំបុត្រហ្នឹង គាត់អ្នកទទួល ខាងមន្ទីរស្រុកហ្នឹង គាត់អ្នកទទួលខុសត្រូវ។ ឯខ្ញុំអត់បានដឹងរឿងនេះទេ គ្រាន់តែបានដឹកតែប៉ុណ្ណោះ។

**ស៖** លោកបានឆ្លើយថាពេលទៅដល់ គឺប្រធានឈ្លបរង់ចាំនៅទីនោះ ហើយនិងមានឈ្លប១០នាក់។ អ៊ីចឹងខ្ញុំចង់ដឹងថាឈ្លបដែលទទួលហ្នឹងមានតែ១០នាក់ទេ ឬក៏លើសពី១០នាក់ ហើយមានកាំភ្លើងទេ?

**ឆ៖** អ្អែ កាលនោះ ដឹងមានអត់ទេ ភ្លេចហើយ។

**ស៖** ពេលដែលលោកទៅប្រមូលមនុស្សតាមឃុំនោះ តើពេលដែលយើង -- ពេលដែលលោកឲ្យមនុស្សឡើងលើឡាននោះ មានឈ្លបនៅឈរចាំមើលទេ?

**ឆ៖** បាទ អត់មានទេ អត់មានឃើញ។ ឃើញតែប្រធានឃុំ ហៅគាត់ឲ្យឡើងឡានតែម្តង។

[១៤:៣១:៤៦]

**ស៖** ហើយប្រធានឃុំហ្នឹងប្រាប់ប្រជាជនទាំងអស់ហ្នឹងថាយ៉ាងម៉េចខ្លះ?

**ឆ៖** ថាបញ្ជូនទៅស្រុកវៀតណាមវិញ។ បាទខ្ញុំឮអ៊ីចឹង។

**ស៖** ហើយប្រជាជនហ្នឹងគាត់មានអីវ៉ាន់ផ្ទាល់ខ្លួនទៅតាមជាមួយទេ?

**ឆ៖** បាទ មានៗខោអាវ មានកញ្ជើ មានល្អី ចាន ឆ្នាំង មួយការរស់នៅរបស់គាត់។

**ស៖** លោកស្តាប់ឮប្រជាជនទាំងអស់ហ្នឹងជជែកគ្នា ឬក៏និយាយគ្នាពីអ្វីទេ?

**ឆ៖** បាទ អត់, អត់ស្តាប់បានដែរ។

**ស៖** ពេលដែលប្រជាជនឡើងជិះឡាននោះ លោកមានបានឃើញដោយផ្ទាល់ភ្នែកថាអាចមានហេតុការណ៍អីកើតឡើង មានការតបត ឬក៏តដៃ ឬក៏អីទេ?

**ឆ៖** បាទ អត់ទេ អត់ឃើញហេតុការណ៍អីផង។

**ស៖** អ៊ីចឹងអត់មានអ្នកណាខ្លះគាត់ព្យាយាមតដៃអីទេមែនទេ?

**ឆ៖** អត់មាន។

**ស៖** ពេលដែលលោកដឹកមនុស្សទៅដល់មន្ទីរស្រុកនោះ លោកមានឃើញឡានទៅរង់ចាំដឹកអ្នកទាំងអស់ហ្នឹងបន្តទៅណាទៀតទេ?

[១៤:៣៤:០៦]

**ឆ៖** បាទ អត់ឃើញ មានតែឡានខ្ញុំមួយហ្នឹង។ អត់ឃើញឡានផ្សេងទៀត អត់ ខ្ញុំដាក់រួចក៏ត្រឡប់មកវិញមក។

**ស៖** តើលោកមានឃើញថា គេមាននាំប្រជាជនទាំងអស់ហ្នឹងទៅកន្លែងណាមួយទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹង ព្រោះខ្ញុំឆ្លើយថាខ្ញុំដាក់ហើយ ក៏ត្រឡប់មកកន្លែងវិញ បាទអត់បានដឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដោយសារតែពេលខ្លី ដូច្នេះខ្ញុំមិនអាចសួរសំណួរបានច្រើនទេ សូមបញ្ចប់ត្រឹមនេះ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមជម្រាបជាមុនថា យើងបានឯកភាពជាមួយមេធាវី កូប៉េ ហើយថា ខ្ញុំចាប់ផ្ដើមសួរមុនសិន បន្ទាប់មកទើបគាត់សួរបន្ថែមនៅពេលក្រោយ លោកប្រធាន។

ជាភាសាអង់គ្លេសមានបញ្ហាបកប្រែ។ ខ្ញុំៗបានបញ្ជាក់ថា ខ្ញុំនឹងសួរសំណួរមុន បន្ទាប់មកនៅសល់ប៉ុន្មានសម្រាប់មេធាវីការពារក្ដី គឺលោក មេធាវី នួន ជា គាត់នឹងសួរចុងក្រោយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ ដល់ពេលសមស្របនឹងសម្រាកដែរហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងបី ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុង

បន្ទប់សវនាការនេះនៅវេលាម៉ោងបី ខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥២ នាទី)*

[១៤:៥២:២៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី សាន់ ឡូន។ បាទ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក សាន់ ឡូន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៅកាន់លោក។ ខ្ញុំនឹងព្យាយាមសួរឲ្យបានជាក់លាក់ ហើយសូមឲ្យលោកឆ្លើយខ្លីៗទៅនឹងសំណួររបស់ខ្ញុំ។ ជាដំបូង ខ្ញុំចាប់អារម្មណ៍ទៅលើខ្សែជីវិតរបស់លោក។ ខ្ញុំចង់ដឹងថា លោកបានរៀនរហូតទៅដល់អាយុប៉ុន្មានដែរ?

[១៤:៥៤:១១]

**លោក សាន់ ឡូន៖**

**ឆ៖** បាទ ខ្ញុំរៀន ដំបូងគឺរៀនសាលាបឋម នៅសាលានៅជិតភូមិ ជិតផ្ទះ ប្រហែលជាបាន៣ឆ្នាំ បានប្រឡងជាប់ទៅរៀននៅអង្គតាសោម។

**ស៖** សំណួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំសួរថា តើលោករៀនរហូតទៅដល់អាយុប៉ុន្មាន?

**ធ៖** បាទ ខ្ញុំឆ្លើយសំណួរនេះ។ រៀនរហូតទៅដល់អាយុ២០ៗៗឆ្នាំ បានឈប់រៀន។

**ស៖** អ៊ីចឹងលោករៀនរហូតទៅដល់អាយុ២០ឆ្នាំ ដូច្នេះពេលលោកនៅតូចនៅសាលាបឋម ហើយនិងនៅពេលដែលលោកទៅដល់អាយុ២០ឆ្នាំហ្នឹង មានពេលណាមួយ លោកឈប់រៀនទេ?

**ធ៖** រៀនសាលា មាន រៀនដល់អាយុ២០ឆ្នាំហ្នឹង គឺឈប់រៀនតែម្តង។

**ស៖** អ៊ីចឹងមានន័យថា តាំងពីតូច ពីអាយុ៦, ៧ឆ្នាំ រហូតទៅដល់២០ឆ្នាំហ្នឹង លោករៀនរហូត មិនដែលផ្អាកនៅចន្លោះពេលណាមួយទេ គឺរៀនបន្តរហូតទៅដល់លោកអាយុ២០ឆ្នាំអ៊ីចឹងមែនទេ?

**ធ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** ដូច្នេះលោកចេះអាន និងចេះរាប់លេខច្បាស់ណាស់មែនទេ?

**ធ៖** បាទ មែន។

**ស៖** ខ្ញុំនឹងត្រឡប់មកចំណុចនេះនៅពេលក្រោយទៀត។ ឥឡូវនេះ ខ្ញុំចង់សុំឲ្យលោកបញ្ជាក់ពាក់ព័ន្ធទៅនឹងទំនាក់ទំនងជាមួយ តាម៉ុក។ លោកថា លោកជាប្អូនថ្លៃរបស់គាត់ ពីព្រោះប្រពន្ធ តាម៉ុក ជាបងស្រីរបស់លោក។ អ៊ីចឹងយើងគិតនៅឆ្នាំ៧៥ គឺជាថ្ងៃដែលខ្មែរក្រហមវាយបែកភ្នំពេញ អ៊ីចឹងខ្ញុំ បើធៀបនឹងឆ្នាំ៧៥ តើពេលណា ឆ្នាំណាដែរដែល តាម៉ុក រៀបការជាមួយនឹងបងស្រីរបស់លោកនោះ?

[១៤:៥៧:២៤]

**ធ៖** បាទខ្ញុំអត់បានដឹង។ មិនដឹងឆ្នាំណា។

**ស៖** ខ្ញុំដឹងថាលោកមិនអាចចាំកាលបរិច្ឆេទច្បាស់លាស់ទេ ពីព្រោះថាវាយូរណាស់មកហើយ។ អ៊ីចឹងហើយបានជាខ្ញុំឲ្យលោកគិតយកឆ្នាំ៧៥ហ្នឹង ជាគោលតម្រុយ ពេលដែលបែកភ្នំពេញហ្នឹង អ៊ីចឹង បើលោកធៀបទៅនឹងឆ្នាំ៧៥ហ្នឹង តើ តាម៉ុក ហ្នឹងគាត់រៀបការជាមួយប្រពន្ធលោកហ្នឹងគឺមុនឆ្នាំ៧៥ ឬក៏ក្រោយពេលដែលខ្មែរក្រហមកាន់អំណាចហើយ?

**ធ៖** តាម៉ុក រៀបការគ្រួសារគាត់ហ្នឹងគឺមុន បាទមុន។ មុនហើយបានកើតហេតុក្រោយ។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ខ្ញុំចង់ឲ្យលោកយកឆ្នាំដដែលហ្នឹង ជាគោលតម្រុយ អ៊ីចឹងបើធៀបទៅនឹងឆ្នាំ៧៥ ខ្ញុំចង់ដឹងថាតើលោកជានីរសារនៅស្រុកត្រាំកក់ហ្នឹង គឺនៅឆ្នាំណាដែរ មុនពេលវាយបែកទីក្រុងភ្នំពេញ ឬក្រោយពេលវាយបែកទីក្រុងភ្នំពេញ?

**ធ៖** បាទ នីរសារហ្នឹង គឺមុនៗបែកទីក្រុងភ្នំពេញ។

**ស៖** លោកបាននិយាយអំពីមនុស្សជាច្រើនដែលធ្វើនៅក្នុងគណៈស្រុកត្រាំកក់។ លោកនិយាយ

អំពី យាយខុម ជាកូនស្រីរបស់ តាម៉ុក, ពេជ្រ ជឹម ហើយលោកថា ពេជ្រ ជឹម នេះកាន់តំណែងបន្តពីកូនរបស់ តាម៉ុក។ ដូច្នេះខ្ញុំចង់សួរលោកថា មុនពេលក្លាយជាលេខាស្រុកត្រាំកក់ តើ ពេជ្រ ជឹម ហ្នឹងធ្លាប់ធ្វើការនៅក្នុងស្រុកត្រាំកក់ហ្នឹងទេ ពីមុនពេលដែលគាត់ក្លាយជាលេខាស្រុកហ្នឹង? ហើយបើធ្វើ គាត់មានតំណែងអ្វីដែរ?

[១៥:០០:២២]

**ឆ៖** ពេជ្រ ជឹម នេះខ្ញុំ -- ពីមុនមកខ្ញុំអត់បានដឹងដែរ ព្រោះទើបដឹងថាគាត់ធ្វើជាស្រុក ធ្វើស្រុកជាមួយនឹង យាយខុម ហ្នឹង។

**ស៖** មុនពេលដែលគាត់ឡើងជំនួស ខុម តើលោកធ្លាប់ឃើញ ពេជ្រ ជឹម ទេ?

**ឆ៖** បាទ ធ្លាប់ឃើញតើ។

**ស៖** លោកឃើញគាត់ហ្នឹងក្នុងពេលអីដែរ? ហើយឃើញនៅកន្លែងណា?

**ឆ៖** បាទ ឃើញគាត់នៅពេលគាត់ត្រូវប្រជុំជាមួយនឹងផ្នែកឃុំ ហៅឃុំមកប្រជុំអីអ៊ីចឹងទៅបានឃើញគាត់។

**ស៖** គាត់ប្រជុំនៅមន្ទីរស្រុកមែនទេ?

**ឆ៖** បាទ នៅមន្ទីរស្រុក នៅកន្លែងគាត់។

**ស៖** ខ្ញុំសួរលោក មុនពេលដែលគាត់ឡើងជាលេខាស្រុក ហើយពេលដែលគាត់ប្រជុំជាមួយនឹងមេឃុំផ្សេងៗហ្នឹង លោកធ្វើការឲ្យគាត់ទេ? ព្រោះអម្បាញ់មិញនេះ លោកថាពេលដែលលោកធ្វើជានីរសារឲ្យ យាយខុម លោកក៏ត្រូវបំពេញភារកិច្ចតាមការចាត់តាំងរបស់អ្នកផ្សេងដែរ អ៊ីចឹងតើ ពេជ្រ ជឹម នេះគាត់បានចាត់តាំងឲ្យលោកធ្វើការអីទេ?

[១៥:០២:៤៥]

**ឆ៖** បាទ អត់ទេ។ គាត់អត់មានចាត់តាំងធ្វើអីទេ គ្រាន់តែធ្វើជានីរសារដដែល។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់។ ខ្ញុំនិយាយអំពីភារកិច្ច អ៊ីចឹងខ្ញុំចង់ដឹងថា ក្នុងពេលដែលលោកធ្វើជានីរសារនេះ តើគាត់មានធ្លាប់ប្រគល់ភារកិច្ចអីឲ្យលោកធ្វើទេ មុនពេលដែលគាត់ឡើងធ្វើជាលេខាស្រុកនោះ?

**ឆ៖** បាទអត់ អត់មានប្រគល់អី។

**ស៖** ខ្ញុំចង់ឲ្យលោកយកឆ្នាំបែកភ្នំពេញជាគោលតម្រុយដដែល។ តើលោកដឹងថា ពេជ្រ ជឹម

ឡើងធ្វើជាលេខាស្រុកត្រាំកក់ជំនួស យាយខុម មុន ឬក៏ក្រោយបែកភ្នំពេញ?

**ឆ៖** បាទ មុនបែកទីក្រុងភ្នំពេញ។ ហើយក្រោយមកក៏ ពេជ្រ ជឹម ហ្នឹងនៅស្រុកដដែល នៅជាលេខាស្រុកដដែល។

**ស៖** នៅថ្នាក់ស្រុកនេះ ខ្ញុំចង់ដឹងលោកស្គាល់ឈ្មោះ ចាយ ឬក៏ ចយ។ លោកស្គាល់ឈ្មោះនេះទេ? ជា ចាយ ឬក៏ ចយ?

**ឆ៖** ចាយ? ចាយ។

**លោក គង់ សំអុន៖**

បាទ លោកសាក្សីគឺឈ្មោះ ចាយ។

**លោក សាន់ ឡូន៖**

**ឆ៖** បើ ចាយ ខ្ញុំស្គាល់។ ចាវ អត់ស្គាល់។

[១៥:០៥:៥០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តើ ចាយ គាត់មានមុខងារអ្វីដែរនៅមន្ទីរស្រុក?

**ឆ៖** តាចាយ នៅមន្ទីរស្រុក កាលខ្ញុំនៅស្រុក គឺគាត់នៅខាងឃុំ។

**ស៖** គាត់ធ្វើអីនៅខាងឃុំហ្នឹង?

**ឆ៖** ខាងឃុំ គឺគាត់ធ្វើជាប្រធានឃុំ លេខាឃុំ។

**ស៖** ឃុំអីដែរលោក?

**ឆ៖** ឃុំដំណាក់ត្រាច។

**ស៖** ពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់នេះដដែល អម្បាញ់មិញនេះ លោកមេធាវី កូប៉េ គាត់បាននិយាយអំពីមនុស្សម្នាក់ដែលឈ្មោះ ឯក ហឿន ឬ អ៊ុល ហឿន។ លោកៗបានឆ្លើយថាលោកមិនស្គាល់ ឯក ហឿន ឬ អ៊ុល ហឿន នេះទេ។ លោកប្រាកដទេ ថាលោកមិនធ្លាប់ស្គាល់ឈ្មោះនេះ ឯក ហឿន ឬ អ៊ុល ហឿន? គាត់មានឈ្មោះពីរ។

**ឆ៖** បាទ អត់ៗស្គាល់មែន។

**ស៖** អ៊ីចឹងលោកមិនចាំថា គាត់មានមុខងារអ្វីនៅក្នុងស្រុកត្រាំកក់ទេ មែនទេ?

**ឆ៖** បើអត់ស្គាល់។

[១៥:០៨:៣៩]

**ស៖** ខ្ញុំមិនទទួលបានការបកប្រែជាភាសាបារាំងនូវចម្លើយរបស់លោកទេ សូមលោកឆ្លើយម្តងទៀត។ អ៊ីចឹងខ្ញុំសួរលោកម្តងទៀត អម្បាញ់មិញនេះខ្ញុំសួរលោកថា លោកប្រាកដទេថា ឯក ហឿន ឬ អ៊ុល ហឿន គឺលោកមិនស្គាល់គាត់ទេ លោកមិនដឹងថាគាត់ហ្នឹងមានមុខងារនៅក្នុងស្រុកត្រាំកក់ទេ មែនទេ?

**ឆ៖** បាទ មែន អត់ស្គាល់មែន។

**ស៖** ដូច្នេះគឺលោកមិនដែលសូម្បីតែឮឈ្មោះនេះមែនទេ?

**ឆ៖** បាទ អត់ដែលឮ។

**ស៖** លោកបាននិយាយអំពីវត្តមានរបស់ ពេជ្រ ជឹម នៅក្នុងគណៈស្រុក ហើយថាគាត់ហ្នឹងមានមុខងារផ្សេងៗ ដូចជាចៅហ្វាយស្រុក។ ហើយគាត់ៗបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ។ អ៊ីចឹងខ្ញុំចង់សួរលោកថា លោកមាននឹកឃើញអំពីកម្មវិធីដោះដូរគ្នារវាងខ្មែរក្រោម ដែលរស់នៅវៀតណាម និងជនជាតិវៀតណាមដែលរស់នៅកម្ពុជា។ អម្បាញ់មិញនេះ លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាជាតិ អំពីការចូលរួមរបស់លោកក្នុងការដឹកជញ្ជូនជនជាតិវៀតណាត្រឡប់ទៅវៀតណាមវិញ។ អ៊ីចឹងជាលក្ខណៈទូទៅ ខ្ញុំចង់សួរលោកថា លោកធ្លាប់ឮអំពីកម្មវិធីដោះដូរគ្នារវាងវៀតណាម ហើយនិងកម្ពុជាក្រោមទេ?

**ឆ៖** បាទ អត់ទេ អត់ដែលបានឮ។ អត់ដឹង។

[១៥:១១:១០]

**ស៖** កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ គឺជាថ្ងៃដែល ពេជ្រ ជឹម គាត់មកផ្តល់សក្ខីកម្មនៅក្នុងសវនាការ គឺក្រោយម៉ោង១០:០៨:២៣វិនាទី ពេជ្រ ជឹម គាត់ឆ្លើយថា៖ "បញ្ហាវៀតណាមត្រូវបានដោះស្រាយនៅពេលដែលមានការដោះដូរឲ្យជនជាតិវៀតណាមត្រឡប់ទៅស្រុកវិញ។" ដូច្នេះជាថ្មីម្តងទៀតលោកសាក្សី ខ្ញុំចង់សួរលោកថា តើលោកនឹកឃើញថា នៅពេលនោះ មានការដោះដូររវាងជនជាតិវៀតណាម និងខ្មែរកម្ពុជាក្រោមទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹង។ ដឹងតែកាលនោះ គេឲ្យទៅដឹកប្រជាជនអស់ទាំងនោះ មិនដឹងថាប្រជាជនយ៉ាងម៉េច ខ្ញុំអត់បានដឹងដែរ។

**ស៖** ចំពោះ ពេជ្រ ជឹម ដដែលនេះ តើលោកចាំថា គាត់នៅធ្វើជាលេខាស្រុកត្រាំកក់នេះ អស់

រយៈពេលប៉ុន្មានទេ? លោកដឹងថា មានពេលណាមួយនោះ គាត់ចាកចេញពីមុខតំណែងនេះទេ?

**ឆៈ** បាទ រឿងនេះ ខ្ញុំក្តាប់មិនបាន អត់បានដឹង។

**សៈ** លោកមាននឹកឃើញទេ ថានៅពេលដែលលោកចេញទៅរៀននៅបាត់ដំបង ពេជ្រ ជឹម គាត់នៅតែធ្វើជាលេខាស្រុកនៅត្រាំកក់ដដែល ឬក៏គេបញ្ជូនគាត់ទៅកន្លែងណាផ្សេងហើយ?

**ឆៈ** ពេលដែលគេបញ្ជូនខ្ញុំឲ្យទៅរៀននៅបាត់ដំបង គឺខ្ញុំមិនដឹងដែរ មិនដឹងជាគាត់នៅធ្វើជាលេខាស្រុកដដែល ឬមួយយ៉ាងម៉េច ព្រោះខ្ញុំទៅរៀនបាត់ហើយ ទៅរៀនបាត់ដំបង។

**សៈ** អ៊ីចឹងពេលដែលលោកធ្វើដំណើរចេញទៅនោះ ពេជ្រ ជឹម នោះគាត់នៅកាន់មុខតំណែងនៅស្រុកត្រាំកក់ហ្នឹងដដែលទេ?

**ឆៈ** បាទ នៅដដែល គាត់នៅធ្វើការនៅស្រុកត្រាំកក់ដដែល។

[១៥:១៥:00]

**សៈ** ចំពោះភាគីទាំងអស់ គឺកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/292.1 ខ្ញុំសូមដកស្រង់នូវប្រតិចារឹកសវនាការ គឺនៅមុនម៉ោង០៩:២៤នាទី គេបានឲ្យ ពេជ្រ ជឹម ប្រតិកម្មទៅនឹងចម្លើយមុនៗរបស់គាត់ ដែលគាត់ថា គាត់មកដល់ភូមិភាគកណ្តាលនៅខែកុម្ភៈ ឆ្នាំ៧៦ គឺសុំទោសគឺ ឆ្នាំ៧៧ ហើយគាត់បានឆ្លើយនៅក្នុងសវនាការថា គាត់ចង់កែប្រែវិញ គឺនៅខែមេសា -- ក្នុងខែកុម្ភៈ ឆ្នាំ៧៦ទេ។ ដូច្នេះលោកសាក្សី ខែកុម្ភៈ ឆ្នាំ៧៦ ឬឆ្នាំ៧៧នេះ លោកនឹកឃើញអ្វីទេ ពាក់ព័ន្ធទៅនឹងការចេញដំណើររបស់លោកទៅបាត់ដំបងនោះ?

**ឆៈ** សូមសួរម្តងទៀត។

**សៈ** លោកឆ្លើយថាលោក ពេលដែលលោកទៅបាត់ដំបង ពេជ្រ ជឹម នៅតែកាន់មុខតំណែងដដែលនៅស្រុក។ ខ្ញុំបានអាននូវចម្លើយរបស់ ពេជ្រ ជឹម នៅក្នុងសវនាការនេះ គាត់បានឆ្លើយថាគាត់បានចេញពីត្រាំកក់ នៅខែកុម្ភៈ ឆ្នាំ៧៦។ ដូច្នេះខ្ញុំចង់សួរលោកថាតើខែកុម្ភៈ ឆ្នាំ៧៦នេះ ធ្វើឲ្យលោកមាននឹកឃើញអ្វីទេ ពាក់ព័ន្ធទៅនឹងការចាកចេញរបស់លោកទៅបាត់ដំបងនោះ?

**ឆៈ** បាទ ដែលរឿងនេះខ្ញុំអត់បានយល់ដឹង បាទអត់ដឹង។ ដល់នៅ ខ្ញុំនៅរៀនមេច្បារ បាត់ដំបងនោះ។

[១៥:១៧:២៥]

**សៈ** ខ្ញុំយល់ថាលោកទៅរៀននៅបាត់ដំបង ក៏ប៉ុន្តែសំណួរខ្ញុំ គឺចង់ឲ្យលោកមានប្រតិកម្មតបទៅ

នឹងចម្លើយរបស់ ពេជ្រ ជឹម។ ពេជ្រ ជឹម គាត់បានឆ្លើយនៅក្នុងសវនាការនេះថា គាត់បានចាកចេញពីស្រុកត្រាំកក់នៅខែកុម្ភៈ ឆ្នាំ១៩៧៦។ លោក លោកឆ្លើយថាលោកចេញទៅបាត់ដំបងនៅពេលដែល ពេជ្រ ជឹម នៅធ្វើជាលេខាស្រុកដដែល។ អ៊ីចឹងខ្ញុំចង់សួរលោកថា កាលបរិច្ឆេទដែលៗ ពេជ្រ ជឹម គាត់ថា គាត់ចាកចេញពីត្រាំកក់នៅខែកុម្ភៈ ឆ្នាំ៧៦នេះ វាធ្វើឱ្យលោកឃើញ នឹកឃើញកាលបរិច្ឆេទអ្វីពាក់ព័ន្ធទៅនឹងការចេញដំណើររបស់លោកទៅបាត់ដំបងទេ? បើលោកនឹកមិនឃើញទេ មិនអីទេ លោកគ្រាន់តែប្រាប់ថា លោកនឹកមិនឃើញទៅ។

**ឆ៖** បាទ ខ្ញុំនឹកមិនឃើញទេ។

**ស៖** ចំណុចមួយដែលខ្ញុំចង់សុំការបំភ្លឺពីលោក។ ក្នុងអំឡុងពេលដែលលោកកាន់មុខងារនៅក្នុងស្រុកត្រាំកក់ និងក្រោយពេលភ្នំពេញបែក តើលោកមានឈ្មោះហៅក្រៅអ្វីផ្សេងពីឈ្មោះលោក សាន់ ឡួន នេះ ទេ?

**ឆ៖** មានឈ្មោះ អាម៉ូញ – ម៉ូញ។

**ស៖** ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីរយៈពេល៤ថ្ងៃ ដែលលោកត្រូវបានចាត់តាំងឱ្យដឹកមនុស្សតាមឡាន។ លោកបានឆ្លើយជាច្រើនទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ ដោយបញ្ជាក់នូវចម្លើយដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺថានៅក្នុងឡានហ្នឹង គឺមានសុទ្ធតែមនុស្សដែលត្រូវដឹក ហើយនិងអីវ៉ាន់របស់ពួកគេ។ ដូច្នេះខ្ញុំចង់សួរលោក ខ្ញុំមិននិយាយអំពីឆ្នាំពិតប្រាកដទេ ខ្ញុំគ្រាន់តែចង់ឱ្យលោកចាំថា តើរដូវណាដែលលោកដឹកប្រជាជនហ្នឹង លោកនឹកឃើញ លោកនឹកមើលឡើងវិញទៅមើល ក្នុងរដូវណាដែរ រដូវប្រាំង ឬក៏រដូវវស្សា?

[១៥:២០:២៤]

**ឆ៖** បាទ ការដឹកនោះគឺក្នុងរដូវប្រាំង។

**ស៖** លោកបានឆ្លើយថា លោកមានឡានធំ ហើយឡានទំនុងដឹកមនុស្សបាន៥០ទៅ៦០នាក់។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ខ្ញុំក៏យល់ផងដែរ តាមរយៈសក្ខីកម្មរបស់លោកថា លោកទៅយកមនុស្សនៅតាមឃុំនីមួយៗ ហើយទៅតាមចំនួនមនុស្សនៅក្នុងឃុំនីមួយៗ ជួនកាលលោកដឹកមួយជើង ឃុំខ្លះទៅលោកដឹកពីរជើង។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ឥឡូវនេះខ្ញុំសូមលើកឡើងអំពីសក្ខីកម្មរបស់បុគ្គលដែលលោកមិនចាំគាត់នេះគឺ អ៊ុល ហឿន ហៅ ឯក ហឿន។ គាត់បាននិយាយជាលើកដំបូងថា លោកដឹកមនុស្សទាំងអស់៩.០០០នាក់។ គាត់ថាទៀតថា គឺលោកហ្នឹងហើយជាអ្នកប្រាប់គាត់ថា មនុស្សទាំងអស់នោះមានចំនួន៩.០០០នាក់។ ពេលដែលខ្ញុំសួរលោកអំពីការអប់រំនោះ លោកថាលោកបានរៀនរហូតទៅដល់អាយុ២០ឆ្នាំ ហើយលោកចេះរាប់លេខច្បាស់ណាស់។ អ៊ីចឹងត្រឹមត្រូវទេ សមហេតុផលទេ ពាក់ព័ន្ធទៅនឹងចំនួនមនុស្សដែលមាននៅក្នុងឡាននោះ គឺថាត្រឹមតែ៤ថ្ងៃនោះ លោកអាចដឹកដល់៩.០០០នាក់។ លោកគិតមើល សមហេតុផលទេ?

**ឆ៖** ការដឹកចំនួនមនុស្សទាំងអស់នេះ គឺខ្ញុំអត់បានដឹងចំនួនថា៩.០០០អីទេ អត់បានដឹង ព្រោះចំនួនទាំងអស់គឺនៅលើឃុំ ហើយនិងស្រុក អ្នកដឹងចំនួនមនុស្សទាំងអស់នេះ។

[១៥:២៣:៣១]

**ស៖** សូមអរគុណ។ ទោះបីជាលោកមិនដឹងតួលេខពិតប្រាកដក៏ដោយ លោកៗបាននិយាយថាឡានរបស់លោកដឹកមនុស្សបានពី៥០ទៅ៦០នាក់ ហើយលោកដឹកក្នុងរយៈពេល៤ថ្ងៃ។ លោកនៅរក្សាចម្លើយហ្នឹងទេ?

**ឆ៖** បាទ។

**ស៖** តាមរយៈបញ្ជីឈ្មោះនៅតាមឃុំដែលលោកបាននិយាយកាលពីព្រឹកមិញនេះ លោកនិយាយមានប្រាំមួយឃុំ ហើយលោកទៅដឹកមនុស្សតាមឃុំទាំងប្រាំមួយហ្នឹង។ ដូច្នេះចាំទេថា ក្នុងរយៈពេលមួយថ្ងៃ លោកអាចទៅដឹកប្រជាជនបានច្រើនឃុំ មែនទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ប្រហែលជាសំណួរខ្ញុំស្មុគស្មាញពេកលោកប្រធាន។ ខ្ញុំនឹងសួរតាមរបៀបផ្សេង ខ្ញុំបំបែកសំណួរឱ្យតូចៗវិញ ងាយស្រួលជាង។ លោកសាក្សី បើតាមការចងចាំរបស់លោក គឺលោកពីពេលព្រឹកលោកទៅយកមនុស្សនៅក្នុងឃុំមួយ ហើយពេលរសៀល លោកទៅដឹកប្រជាជននៅក្នុងឃុំមួយទៀត។ តើលោកនឹកឃើញថាលោកបានធ្វើអ៊ីចឹងទេ?

[១៥:២៥:៣៤]

**លោក សាន់ ឡូន៖**

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** ដូច្នេះខ្ញុំចង់សួរលោកថា ក្នុងរយៈពេល៤ថ្ងៃដែលលោកដឹកជញ្ជូនមនុស្សនោះ គឺថាមួយថ្ងៃលោកអាចដឹកមនុស្សបានលើសពីពីរឃុំ មែនទេ?

**ឆ៖** បាទ។

**ស៖** ប្រសិនបើលោកចាំ តើលោកអាចជម្រាបបានទេថាថ្ងៃដំបូង លោកទៅដឹកប្រជាជនពីឃុំណាខ្លះ?

**ឆ៖** លើកដំបូង មិនដឹងឃុំណាទេ ភ្លេចហើយ យូរឆ្នាំ។

**ស៖** មិនជាអ្វីទេ ខ្ញុំយល់អំពីចំណុចនេះ។ អ៊ីចឹងលោកឯកភាពទេ ថាលោកមានឡានតែមួយទេហើយមានតែលោកម្នាក់គត់នៅពេលដែលដឹកទៅដឹកមកហ្នឹង គឺលោកតែម្នាក់ឯង មានឡានតែមួយហើយលោកដឹកប្រជាជនហ្នឹង គឺដឹកពីឃុំមួយៗហ្នឹងទៅដល់ស្រុក អ៊ីចឹងមែនទេ?

**ឆ៖** ឡានហ្នឹងមានខ្ញុំហ្នឹង ខ្ញុំជាអ្នកបើក ប៉ុន្តែម្នាក់ទៀតវាអ្នកទៅជាមួយសម្រាប់ ហៅថាសម្រាប់មើលឡានថែឡាន គេហៅថាព្រូណា ព្រូឡាន ជួយការងារ ពេលឡានខូចទៅជួយគ្នាអ៊ីចឹងទៅ។

**ស៖** បាទ អ៊ីចឹងព្រូឡានហ្នឹងនៅក្នុងឡានជាមួយនឹងលោកដែរមែនទេ?

**ឆ៖** បាទ នៅជាមួយគ្នា។

[១៥:២៨:១៤]

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ ឬក៏សហព្រះរាជអាជ្ញាទេខ្ញុំមិនច្បាស់ទេ លោកថាពេលដែលលោកដាក់មនុស្សនៅស្រុក គឺប្រគល់ជូនប្រធានឈ្លបស្រុកហើយលោកត្រឡប់មកផ្ទះវិញ។ ខ្ញុំចង់សួរលោកថា ពីផ្ទះរបស់លោកទៅកន្លែងដែលលោកដាក់មនុស្សចុះហ្នឹងមានចម្ងាយប៉ុន្មានគីឡូម៉ែត្រដែរ?

**ឆ៖** ពីកន្លែងខ្ញុំនៅហ្នឹងទៅកន្លែងដាក់មនុស្សចុះហ្នឹងប្រហែលជា១០គីឡូ ថា១០គីឡូ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីមុខងាររបស់លោកជានីរសារ។ លោកឆ្លើយថាលោកធ្វើជានីរសារឲ្យ យាយខុម និងជាទូទៅធ្វើលេខាឲ្យ -- ធ្វើជានីរសារឲ្យគណៈស្រុក។ លោកបាននិយាយអំពីកិច្ចប្រជុំជាច្រើនដែលបានប្រព្រឹត្តទៅនៅមន្ទីរស្រុក គឺលោកបាននិយាយជាមួយសហព្រះរាជអាជ្ញា

អំពីបញ្ហាប្រជុំនេះ។ ឥឡូវនេះខ្ញុំសូមនិយាយអំពីកិច្ចប្រជុំដែលលោកបានចូលរួមក្នុងឋានៈលោកជានីរសារ។ ខ្ញុំចង់ដឹងថា លោកជានីរសារហ្នឹង លោកអាចចូលរួមក្នុងកិច្ចប្រជុំណាខ្លះបាន? ហើយចូលរួមហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ក្នុងឋានៈជានីរសារនេះ មិនអាចចូលរួមប្រជុំជាមួយថ្នាក់ស្រុកបានទេ។

**ស៖** ដូច្នេះមានន័យថា នៅពេលដែលលោកនិយាយអំពីកិច្ចប្រជុំនៅថ្នាក់ស្រុកនោះ មានន័យថា លោកមិនបានចូលរួមទេ។ លោកបាននិយាយអំពីប្រជុំរវាង តាម៉ុក និងចៅហ្វាយស្រុក។ អ៊ីចឹងលោកមិនបានចូលរួមក្នុងកិច្ចប្រជុំបែបហ្នឹងទេ មែនទេ?

[១៥:៣១:០៤]

**ឆ៖** មិនបានចូលរួមប្រជុំ។

**ស៖** លោកសាក្សី សូមលោកឆ្លើយម្តងទៀត អម្បាញ់មិញនេះអ្នកបកប្រែមិនបានបកប្រែនូវចម្លើយរបស់លោកជាភាសាបារាំងទេ។

**ឆ៖** សុំសំណួរម្តងទៀតមើល។

**ស៖** អម្បាញ់មិញនេះ ខ្ញុំសួរលោក ថានៅពេលដែលលោកនិយាយអំពីកិច្ចប្រជុំជាច្រើន រវាងតាម៉ុក និងលេខាស្រុកនោះ ខ្ញុំសួរបញ្ជាក់ថា លោកមិនដែលបានចូលរួមក្នុងកិច្ចប្រជុំបែបហ្នឹងទេ មែនទេ?

**ឆ៖** បាទ មែន អត់ដែលបានប្រជុំទេ។

**ស៖** លោកក៏បាននិយាយអំពីកិច្ចប្រជុំជាមួយ ពេជ្រ ជឹម មុនពេលគាត់ឡើងជាលេខាស្រុក គឺពេជ្រ ជឹម គាត់ប្រជុំជាមួយលេខាឃុំ។ អ៊ីចឹងលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយជាមួយ ពេជ្រ ជឹម ហ្នឹងទេ?

**ឆ៖** បាទ អត់ទេ អត់ដែល។ អត់ត្រូវការ ត្រូវប្រជុំអីជាមួយស្រុក។

**ស៖** ចុះលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំនៅថ្នាក់ឃុំទេ?

**ឆ៖** បាទ អត់។

[១៥:៣៣:១៧]

**ស៖** លោកបាននិយាយជាមួយសហព្រះរាជអាជ្ញាអំពីរយៈកាលមុនឆ្នាំ៧៥ ខ្ញុំគិតថា ដូចជាឆ្នាំ៧១, ឆ្នាំ៧២ ជាឆ្នាំដែលលោកធ្វើជាប្រធានភូមិ។ ដូច្នេះតើលោកអាចបញ្ជាក់បានទេ លោកពិតជាបាន

ធ្វើជាប្រធានភូមិមែនទេ? ហើយពេលលោកធ្វើជាប្រធានភូមិហ្នឹង លោកមានបានចូលរួមប្រជុំទេ?

**ឆ៖** បាទ ពេលនោះគឺឆ្នាំ៧១, ៧២ហ្នឹងបានធ្វើជាប្រធានភូមិមែន ហើយក៏បានរួមប្រជុំញឹកញាប់គឺនៅក្នុងខាងឃុំ ហើយខាងស្រុក យូរៗម្ដង ហ្នឹងអ៊ីចឹង។

**ស៖** ចាប់ពីពេលដែលលោកក្លាយជានីរសារ នៅមន្ទីរស្រុក តើលោកបន្តកាន់តំណែងហ្នឹងជាមេភូមិទៀតទេ?

**ឆ៖** រួចគឺឈប់ផ្លាស់ឲ្យគេធ្វើម្ដង។

**ស៖** ដូច្នេះមានន័យថា ពេលដែលលោកធ្វើជានីរសារស្រុកហ្នឹង លោកមិនដែលបានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ភូមិ ថ្នាក់ឃុំ ឬថ្នាក់ស្រុកទេ មែនទេ?

**ឆ៖** បាទ ហ្នឹងហើយ ត្រឹមត្រូវ។

**ស៖** លោកបានលើកឡើងនូវចំណុចមួយចំនួន ជាមួយមេធាវី កូប៉េ និងជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទៅនឹងបញ្ហាអតីតទាហាន លន់ នល់។ ខ្ញុំចង់សួរលោកជាទូទៅ តើលោកចាំថាមុនពេលរំដោះទីក្រុងភ្នំពេញ ហើយនិងក្រោយពេលរំដោះភ្នំពេញហ្នឹង តើមានការប្រព្រឹត្តយ៉ាងម៉េចខ្លះចំពោះទាហាន លន់ នល់?

[១៥:៣៦:៣១]

**ឆ៖** បាទ ខ្ញុំអត់បានដឹង។

**ស៖** មុនខែមេសា ឆ្នាំ១៩៧៥ តើលោកដឹងថាមានជម្លោះប្រដាប់អាវុធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះទេ?

**ឆ៖** បាទ អត់ៗដឹង។

**ស៖** ក្នុងពេលដែលលោកបំពេញមុខងារជាប្រធានភូមិ តើលោកដឹងថាមានទាហានណាមករកស្បៀងនៅក្នុងភូមិរបស់លោកទេ ក្នុងពេលដែលមានជម្លោះប្រដាប់អាវុធហ្នឹង?

**ឆ៖** ក្នុងពេលនោះ អ្នកដែលមករកស្បៀងគឺទាហានខាង លន់ នល់ៗ ទាហាន មករកស្បៀងមករកអីហ្នឹង។

**ស៖** ពេលមករកស្បៀងហ្នឹងទាហានលន់ នល់ មករកស្បៀងហ្នឹងនៅឆ្នាំណាដែរ លោកចាំទេ?

**ឆ៖** បាទ អត់ចាំ។

**ស៖** អ៊ីចឹងពេលនុ៎ង តើមានមេដឹកនាំខ្មែរក្រហមណាមួយនៅក្នុងភូមិរបស់លោកហ្នឹងទេ?

**ឆ៖** បាទ អត់ដឹង ក្ដាប់អត់បាន។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពី តាម៉ុក និងរបៀបធ្វើការងាររបស់ តាម៉ុក ជាមួយនឹងស្រុកត្រាំកក់។ លោកឆ្លើយថា គាត់មាននីរសារមួយឈ្មោះ ទូច ហើយនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា លោកថាតាមរយៈ ទូច នេះហើយដែល តាម៉ុក បញ្ជូនបទបញ្ជាមក។ ដូច្នេះពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំចង់សួរលោកដូចតទៅ នៅពេលដែល ទូច នាំសំបុត្រមកស្រុក តើលោកដឹងអំពីខ្លឹមសារនៅក្នុងសំបុត្រហ្នឹងទេ?

[១៥:៤០:០២]

**ឆ៖** ពេលដែល ទូច នាំសំបុត្រមកស្រុក ខ្ញុំអត់បានដឹងខ្លឹមសារសំបុត្រនោះទេ។

**ស៖** ដូច្នេះនៅពេលដែលលោកនិយាយថា តាម៉ុក បញ្ជូនបញ្ជាមកនោះ លោកមិនដឹងថាមានព័ត៌មានអ្វីខ្លះនៅក្នុងសំបុត្រដែលគេនាំយកមកហ្នឹងទេ មែនទេ?

**ឆ៖** ពិតមែន។

**ស៖** ដូច្នេះខ្ញុំចង់សួរលោកទៀតថា ម៉េចបានជាលោកហ៊ាននិយាយថា តាម៉ុក ចេញបញ្ជាឲ្យចាប់មនុស្សនោះ បើលោកមិនដឹងថានៅក្នុងសំបុត្រនុំងមានខ្លឹមសារយ៉ាងណាផងនោះ?

**ឆ៖** បានជាខ្ញុំហ៊ានថា បញ្ជា លោកតាម៉ុក បញ្ជាឲ្យចាប់មនុស្សនោះ គឺទាល់តែការបញ្ជារបស់គាត់ ហ្នឹងទើបខាងក្រោមចាប់បាន។ ហ្នឹងខ្ញុំយល់អ៊ីចឹង ដឹងអ៊ីចឹង។

**ស៖** ក៏ប៉ុន្តែមុននេះ នៅពេលដែលខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅថ្នាក់ភូមិ ឬថ្នាក់ឃុំ ឬថ្នាក់ស្រុក នៅពេលដែលលោកធ្វើជានីរសារនោះ លោកថា លោកមិនដែលបានចូលរួមក្នុងកិច្ចប្រជុំទាំងអស់ហ្នឹងទេ។ អ៊ីចឹងម៉េចបានជាលោកដឹងអំពីតួនាទី ឬក៏អំណាចរបស់អ្នកណាម្នាក់នោះ បើលោកមិនបានចូលរួមក្នុងការប្រជុំទាំងអស់នោះផង?

[១៥:៤២:៣៦]

**ឆ៖** ខ្ញុំមិនបានចូលរួមប្រជុំទេ ហើយតួនាទីថ្នាក់ដឹកនាំអី ក៏អត់ដឹងដែរ អត់យល់។

**ស៖** លោកថាលោកមិនចាំអំពីឈ្មោះ អ៊ុល ហឿន ទេ។ ឥឡូវនេះខ្ញុំសូមអានចម្លើយរបស់គាត់ជូនអង្គជំនុំជម្រះ។ គាត់ៗបាននិយាយអំពីលោក គឺនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥។ គឺនៅចន្លោះពីម៉ោង១១:០២នាទីទៅដល់ម៉ោង១១:០៤នាទី នេះជាចម្លើយរបស់ អ៊ុល ហឿន ខ្ញុំសូមដកស្រង់៖ "ខ្ញុំជួបឡួន ជាប្អូនថ្លៃរបស់ តាម៉ុក ហើយខ្ញុំចាំពីឈ្មោះ មួយ។ គាត់បាននិយាយអំពីការដឹកជនជាតិវៀតណាម

ទៀត។ គាត់ថា ខ្ញុំសួរថាមានមនុស្សប៉ុន្មាននាក់ គាត់និយាយអំពីលោកនេះ លោកប្រាប់គាត់ថា មនុស្សទាំងអស់៩.០០០នាក់ ឬក៏៩.០០០គ្រួសារ។" សូមបញ្ចប់ការដកស្រង់។ មុននេះខ្ញុំសួរថា លោកបានលេខ ៩.០០០នេះមកពីណា លោកថា លោកមិនដឹងទេ លោកមិនដឹងថាមានប៉ុន្មានទេ។ ដូច្នេះខ្ញុំចង់សួរលោកថា តើលោកមានបានជជែកគ្នាជាមួយ ឯក ហឿន ឬ អ៊ុល ហឿន នេះដែរឬទេ? ហើយលោកមានបាននិយាយប្រាប់គាត់ថា លោកបានដឹកមនុស្ស៩.០០០ដែរឬទេ?

**ឆ៖** ថាម៉េចទេ ខ្ញុំមិនច្បាស់ដែរ អត់ច្បាស់ ដឹងបានជជែក ឬមួយក៏បានប្រាប់ អីយ៉ាងម៉េចខ្ញុំពិបាកដែរ អត់ច្បាស់ទេ មានការភ្លេច ហើយអាម៉េចមិនដឹងទេ។ ឬមួយក៏ខ្ញុំ--

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាល! និយាយសិន កុំអាល! និយាយទៅក្បាលមីក្រូហ្វូនអត់បើប្រតិបត្តិការហ្នឹង ដូចលោកអត់និយាយអីចឹង និយាយតែម្នាក់ឯងអីចឹង។

**លោក សាន់ ឡូន៖**

**ឆ៖** ខ្ញុំមិនបានដឹងចំនួនមែន គ្រាន់តែដឹក។

[១៥:៤៦:២៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឯក ហឿន ដដែលនេះគឺនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E1/298.1 គាត់និយាយអំពីបុគ្គលដែលចេញបញ្ជាមកលោក។ ហើយនៅថ្ងៃនេះលោកបាននិយាយ ក៏ដូចជានៅពេលដែលលោកនិយាយនៅក្នុងកំណត់ហេតុរបស់លោក លោកនិយាយអំពីឈ្មោះ ភី លោកថាលោកទទួលបញ្ជាពី ភី។ នេះជាចម្លើយរបស់ ឯក ហឿន ឬ អ៊ុល ហឿន ខ្ញុំសូមដកស្រង់៖ "គាត់មិនទទួលបញ្ជាពីតាម៉ុក ឬពីតំបន់ទេ គឺទទួលបញ្ជាពី តាចាយ។" ដូច្នេះលោកសាក្សី តើលោកនឹកឃើញទេថា តាចាយ ឬក៏ ភី ជាអ្នកចេញបញ្ជាមកឲ្យលោកនោះ?

**ឆ៖** មានតែ ភី ដែលចេញបញ្ជាឲ្យខ្ញុំ ឈ្មោះ ភី។

**ស៖** លោកថា តាចាយ ជាប្រធានឃុំ ដូច្នេះគាត់ធ្លាប់ចេញបញ្ជាណាមួយឲ្យលោកធ្វើការអ្វីមួយនៅមន្ទីរស្រុកដែរឬទេ?

**ឆ៖** បាទ អត់ទេ។

**សៈ** តើលោកចាំថាលោកធ្លាប់ជជែកគ្នាជាមួយ ឯក ហឿន ឬ អ៊ុល ហឿន ឬក៏ជាមួយអ្នកណាផ្សេងទៀតដែលលោកថាលោកទទួលបញ្ជាពី តាចាយ ទេ?

**ឆៈ** បាទ អត់ទេ អត់។

[១៥:៤៩:០៤]

**សៈ** ចំណុចចុងក្រោយពាក់ព័ន្ធនឹងការរៀនសូត្ររបស់លោក លោកឆ្លើយថាលោកបានចេញពីត្រាំកក់ ទៅបាត់ដំបងតាមបញ្ជារបស់ តាម៉ុក គឺតាម៉ុក ឲ្យលោកទៅរៀនសូត្រនៅបាត់ដំបង។ ដូច្នេះលោកចាំទេ អ្នកណាជាអ្នកបង្រៀនលោកនៅបាត់ដំបងហ្នឹង?

**ឆៈ** ការបញ្ជូន – តាម៉ុក បញ្ជូនខ្ញុំឲ្យទៅរៀនមេច្បារបាត់ដំបងនោះ គឺការបង្រៀនជាមួយចិនៗ ហើយខ្មែរជាអ្នកបកភាសាចិននោះ។

**សៈ** លោកអាចជម្រាបបានទេ ចិនហ្នឹងគេបង្រៀនអំពីអ្វីដែរ?

**ឆៈ** ចិនគេបង្រៀនពីខាងកសិកម្ម ខាងធ្វើស្រែ ធ្វើស្រូវ បង្កាត់ពូជស្រូវ។

**សៈ** ចំណុចមួយផ្សេងទៀត លោកបាននិយាយអំពីការងាររបស់លោកជាប្រធានភូមិ តើលោកចាំទេ នៅស្រុកត្រាំកក់ ខ្មែរក្រហមបានមកដល់ស្រុកនេះ យូរមកហើយ មុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ឬក៏តែប៉ុន្មានថ្ងៃមុន ១៧ មេសា ឆ្នាំ៧៥ នេះទេ ដែលខ្មែរក្រហមបានចូលមកដល់? លោកអាចបញ្ជាក់បានទេ ១ឆ្នាំ, ២ឆ្នាំ, ៣ឆ្នាំ មុនពេលបែកទីក្រុងភ្នំពេញ ឬក៏យ៉ាងម៉េច?

**ឆៈ** បាទ ខ្ញុំមិនអាចបញ្ជាក់បាន មានការភ្លេចភ្លាំង។

**សៈ** នៅក្នុងពេលដែលលោកធ្វើការដឹកមនុស្សដូចដែលលោកបានឆ្លើយ តើលោកចាំទេ ថាក្រៅពីរយៈពេល៤ថ្ងៃហ្នឹង លោកមិនបានចូលរួមក្នុងការដឹកជញ្ជូនមនុស្សទៀតទេ គឺលោកដឹកតែត្រឹម៤ថ្ងៃនេះ តែប៉ុណ្ណោះ មែនទេ?

**ឆៈ** បាទ។

[១៥:៥២:៥៩]

**សៈ** លោកថា លោកមិនចាំថា មានការដោះដូរ ឬក៏អត់ទេ ក៏ប៉ុន្តែលោកបានឆ្លើយថា លោកចាំពេលដែលវៀតណាមត្រឡប់ទៅស្រុកវិញ។ លោកថា ពួកជនជាតិវៀតណាមត្រឡប់ទៅស្រុកវិញ។ ដូច្នេះទោះបីជាលោកមិនដឹងអំពីកម្មវិធីដោះដូរនេះក៏ដោយ តើលោកដឹងថា មានអ្នកណាខ្លះមកដល់ស្រុកត្រាំកក់ មកដល់សហករណ៍ត្រាំកក់? ហើយមានអ្នកណាមកដល់កន្លែងណាផ្សេងក្រៅពីត្រាំកក់ទេ?

លោកមានឃើញហ្វូងមនុស្សមកដល់ទេ ក្រោយពីជនជាតិវៀតណាមដែលត្រូវបានលោកដឹកចេញទៅនោះ?

**ឆ៖** បាទ អត់, អត់បានឃើញ។

**ស៖** គេបានសួរសំណួរលោក ថាតើលោកបានឃើញមនុស្សដែលលោកដឹកហ្នឹងជាថ្មីម្តងទៀតទេ? ឥឡូវនេះ ខ្ញុំចង់សួរលោកវិញ ថាតើក្នុងចំណោមមនុស្សដែលលោកបានដឹកចេញទៅហ្នឹង លោកស្គាល់អ្នកណាខ្លះទេ? ពីមុនមកលោកធ្លាប់ឃើញអ្នកណាខ្លះទេ ក្នុងចំណោមអ្នកទាំងអស់ហ្នឹង?

**ឆ៖** បាទ អត់ទេ, អត់ស្គាល់ អត់បានស្គាល់។

**ស៖** ដូច្នេះនៅពេលដែលគេសួរលោកថា លោកធ្លាប់ឃើញអ្នកទាំងអស់ហ្នឹងជាថ្មីម្តងទៀត លោកឆ្លើយថា លោកមិនស្គាល់ពួកគេទេ។ អ៊ីចឹងលោកអាចបញ្ជាក់ពីចំណុចនេះឲ្យបានច្បាស់ម្តងទៀតបានទេ ហេតុអីបានជាលោកមិនអាចជួបពួកគេម្តងទៀតនោះ?

[១៥:៥៥:២២]

**ឆ៖** ខ្ញុំមិនបានជួបពួកគេទាំងអស់នោះបានទៀតទេ ព្រោះខ្ញុំមកនៅឆ្ងាយកន្លែងស្រុក អ៊ីចឹងទៅវាមិនដឹងគាត់ទៅណាទៅណី។ ខ្ញុំអត់បានដឹង ក្តាប់មិនបាន។

**ស៖** អ៊ីចឹងលោកអាចបញ្ជាក់ឲ្យច្បាស់ទេ ថាពីមុនមកហ្នឹងលោកមិនធ្លាប់ស្គាល់អ្នកទាំងអស់ហ្នឹងទេ មែនទេ?

**ឆ៖** អត់សូវស្គាល់។

**ស៖** លោកសហព្រះរាជអាជ្ញាពេលដែលចាប់ផ្តើមសួរហ្នឹង គាត់សួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងចំណុចដែលថា នៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតសួរលោកហ្នឹង ពេលដំបូងឡើយនោះ គឺលោកមិនបានសហការដោយស្មោះត្រង់ទេ ព្រោះថាលោកបានឆ្លើយថាលោកមិនចាំអ្វីទាំងអស់។ ហើយលោកៗបានឆ្លើយថា នៅសម័យនោះលោកខ្លាច។ ខ្ញុំគិតថានៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោកនិយាយថាពេលខ្លះទៅលោកភ្លេចភ្លាំង លោកមិនចាំច្បាស់។ ដូច្នេះខ្ញុំចង់សួរលោកថា នៅថ្ងៃនេះ លោកឆ្លើយតាមការចងចាំរបស់លោក ឬក៏លោកលាក់លៀម លាក់បាំងការពិត?

**ឆ៖** បាទ ខ្ញុំនិយាយនេះគឺអត់មានលាក់លៀមអីទេ គឺនិយាយការពិត ជូនអស់លោកដោយស្មោះត្រង់។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំអស់សំណួរហើយ។ មេធាវី គង់ សំអុន ក៏អត់សំណួរដែរ។

**ប្រធានអង្គជំនុំ៖**

បាទ ចុងក្រោយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរសំណួរចុងក្រោយចំពោះសាក្សីនេះ បើសិនបើមាន។ សូមអញ្ជើញ!

[១៥:៥៨:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសួរសំណួរអស់ហើយ ដូច្នេះលែងមានសំណួរអីសួរទៀតហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ចាប់ពីផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយសវនាការនៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-889 និងមានសាក្សីបម្រុងមួយរូប 2-TCW-1008 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយអង្គជំនុំជម្រះសូមអរគុណ លោក សាន់ ឡុន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃ កន្លងមកនេះ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ឥឡូវនេះលោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានជួបតែសំណាងល្អ មានសុខភាពល្អ មានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក សាន់ ឡុន វិលត្រឡប់ទៅកាន់លំនៅឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួម

សវនាការនៅថ្ងៃចន្ទ ទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ជាកំណត់។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩នាទី)*